**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

សមាគមបុគ្គលិកសិក្សាខ្មែរ

* **ចំណងមិត្តភាពនិងការឧបត្ថម្ភគ្នាទៅវិញទៅមក**
* **ការពង្រឹងនិងពង្រីកចំណេះដឹង និង ជីវភាព**
* **ការការពារផលប្រយោជន៍គ្នានាំងផ្លូវចិត្ត - សំភារៈ**

**២៨**

# ទស្សនាវដ្ដី គ្រូបង្រៀន



ប្រាសាទព្រះវិហារ កសាងដោយព្រះបាទសុរិយាវរ្ម័នទី១

នាដើមសតវត្សរ៍ទី១១ នៅលើភ្នំព្រះវិហារ (កំពស់ ៦២៥ម) នៃជួរភ្នំដងរែក

ខែ កក្កដា-សីហា-កញ្ញា ឆ្នាំ ២០០៦
ផ្សាយចេញរាល់ត្រីមាស ពីទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ
១២៨B មហាវិថីព្រះនរោត្តម (ភ្នំពេញ)
ទូរស័ព្ទ : ០២៣ ២១៦ ១៨៤-០១១ ៨៨៣ ៩៨៨

# មាតិកា


**គណៈកម្មការរៀបរៀង និង និពន្ធ**

- លោក កែវ យ៉ារ
- លោក ជុំ ហ៊ីន
- លោកស្រី គុយ ផល្លា
- លោក ស្វាយ ទិត្យ
- លោកជំទាវ ប៉ែន ណារុល
- លោក ថោង បូរ៉ាន់
- លោក កៅ ជឿន
- លោកស្រី ប្រាក់ សូលីដា
- លោកស្រី នន់ សុខុំ
- លោក ប៉ែន សារុណ
- សមាជិក_សមាជិកាស.ប.ស.ខ

**គណៈកម្មការត្រួតពិនិត្យ**

- លោក យស់ អ៊ាង
- លោកជំទាវ ហួរ សិរី
- លោក ស៊ុង វ៉ាន់ថន
- លោកបណ្ឌិត អ៊ឹម កុច
- លោក សូង សារុន
- លោក ស៊ិន ស៊ីម

**វិចិត្រករ**

លោក ប៉ាន់ ត្រា

**ការីកុំព្យូទ័រ**

កញ្ញា ម៉ៃ សុនី

**គ្របខាងក្រៅ**

- ពីមុខៈ ប្រាសាទព្រះវិហារ
- ពីក្រោយៈ យុវសិស្ស ឌី គុជសារ



| ល.រ | ចំណងជើងអត្ថបទ | ទំព័រ |
|---|---|---|
| ១ | វិចារណកថា | ១ |
| | **រាជកិច្ច** | |
| ២ | អនុក្រឹត្យស្តីពីការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រី... | ២ |
| | **ទស្សនវិជ្ជាទូទៅ** | |
| ៣ | ទំនៀមទំលាប់ប្រពៃណីខ្មែរ ស្តីពីការអប់រំចរិយាសម្បត្តិ (ត) | ៤ |
| ៤ | សម្បត្តិវប្បធម៌លទ្ធកម្ម និងសម្បត្តិវប្បធម៌ធម្មជាតិ | ៧ |
| ៥ | ធនធានសំរាប់បំរើការបូជាប្រាសាទមួយ | ៩ |
| | **ចិត្តវិទ្យា-អប់រំ** | |
| ៦ | វិធីថ្មីដើម្បីអប់រំសិស្សខូច | ១០ |
| ៧ | គំរូនៃការសិក្សាមួយ | ១៣ |
| ៨ | ប្រភេទនៃចរិតលក្ខណៈ | ១៥ |
| | **វិទ្យាសាស្ត្រ និងពត៌មានវិទ្យា** | |
| ៦ | លំដាប់នៃការវិវត្តសរីរាង្គមនុស្ស | ១៧ |
| | **ការអប់រំ និងគរុកោសល្យ** | |
| ៧ | ការអប់រំ (តចប់) | ១៩ |
| ៨ | វិធីបង្រៀន និងកម្មវិធីសៀវភៅសិក្សាភាសាខ្មែរនៅបឋមសិក្សាបំពេញវិជ្ជាពីឆ្នាំ ១៩៥៣ ដល់ឆ្នាំ ១៩៧០ (ត) | ២១ |
| ៩ | កំណែលំអសាលារៀន : ជំហានដំបូងមួយ (ត) | ២៣ |
| ១០ | ការផលិតសំភារៈ និងការប្រើប្រាស់សំភារៈឧបទេសក្នុងការបង្រៀន... | ២៧ |
| ១១ | គំនូរ : វិធីបង្រៀនគំនូរ (ត) | ៣០ |
| ១២ | ភាសា : ព្យាង្គគំរូតសម័យខេមរយានកម្ម (ត) | ៣៣ |
| | **នាទីកំណាព្យ និង តំរិះ** | |
| ១៣ | យើងទាំងអស់គ្នាជួយការពារត្រីបឹងទន្លេសាប | ៣៦ |
| ១៤ | បានរស់ | ៣៨ |
| ១៥ | តម្រងមិនជ្រាបទឹក | ៣៩ |
| ១៦ | ល្បែងគណិតវិទ្យាពិសេស | ៤១ |
| ១៧ | វេទិកាស្ត្រី : មង្គលនៃស្ត្រី | ៤៤ |
| | **ពត៌មាន** | |
| ១៨ | តើលោកគ្រូ អ្នកគ្រូ ដឹងទេ...? | ៤៦ |
| ១៩ | ស្ថិតិសពខែមេសា-ឧសភា-មិថុនា ឆ្នាំ២០០៦ | ៤៧ |



**ទូរស័ព្ទផ្ទះគ្រូបង្រៀន**

ភ្នំពេញ : ០១២ ៨៩៧ ១៧៧, កំពត : ០១២ ៨៥៦ ៧២២, ក្រុងព្រះសីហនុ : ០១២ ៦៩៩ ៥៦០

សៀមរាប : ០៦៣ ៧៦០ ២១៣ / ០១១ ៨៩៧ ០៩៦ / ០១២ ៦៧៥ ៦៤០

# វិចារណកថា

បុព្វបុរសខ្មែរយើងបានអោយតំលៃខ្ពស់ដល់ស្រ្តីដែលអាចបញ្ជាក់តាមបញ្ញត្តិ ភាសិត ស្នាដៃ ភារកិច្ច និងលក្ខណៈពិសេសខាងក្រោមនេះ ÷

- បញ្ញត្តិជាច្រើនត្រូវបានទាក់ទងនឹង "មាតា" ÷

មេឃុំ មេភូមិ មេបា មេបុណ្យ...មាតុភូមិ(ពាក្យចុងក្រោយនេះនៅលើលោក គេនិយម "បិតា" ជា "ធំ") ។

- ភាសិត ពាក្យស្លោក ច្បាប់ក្បួនលើកសរសើរពីស្រ្តី ÷
  - "ទ្រព្យគង់ឡិតស្រ្តី ចេះរៀបដាក់ទុក"
  - "សូវស្លាប់បា កុំអោយស្លាប់មេ សូវលិចទូកកណ្តាលទន្លេ កុំអោយភ្លើងឆេះផ្ទះ"
  - "ទាល់តែមានប្រពន្ធ នោះទើបគង់ទ្រព្យ"
  - ប្រពន្ធល្អទុកដូចជាម្តាយ ( មាតុភរិយា)
- ស្នាដៃលេចធ្លោរបស់ស្រ្តីៈ
  - សាកលវិទ្យាធិការ ( ព្រះនាងឥន្រ្ទទេវី ព្រះជាយាព្រះបាទជ័យវរ្ម័នទី ៧)
  - ស្ថាបនា : ជោគជ័យការកសាងភ្នំស្រី ភ្នំរោងដំរី
  - កំណែទំរង់អាពាហ៍ពិពាហ៍ៈ ក្រោយពីឃើញភាពទន់ខ្សោយ អសកម្មរបស់បុរសក្នុងការស្ថាបនានានា : ភ្នំស្រី-ភ្នំប្រុស ភ្នំរោងដំរី ("ភ្នំជើងមីដែង" ជាពាក្យដែលបុរសចាញ់ស្រ្តី ហើយប្រើពាក្យ ទ្រគោះបោះបោកដាក់ស្រ្តី) ក្សត្រីដឹកនាំការស្ថាបនាភ្នំស្រីសំរេចអោយបុរសត្រូវដណ្តឹងស្រ្តីវិញដោយអោយពិសោធការងារមុនរៀបអាពាហ៍ពិពាហ៍ ។
- លក្ខណៈពិសេស : ប្រការសំខាន់ ស្រ្តីធ្វើអ្វីៗបានទាំងអស់ដូចជាបុរស តែបុរសមិនអាចធ្វើបានដូចស្រ្តីទេ នោះគឺការចិញ្ចឹមកូននៅក្នុងគភ៌ដែលជាការលំបាកលំបិន ហើយក្នុងករណីនេះ ប្រសិនបើចិញ្ចឹមកូនតាមបែបវិទ្យាសាស្រ្ត (ដាក់កែវ)វិញ នោះយើងត្រូវចំណាយលុយកាក់អស់យ៉ាងច្រើន ។

ប៉ុន្តែហេតុអ្វីបានជាត្រូវគេមើលស្រាលទៅវិញ ( បង្វិលមិនជុំជើងក្រាន) ។

នេះជាទស្សនៈខុសឆ្គងមួយដែលគេនិយមថា ការងារនៅទីឆ្ងាយមានតំលៃជាង ហើយគេក៏បានកែលំអជាបណ្តើរៗ÷ ពី "ប្តីរែក ប្រពន្ធទូល" មក "ស្មើ" គ្នាវិញក្នុងការចែកចាយទ្រព្យសម្បត្តិនៅពេលមានការលះលែងគ្នានោះ ហើយនៅចំពោះមុខនេះ ការងារយេនឌ័រត្រូវបានពង្រីក ពង្រឹងជារាល់ថ្ងៃ ។

គួរយើងត្រូវគិតថា "ការងារណាក៏ល្អដែរ" មិនគួរថា "ជិត វិឆ្ងាយ" ឡើយ ។ យើងកំណត់អោយបានច្បាស់អំពីសមភាពរវាងបុរស និងស្រ្តី ព្រោះស្រ្តីមានឯកទេសកម្មមួយ គឺទារកវប្បកម្មដែលត្រូវតែយកចិត្តទុកដាក់បំពាក់បំប៉នអោយបានដល់គ្រប់ស្រ្តីទាំងអស់ មិនគួរបង្កើតសមភាពរបៀប រែក សែង កាប់គាស់ ភ្ជួររាស់ ដើរចោលផ្ទះសំបែង ចោលកូនចៅដូចបុរសនោះឡើយ ៕

**គណៈកម្មាធិការនាយក**

រាជកិច្ច

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ១៤០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលថ្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ថាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- យោងតាមសេចក្តីជូនដំណឹងលេខ ១៧៥៩សជណ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីការតម្លើងប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការសំរាប់ឆ្នាំ២០០៦ និងយោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១**

តម្លៃឯកតានៃសន្ទស្សន៍មូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល ដូចមានចែងក្នុងមាត្រា ៤ វាក្យខ័ណ្ឌទី១ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្ដីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិលត្រូវកែប្រែពីចំនួន៣៤៥រៀល ទៅចំនួន៤០០រៀល ក្នុងមួយសន្ទស្សន៍។

**មាត្រា២**

តម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋាន ដូចមានកំណត់ក្នុងមាត្រា ១ ត្រូវចាប់អនុវត្តពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៦ តទៅ។

**មាត្រា៣**

អនុក្រឹត្យនេះ មានប្រសិទ្ធភាពអនុវត្តផងដែរចំពោះនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ។

**មាត្រា៤**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន។

**មាត្រា៥**

អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៥

**នាយករដ្ឋមន្ត្រី**

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានយកសេចក្ដីជំរាបជូន

សម្ដេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

និងជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

ហត្ថលេខា និងត្រា

**សុខ អាន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ




# សំលៀកបំពាក់ និងប្រពៃណីខ្មែរស្តីពីការគោរពមារយាទសង្គម (ត)

## ៤-សំលៀកបំពាក់ក្នុងឱកាសលៀងក្រយាហារ

ចំណែកខាងភ្ញៀវខ្មែរបុរាណក៏ប្រើពណ៌ដែរ តែមិនដូចសាមីខ្លួនអ្នកការទេ គេច្រើនស្លៀកពាក់ឱ្យសមរម្យតាមកិច្ចដែលហៅថា ជាមង្គល ព្រោះពណ៌ទាំងឡាយក្រៅអំពីស និងខ្មៅ ទុកជាពណ៌មង្គលដែលបង្កើតឡើងនូវសិរី។ បើគេពុំអាចជៀសអោយផុតពីស និងខ្មៅ គេតែងតែចម្រុះលាយពណ៌ គេមិនស្លៀកពាក់សសុទ្ធទេ ត្បិតពណ៌សជាពណ៌សម្រាប់កាន់ទុក ឯពណ៌ខ្មៅជាពណ៌ដែលមិនរាប់ចូលក្នុងមង្គល។

ដូច្នេះ បុរសគេច្រើនស្លៀកសំពត់ពណ៌ផ្សេងៗ និងពាក់អាវស។ ស្រីៗគេប្រើស្ទើរតែពណ៌ទាំងអស់ គឺស្លៀកខៀវ ជាម្ពូង ហូល ។ល។ ពាក់អាវពណ៌លាត ពណ៌ផ្កា ទាំងក្រមាបង់ក ក៏មានពណ៌ មានផ្កាទៀតផង។

ដល់អារ្យធម៌អឺរ៉ុបចូលមក យើងយកបែបផែនគេមកប្រើជាច្រើនតាមសម័យនិយម។ ទាំងប្រុស ទាំងស្រី មិនប្រកាន់ថា ពណ៌អ្វីឡើយ តែគេត្រូវស្លៀកពាក់អោយត្រឹមត្រូវតាមរបៀបដែលសមជាទីគោរពដល់អ្នកសាមីខ្លួនដើមការ និងភ្ញៀវផងគ្នា÷

ក-បុរស បើរៀបខ្លួនតាមរបៀបខ្មែរ គេស្លៀកសំពត់ពាក់អាវកុត កត្រង់ ស្បែកជើង ស្រោមជើងខ្មៅ ឬពណ៌ផ្សេងៗ។ បើគេពាក់អាវបើកក គេចងក្រវាត់ទៀតទើបសមរម្យ។ តែបើគេពាក់អាវបើកកចងក្រវាត់ ជើងទទេក៏ឈ្លើយណាស់ដែរ។ គេត្រូវអោយមានគ្រប់ប្រដាប់ទើបល្អមើលមិនទើសភ្នែកអ្នកទាំងពួង។

ខ-តាមរបៀបអឺរ៉ុប គេស្លៀកខោជើងវែង អាវបិទក ស្បែកជើង ស្រោមជើង ខោជើងវែង អាវបើកក ចងក្រវាត់ក៏បាន តែបើពាក់អាវបើកក ដោយមិនចងក្រវាត់ជាការមិនល្អមើលដែរ។ បើស្លៀកខោជើងវែង ហើយពាក់តែអាវទ្រនាប់ មិនពាក់អាវក្រៅ (Chemise) "តឺនុយដឺស្វារ៉េ" (Tenue de soirée) ទោះចងក្រវាត់ក្តី មិនចងក្រវាត់ក្តី នឹងបានឈ្មោះថា មិនចុះរបៀប មិនមានការគោរពដល់គ្នា និងគ្នា។

គ-អ្នកដែលស្គាល់របៀប គេមិនដែលរៀបខ្លួនអោយខាស់ទេ ខ្លះគេស្លៀកពាក់តាមសំលៀកបំពាក់ធំផងដែលហៅថា "តឺនុយដឺស្វារ៉េ" គឺខោសាក្លាតខ្មៅ អាវបើកកសសីមិដៃវែង ណឺដខ្មៅ ស្បែកជើងស្រោមជើងខ្មៅ (នេះសម្រាប់លៀងធំ)។

**សូមចាំថា:**

គ១-ស្បែកជើងសង្រែក មិនគប្បីប្រើប្រាស់ក្នុងឱកាសតែងខ្លួនទៅទទួលលៀងភោជនាហារនានាសោះ ឡើយ ត្រូវពាក់ស្បែកជើងដែលឃ្ពុបបាត់ជើង ស្បែកខ្មៅភ្លឺរលើប ជាស្បែកជើងបែបសំខាន់ណាស់សម្រាប់ពាក់ក្នុងពេលដែលរៀបខ្លួនតាមរបៀបសំលៀកបំពាក់ "តឺនុយដឺស្វារ៉េ" (tenue de soirée) ។

គ២-លោកអ្នកមានទុក្ខកំពុងទ្រាំទ្រទុក្ខទាំងនោះដោយមានសំលៀកបំពាក់សសុទ្ធ ឬខ្មៅសុទ្ធ (សម្រាប់ស្រីៗ) រីឯការពាក់បាំនដៃខ្មៅនៅដៃអាវខាងឆ្វេង ឬសំពត់ខ្មៅ១បន្ទះតូច (បានអធិប្បាយក្នុងសំលៀកបំពាក់កាន់ទុក្ខ) នៅផ្ចិតព្រលាត់អាវបើកក (សំរាប់ប្រុស) ជាសំគាល់ថា ខ្លួនអ្នកមានទុក្ខនោះមិនត្រូវអញ្ជើញទៅក្នុងមង្គលការអាពាហ៍ពិពាហ៍ទេ។ បើថាត្រូវទៅខានមិនបាន ត្រូវចេញពីត្រណមកាន់ទុក្ខសិនទើបជាការគួរ។ បើយើងមិនទាន់ចេញពីកាន់ទុក្ខទេ ត្រូវយើងឆ្លើយជាលាយលក្ខណ៍អក្សរទៅវិញតបនឹងសេចក្ដីអញ្ជើញគេថា "យើងនៅក្នុងកំឡុងកាន់ទុក្ខទៅពុំបានទេ" ។

មិនតែឱកាសមង្គលការទេ សូម្បីតែគេអញ្ជើញលៀងកំសាន្តសប្បាយ លោក-អ្នកកាន់ទុក្ខ ក៏ពុំគួរអញ្ជើញទៅដែរ ព្រោះយើងនឹងស្ដាប់ភ្លេង ភ្លេង មើលល្ខោន ឬច្រៀងរាំដោយខ្លួនឯងក្ដី សញ្ញាដែលសំគាល់ទុក្ខនោះ ត្រឡប់ទៅជាក្លែងទៅវិញ។

## ៥. សំលៀកបំពាក់ធ្វើការងារ

ពេលដែលទៅបំពេញកិច្ចការរាជការនៅមន្ទីរស្ដីការនានានោះ មន្ត្រីរាជការតូច-ធំទាំងឡាយ គប្បីស្លៀកពាក់អោយសមរម្យ ដើម្បីអោយប្រជារាស្ត្រស្គាល់បានថា ជាមន្ត្រីដោយឫកពារ និងដោយសំលៀកបំពាក់ដ៏ស្អាតបាត ត្រឹមត្រូវ។ នៅក្នុងមន្ទីរស្ដីការនីមួយៗ អស់លោកស្លៀកពាក់មានរបៀបរៀបរយល្អ នោះជនដទៃដែលគេចូលទៅ គេរមែងមានសេចក្ដីកោតញញើតដោយឃើញរបៀបរៀបចំទីកន្លែងធ្វើការ និងរបៀបរៀបចំខ្លួនប្រាណសមរម្យល្អ។ បើយើងមានការចង់ទៅជួបនឹងលោកណាមួយដែលមានយសសក្តិខ្ពស់ជាងយើងនោះ យើងគប្បីរៀបចំសំលៀកបំពាក់អោយបានសមរម្យ គឺថាបើតែងខ្លួនជាខ្មែរក្ដី ជាបារាំងក្ដី ក៏ត្រូវអោយមានសណ្ដាប់ធ្នាប់ជារាប។

ឧបមាថា: យើងចង់ទៅជួបលោករដ្ឋមន្ត្រី ឬចៅហ្វាយខេត្ត ឬចាងហ្វាងសាលា ឬនាយកក្រុមណាមួយ ។ល។ ដោយមានការរាជការ ឬការផ្ទាល់ខ្លួននោះ ត្រូវស្លៀកពាក់អោយត្រឹមត្រូវ។ ចំណែកលោកជាធំវិញ យើងមិនត្រូវរិះគន់លោកទេ ក្នុងពេលដែលលោកឈប់សម្រាកនៅផ្ទះ ព្រោះលោកពុំអាចប្រាប់ជាមុនថា យើងនឹងទៅជួបលោក។ ចុះបើក្នុងពេលធ្វើការវិញ លោកក៏គង់រៀបចំខ្លួនប្រាណអោយបានត្រឹមត្រូវរាល់ពេលវេលាដែរ ដោយលោកមានការប្រុងប្រយ័ត្នក្រែងមានភ្ញៀវពន្នីចូលមកជួប។

## ៦. សំលៀកបំពាក់ដើរកំសាន្ត

ដែលហៅថាការដើរកំសាន្ត គឺយើងដើរលំហើយខ្លួន ដើរយកខ្យល់អាកាសតាមមាត់ទន្លេ មាត់ស្ទឹង មាត់បឹង មាត់ព្រៃក សួនផ្កា ឬទីវាលឯណាមួយ ។ល។ ក្រោយពេលដែលយើងធ្វើការហត់នឿយព្រួយចិត្ត ព្រួយគំនិត ដោយហេតុផ្សេងៗ។ យើងដើរទៅលេងទីនោះ ឬអង្គុយសម្រាកកំលាំង ឬឈរមើលទឹក និងព្រៃព្រឹក្សាបុប្ផ លតាវល្លិ៍ ដែលប្រកបដោយពណ៌ល្អមើល ទាំងមានក្លិនពិដោរក្រអូបឈ្ងុយឈ្ងប់។ វត្ថុទាំងនេះ ជាគ្រឿងលំហែចិត្តសម្រាប់បំភ្លេចទុក្ខ បំភ្លេចសេចក្ដីនឿយ ព្រួយ បំភ្លេចការកង្វល់ទាំងឡាយទាំងពួងបានមួយគ្រាៗ។

មិនតែប៉ុណ្ណោះទេ អ្នកដែលមានជម្ងឺឈឺស្កាំងស្គមដូចជាអ្នកឈឺសួតជាដើម ក៏ត្រូវដើរទៅផ្លាស់ខ្យល់អាកាសម្តងៗដែរ តាមតម្រាវេជ្ជសាស្ត្រដែលលោកបានកិតទុកមក។

តទៅទៀត នៅបន្ទាប់ពីការនឿយហត់ បន្ទាប់ពីពេលដើរលេងសម្រាកកាយ កំលាំងកាយ និងគំនិតមានការចង់បរិភោគចំណីដំមានឱជារសឆ្ងាញ់ពិសា និងបានចំរើនកំលាំងប្រកបការតទៅនោះ យើងត្រូវស្វែងរកភោជនាគារ (ផ្ទះលក់បាយ) ណាដែលមានឈ្មោះល្បីខាងធ្វើម្ហូបចំណីគ្រប់ថែម។

ដំណើរកំសាន្តរបស់យើងទាំងនេះ ក៏ជាការសម្តែងឬកពារចំពោះមុខមហាជនទាំងឡាយទាំងពួង។ អ្នកទាំងពួងក៏មានការដើរលេងដូចៗគ្នាក្នុងពេលត្រូវគ្នា។ ដូច្នេះ យើងទាំងអស់គ្នា គប្បីស្លៀកពាក់អោយសមរម្យ អោយជាទីគោរពដល់គ្នានឹងគ្នាទៅវិញទៅមក ព្រោះបើស្លៀកពាក់មិនសមរម្យនឹងរាប់ថា ជាសុភាពរៀបរយក៏ពុំបានទាំងអោយរំខានដល់មិត្តភក្តិដែលជួបប្រទះគ្នានៅទីនោះៗផង។ ឧបមាដូចមានមិត្តពីរនាក់កំពុងសន្ទនាគ្នានៅក្នុងសួនមួយកន្លែង អ្នកទាំងនោះស្លៀកពាក់ចុះបែបផែន តាមអារ្យធម៌សម័យនិយម សមរម្យជាអ្នកមានឬកពារសុភាពខ្ពង់ខ្ពស់ ហើយមានម្នាក់ទៀតដើរមកទីនោះដែរ តែស្លៀកសារុង ពាក់អាវកាក់ បង់ក្រមាតភ្ជក់ មកឈប់ឈរនិយាយផង យ៉ាងនេះឃើញថា មិនសមរម្យ មិនល្អមើលដល់ភ្នែកអ្នកដទៃដែលគេមករកកន្លែង អាស្រ័យសម្រាកសម្រាន្តកំសាន្តចិត្តដូចយើងដែរ។

នេះហើយឃើញថា ក្នុងពេលដើរកំសាន្តសប្បាយ ក៏ត្រូវស្លៀកពាក់អោយត្រឹមត្រូវទើបមិនទើសភ្នែកគេឯងទាំងជនអារ្យប្រទេស ក៏គេមានពាក្យសរសើរដល់ជាតិដល់ប្រទេសយើងពុំខាន។ បើពុំធ្វើដូច្នោះទេ នឹងមានពាក្យគេរិះគន់ថា ប្រទេសយើងនេះមានពលរដ្ឋល្ងង់ខ្លៅច្រើនណាស់តាំងតែអំពីសំលៀកបំពាក់ឡើងទៅ។

ប្រមូលសេចក្តីទៅឃើញថា សំលៀកបំពាក់ដើរលេង ដើរមើលបុណ្យផ្សេងៗ ប្រុសក្តីស្រីក្តី គប្បីតែងខ្លួនអោយល្អមើល អោយត្រូវភ្នែកអ្នកទាំងពួងផង គឺថាបើប្រសិនជាយើងរៀបខ្លួនតាមជនអារ្យប្រទេសនោះ ឃើញថារុងរឿងល្អក្នុងប្រទេសយើង។ ប្រុសស្លៀកខោជើងវែង ស្បែកជើង ស្រោមជើង ពាក់អាវសឺមីដៃវែង ឬដៃខ្លី ចងក្រវាត់ ឬគ្មានក្រវាត់ក៏បាន ឬពាក់អាវបោកបៅ៤ដៃខ្លីក៏បាន។ ស្ត្រីក៏តែងខ្លួនតាមសម័យថ្មីមានពាក់អាវបែបចំនើបប្លែកគ្នាតាមរចនា។ សូម្បីតែកូនចៅតូចៗដែលទើបនឹងចេះដើរ ចេះរត់ក៏ត្រូវតែរៀបចំខ្លួនប្រាណគេអោយសមតាមសម័យអោយបានស្អាតបាតដែរ។

ដូចជាដើរមើលបុណ្យផ្សេងៗមានបុណ្យតាំងតុ ឬអុំទូកជាដើមនោះ គួរតែងខ្លួនអោយល្អបន្តិចឡើងទៀត គឺល្អដោយសាច់សំពត់ និងពណ៌សំពត់ដែលយកមកកាត់អាវ។

(នៅមានត)

ដកស្រង់ដោយលោកស្រី លឹម ច័ន្ទសារ

គតិការបឋមសិក្សា



ដកស្រង់ចេញពីសៀវភៅ "ទំនៀមទំលាប់ និងប្រពៃណីខ្មែរ" របស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ [illegible] ឆ្នាំ១៩៥៨

# សម្បត្តិវប្បធម៌លទ្ធកម្ម(១) និងសម្បត្តិវប្បធម៌ធម្មជាតិរបស់ខ្មែរ

ប្រទេសទាំងឡាយដែលគេទទួលស្គាល់ថា មានវប្បធម៌ និងអរិយធម៌រុងរឿងដោយសារតែសម្បត្តិវប្បធម៌របស់ខ្លួន យ៉ាងណាមិញប្រទេសខ្មែរដែលសំបូរដោយសម្បត្តិវប្បធម៌ជាកេរដំណែល និងមតិករបស់បុព្វបុរស ជាភស្តុតាងនៃដួងព្រលឹងជាតិ ទោះបីជាសម្បត្តិវប្បធម៌លទ្ធកម្មក្តី សម្បត្តិវប្បធម៌ធម្មជាតិក្តី។ តើសម្បត្តិវប្បធម៌ទាំងពីរយ៉ាងនេះ អាចបណ្តុះបណ្តាលគំនិតជាតិនិយម ឬគំនិតមាតុភូមិនិយមដែរឬទេ?

**អ្វីខ្លះដែលជាសម្បត្តិលទ្ធកម្មរបស់ខ្មែរ?**

សម្បត្តិវប្បធម៌សំគាល់នូវភោគទ្រព្យទាំងឡាយសំរាប់បណ្តុះចំណេះដឹង បណ្តុះគំនិតពិចារណា បណ្តុះទឹកចិត្តស្រឡាញ់រាប់អានដែលយើងចង់បាន និងចង់រក្សាទុកអោយបានប្រពៃ ពោលគឺជាឃ្លាំងនៃពុទ្ធិ។ សម្បត្តិវប្បធម៌លទ្ធកម្មសំគាល់នូវភោគទ្រព្យទាំងឡាយដែលជនជាតិណាមួយបានបង្កើតឡើង កសាងឡើង បណ្តុះបណ្តាលឡើងជាសមិទ្ធផលសំរាប់ជាមតិកដល់កូនចៅជំនាន់ក្រោយ។ តើខ្មែរមានសម្បត្តិលទ្ធកម្មអ្វីខ្លះ? យើងអាចស្រាវជ្រាវរកសម្បត្តិវប្បធម៌លទ្ធកម្មរបស់ខ្មែរតាមវិស័យនីមួយៗដូចជា វិស័យអក្សរសាស្ត្រ វិស័យវិទ្យាសាស្ត្រ វិស័យតិចនិចវិស័យជំនឿ វិស័យសិល្បៈ និងវិស័យស្ថាបត្យកម្ម។

ក្នុងវិស័យអក្សរសាស្ត្រ ខ្មែរមានសំណេរយ៉ាងច្រើនដែលសរសេរលើស្បែកសត្វ លើបន្ទះក្តារ លើផ្ទាំងថ្មដែលគេហៅថា សិលាចារឹក ដូចជាសិលាចារឹកលើភ្នំដា ស្តុកកក់ធំ វ៉ាតញ៉ូ ប្រាសាទប្រាំល្វែង និងសិលាចារឹកនៅប្រាសាទដទៃទៀតយ៉ាងច្រើនរាប់ក្នុងចំណោមរចនាបថទាំង១២ដូចជា រចនាបថសំបូរ ព្រៃក្មេង កំពង់ព្រះ គូលែនព្រះគោ បាខែង កោះកេរ បន្ទាយស្រី ឃ្លាំងបាពួន អង្គរធំ បាយ័ន...។ ខ្មែរមានសំណេរលើសាស្ត្រាស្លឹករឹតដែលមានគង់លំទុកនៅវត្តអារាមរហូតដល់សព្វថ្ងៃ ព្រមទាំងសំណេរលើក្រដាសដូចមានបោះពុម្ពសព្វថ្ងៃនេះ។ ទាំងអស់នេះគឺជាសម្បត្តិវប្បធម៌ផ្នែកអក្សរសាស្ត្ររបស់ខ្មែរដែលមានតាំងពីបុរាណកាលរហូតមកដល់សព្វថ្ងៃ ជាកេរដំណែលដ៏មានតំលៃបំផុតសំរាប់ជនជាតិខ្មែរ។

ក្នុងវិស័យវិទ្យាសាស្ត្រ គេបានកត់សំគាល់ឃើញថា ខ្មែរចេះគន់គូរដំណើរគោចរព្រះអាទិត្យ ព្រះច័ន្ទតាមរនោច តាមខ្នើត ដើម្បីកំណត់សូរ្យគ្រាស និងច័ន្ទគ្រាស គ្រាន់តែវិធីពន្យល់លេខប្លែកពីអឺរ៉ុបបន្តិច។

ក្នុងវិស័យតិចនិចវិញ ខ្មែរចេះធ្វើសិប្បកម្មដូចជាធ្វើកញ្ច្រែង គ្រក បង្គី ល្អាង ល្អី ធ្នូ ស្នា ចង្អេរ ត្បាល់កិនស្រូវ ក្អម ឆ្នាំង...។

ក្នុងវិស័យជំនឿ ខ្មែរជឿហោរា ជឿធម្មជាតិ ជឿគុណម្តាយឪពុក ជឿខ្មោចព្រាយ ជឿអ្នកតា និងជឿអាទិទេពផងដែរ ព្រមទាំងជឿថាមនុស្សស្លាប់ទៅកើតវិញ។

(១) សម្បត្តិវប្បធម៌ដែលបានសាងហើយ

ក្នុងវិស័យសិល្បៈ ខ្មែរមានភ្លេង របាំ ចំរៀង ល្ខោន និងគ្រឿងភ្លេងយ៉ាងច្រើន។ ខ្មែរមានភ្លេងប្រជាប្រិយ ភ្លេងការ ភ្លេងមហោរី ភ្លេងខ្មែរ...។ ខ្មែរមានរបាំត្រុដិ របាំទន្សោង របាំមេអំបៅ របាំអាយ៉ៃ របាំរាំវង់ របាំរាំក្បាច់ របាំ ត្រុត របាំកាប់ក្របីផឹកស្រា របាំយីកេ... ដែលគេប្រទះឃើញរហូតមកដល់សព្វថ្ងៃនេះ។ ខ្មែរមានចំរៀងចាប៉ី សំរាប់និទានរឿង ចំរៀងប្រប់កែសំរាប់ឆ្លើយឆ្លងគ្នា ចំរៀងបំពេរ ចំរៀងលួងលោម ចំរៀងស្នេហា...។ ខ្មែរមានល្ខោនខោល ល្ខោនត្រាប់ ល្ខោននិយាយ ល្ខោនបាសាក់ដែលមានជីវិតរហូតមកដល់សព្វថ្ងៃជាតំណាងអោយវប្បធម៌ និងអរិយធម៌ខ្មែរ។ ខ្មែរមានគ្រឿងភ្លេងច្រើនទៀតដូចជា រនាតឯក រនាតដែក រនាតធុង ទ្រខ្មែរ ទ្រសោ ទ្រអ៊ូ ទ្រឆេ តាខេ ខ្លុយ ឃឹម ស្គរ សំភោ ប៉ីកែវ ប៉ីបបុស ប៉ីអ ប៉ីពក ស្រឡៃ គងតូច គងធំ ចាប៉ី ឆៃយ៉ាំ ក្រាប់ សាដៀវ... ដែលមានរូបរាងរហូតមកដល់សព្វថ្ងៃ ហើយជាសម្បត្តិវប្បធម៌ពិសេសសំរាប់បញ្ជាក់នូវលក្ខណៈភ្លេងខ្មែរ។

ខ្មែរមានល្បែងប្រជាប្រិយជាច្រើនដូចជា ប្រណាំងទូក ប្រណាំងសេះ ប្រណាំងរទេះគោ ប្រជល់មាន់ ប្រជល់ដំរី ប្រជល់ជ្រូក ប្រជល់គោ ប្រជល់ត្រី បោះអង្គុញ ចោលឈូង លាក់កន្សែង ចិញ្ចពួន ស្តេចចង់ អ៊ុ ចោលឈូង វាយឆ្នាំង ទាញព្រ័ត្រ ហ៊ីង... ដែលមានជីវិតរហូតមកដល់សព្វថ្ងៃនេះ ប៉ុន្តែមានល្បែងខ្លះហាក់ដូចជាបាត់បង់ខ្លះដែរ ពីព្រោះយើងលែងនឹកនា។

(នៅមានត)

លោក ឆេង ឡឿន
ប្រធានការិ.អប់រំ និងគ្រប់គ្រង
នៃវិទ្យាស្ថានជាតិអប់រំ

## សំណួរល្បងប្រាជ្ញា

ផ្លែអំពិលខ្ចីមានរសជាតិ - ជូរ

ផ្លែល្ហុតខ្ចីមានរសជាតិ - ចត់

បើយើងយកអំពិលខ្ចី និងល្ហុតខ្ចីទំហំប៉ុនគ្នាទៅបរិភោគជាមួយគ្នា តើល្បាយនោះ មានរសជាតិដូចម្តេច?

(ចំលើយនៅទំព័រទី១៦)

ឆាត់ សំ

# ឧទាហរណ៍សំរាប់បំភ្លឺការប្រើប្រាសាទមួយ(*)

ប្រាសាទតាព្រហ្ម និងបន្ទាយឆ្មារ យើងដឹងថា ជាប្រាសាទដែលកសាងដើម្បីជាជ័យមង្គលដល់ព្រះរាជវង្ស យ៉ាងជិតរបស់ស្ដេច ។

ប្រាសាទបន្ទាយឆ្មារ សាងដើម្បីការគោរពដល់ព្រះរាជបុត្រ ១អង្គទ្រង់ព្រះនាម ស្រីន្ទ្រកុមារ និងប្លា៤នាក់ ដែលជាភឿនចំបាំង ហើយដែលបានជួយជីវិតព្រះកុមារជាច្រើនគ្រា មានចំបាំងនឹងរាហូ និងចំបាំងនឹងពួកចាមជាដើម ។

ប្រាសាទតាព្រហ្មសាងឡើងនៅឆ្នាំ១១៨៦ ដើម្បីឧទ្ទិសដល់ព្រះបរមរូបព្រះវររាជជននីដែលតាំងលើកឡើងជាព្រះប្រាជ្ញាបារមីតា ព្រមទាំងព្រះរូបសម្ដេចព្រះគ្រូ និងព្រះរូប២៦០ទៀត ។

សិលាចារឹកដ៏ដែលនៅនឹងកន្លែងដដែលនៅឡើយ ហើយដែលខ្ញុំបានប្រែចេញកាលពីឆ្នាំ ១៩០៦ នោះ ធ្វើអោយយើងដឹងច្បាស់នូវមនុស្សដែលធ្វើរាជការក្នុងប្រាសាទនោះ ទាំងគ្រឿងប្រដាប់សំរាប់ប្រាសាទនោះនិងស្បៀងអាហារដែលមានប្រយោជន៍ដល់ការបូជា ។ យើងបានដឹងថា ប្រាសាទនោះមានភូមិចំណុះ៣ ១៤០ភូមិហើយមនុស្សដែលធ្វើការថែរក្សាប្រាសាទនេះចំនួន ៧៩ ៣៦៥នាក់ មនុស្ស ១២ ៦៤០នាក់ នៅខាងក្នុងកំពែង ។ ក្នុងមនុស្សទាំងប៉ុន្មាននេះ មានអធិការ៨រូប មានមេគណ ២ ៧៤០ មានអ្នកគាល់បំរើ ២ ២០២នាក់ មានស្រ្ដីរបាំ ៦១៥នាក់ ។ គ្រឿងប្រដាប់សំរាប់ប្រាសាទនោះគឺ មានចានជាមមាស១ ទំងន់ជាង ៥ ០០០គីឡូក្រាម បើតាមថ្លៃសព្វថ្ងៃ ១០០ លានហ្វ្រង់ (គឺ១០លានរៀល) ចំណែកចានជាមប្រាក់ក៏មានទំងន់ប្រហែលគ្នាដែរ ពេជ្រទាំងគ្រាប់ធំ ៣៥គ្រាប់ កែវមុក្ដា ៤០ ៦២០គ្រាប់ ត្បូងយ៉ាងល្អ ៤ ៥៤០គ្រាប់ ឆ្កិលមាសយ៉ាងធំ១ វាំងស្រុកចិន ៥៦៧ ដែរធ្វើដោយព្រៃ ៥១២ ក្បោះ ៥២៣ ។ រួចពីនេះ របៀបរាប់ស្បៀងអាហារគ្រប់យ៉ាង គឺអង្ករ ប៊ឺរ ទឹកដោះគោ កករស្ករ ប្រេង គ្រាប់ផ្សេងៗដែលសំរាប់ប្រើក្នុងការបូជារាល់ថ្ងៃ ហើយចំនួនដែលត្រូវចាយសំរាប់ថ្ងៃបុណ្យ និងបញ្ជីវត្ថុដែលត្រូវឃ្លាំងជំបើកអោយរាល់ឆ្នាំ គឺគ្រាប់ផ្សេងៗ ប៊ឺរ ទឹកដោះគោ ទឹកឃ្មុំ ប្រេង ក្រមួន ខ្លឹមចន្ទន៍ កបូរ គ្រឿងចីវរ ២ ៣៨៧ គូ សំរាប់ទ្រង់ថ្វាយព្រះរូបទាំងអស់ ។

សិលាចារឹកនោះបញ្ចប់សេចក្ដីថាម្ល៉េះ ដែលធ្វើនូវបុណ្យកិរិយាវត្ថុទាំងប៉ុន្មាននេះ មហាក្សត្រដោយមានសេចក្ដីគោរពបំផុតជាចំពោះព្រះវររាជមាតាបានទ្រង់ឧទ្ទិសដូច្នេះ ដោយអំណាចអានុភាពរបស់ការដ៏ប្រសើរដែលខ្ញុំបានធ្វើនេះ សូមអោយព្រះវររាជមាតាខ្ញុំ នៅវេលាដែលទ្រង់រួចផុតពីសមុទ្រសាគរ ពោលគឺសង្សារវដ្ដហើយ បានសំរេចនូវភាវៈជាព្រះពុទ្ធ ។...

***Georges Coedès***

---

(*)ដកស្រង់ពីក្នុងសៀវភៅ "UN GRAND ROI DU CAMBODGE JAYAVARMAN VII" (ស្ដេចមហាក្សត្រមួយអង្គក្នុងប្រទេសកម្ពុជា ជ័យវរ្ម័នទី៧) ដែលបកប្រែដោយព្រមការ ជុំ ម៉ៅ ការផ្សាយរបស់ព្រះរាជបណ្ណាល័យ ព.ស ២៤៧៨ គ.ស១៩៣៥



# វិធីថ្មីដើម្បីអប់រំសិស្សខូច

នៅទីណា ក៏ដូចជាទីណាដែរ បើនិយាយពីសាលារៀន តែងតែមានសិស្សខូចដែលបង្កបញ្ហាលំបាកដល់សាលា និងមិត្តភក្តិរបស់គេ។ បើយើងបណ្តោយបញ្ហានេះអោយកើតឡើង វានឹងក្លាយជាបន្ទុកមួយសំរាប់សង្គមនាពេលអនាគត ដោយសារសិស្សគ្មានការអប់រំ។ ដូច្នេះ យើងមិនអាចបោះបង់ចោលសិស្សខូចណាមួយ ឬប្រើវិធីក្តៅណាមួយ ដើម្បីអប់រំគេដែរ។ ការសហការរវាងអាណាព្យាបាលរបស់សិស្ស និងគ្រូបង្រៀន គឺជាដំណើរការមួយដោយមិនអាចខ្វះខាងណាមួយបានឡើយ។ យើងលើកយកបទពិសោធន៍ពីរ ជាគតិសំរាប់ពិចារណា :

## បទពិសោធន៍មួយនៅសហរដ្ឋអាមេរិក

**ថម**(Tom)អាយុ១៥ឆ្នាំ ជាសិស្សអនុវិទ្យាល័យមួយនៅរដ្ឋអូហៃអូ(Ohio)។ វាជាសិស្សខូច មានឥរិយាបថពុំគប្បីនៅក្នុងសាលា វាជជែកគ្នាក្នុងថ្នាក់ មករៀនយឺត និងមិនចេះប្រើពាក្យគួរសមជាដើម ហើយវាត្រូវបានបញ្ជូនទៅការិយាល័យនាយក។ លោក **ចន ឡាស៊ែ** (John Lazares) ជានាយកសាលារបស់ថម ជាដំបូងគាត់ដាក់ពិន័យថម អោយវាបន្ថែមម៉ោងមួយម៉ោងនៅថ្ងៃបន្ទាប់ និងព្យាយាមនិយាយជាមួយសិស្សនេះ ប៉ុន្តែ ថម មិនយកចិត្តទុកដាក់ស្តាប់ទេ។ លោក ចន គិតថា ក្មេងនេះមិនយូរទេនឹងត្រលប់មកកាន់ការិយាល័យរបស់គាត់វិញ គាត់ប្រាប់ថា បើសិនជាគ្រូរបស់ប្អូនបញ្ជូនប្អូនមកម្តងទៀត ខ្ញុំនឹងផ្ញើសំបុត្រ ឬទូរស័ព្ទហៅឪពុក ឬម្តាយរបស់ប្អូនអោយមកសាលានេះ ហើយប្រាប់ថា "កូនរបស់អ្នកមានបញ្ហាជាមួយនឹងគ្រូ សូមមកកាន់សាលា ខ្ញុំចង់អោយអ្នកចូលថ្នាក់ជាមួយកូនរបស់អ្នក"។ ភ្លាមនោះ ថម ងើបឡើងហើយនិយាយថា "អូហ៎! ទេ កុំហៅគាត់មក ខ្ញុំមិនចង់អោយគាត់មកសាលាទេ ខ្ញុំសន្យានឹងកែខ្លួនទៅជាសិស្សល្អ"។ លោក ចន បានពិចារណាសំដីរបស់ថម "ខ្ញុំមិនចង់អោយ គាត់(ឪពុកឬម្តាយ)មកសាលាទេ" ហើយគាត់គិតថា "ប្រហែលជាអាចមានវិធីថ្មី ដើម្បីដាក់ពិន័យសិស្សតាមវិធីត្រជាក់តែមានប្រសិទ្ធភាពជារៀងរហូត"។ នៅសហរដ្ឋអាមេរិក នាយកសាលា ឬគ្រូបង្រៀនមានវិធីជាច្រើនដើម្បីដាក់ពិន័យសិស្សខូច។ មជ្ឈដ្ឋានអាណាព្យាបាល ត្រូវតែយកចិត្តទុកដាក់ និងធ្វើទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយសាលារៀន ព្រោះថាគ្រូតែងតែសរសេរសំបុត្រ ឬទូរស័ព្ទហៅអាណាព្យាបាល បើអាណាព្យាបាលមិនមកទេ ក្នុងករណីធ្ងន់

ធ្វើ នាយកសាលាមានសិទ្ធិព្យួរការសិក្សា ឬអាចបញ្ឈប់មិនអោយមករៀន ពីរឬបីថ្ងៃជាបណ្តោះអាសន្ន ឬអាចមួយសប្តាហ៍ក៏មាន។ បើសិនជាករណីធម្មតា ត្រូវដាក់ពិន័យអោយបន្ថែមម៉ោង មិនអោយចេញ។ ដូច្នេះ នៅ សហរដ្ឋអាមេរិកត្រូវតែបង្ខំអាណាព្យាបាលអោយសហការជាមួយសាលាជានិច្ច។ ចំពោះលោក ចន វិញ មិនចង់បញ្ឈប់សិស្សទេ ព្រោះសិស្សមួយចំនួនសប្បាយចិត្តទៅវិញ ដោយគេយល់ថា ការបញ្ឈប់នេះជាវិស្សមកាលរបស់ពួកគេ។ ពីរបីថ្ងៃក្រោយមក មានសិស្សម្នាក់ទៀតមកកាន់ការិយាល័យរបស់គាត់ សិស្សនោះប្រព្រឹត្តមិនគប្បីក្នុងថ្នាក់ គាត់បានផ្ញើសំបុត្រទៅអោយឪពុកម្តាយក្មេងនោះ "បើសិនជាលោកមកសាលា ខ្ញុំនឹងមិនបញ្ឈប់កូនលោកទេ"។ ឪពុកក្មេងនោះក៏បានមកសាលា និងចូលបន្ទប់រៀនមួយចំនួនជាមួយកូនគាត់តាមការណែនាំរបស់នាយក។ សិស្សដទៃទៀតបានសំលឹងមើលសិស្សនោះ និងឪពុករបស់គេ ក្មេងនោះមានការអាម៉ាស់យ៉ាងខ្លាំង ហើយបានកែខ្លួនជាសិស្សល្អវិញ ដោយគេមិនចង់អោយឪពុករបស់ខ្លួនមកសាលាជាថ្មីទៀត ហើយសិស្សផ្សេងទៀតក៏កែខ្លួនដែរ ព្រោះគេមិនចង់អោយឪពុកម្តាយរបស់គេមករៀនជាមួយឡើយ។ ក្នុងឆ្នាំនោះមានឪពុកម្តាយ៦០នាក់មកសាលាជាមួយកូនដែលខិលខូច។ ឆ្នាំបន្ទាប់ មានឪពុកម្តាយតែពីរបីនាក់ប៉ុណ្ណោះ ដែលត្រូវមកសាលាជាមួយកូន។ នាយកសាលាដទៃទៀត បានឮអំពីវិធីថ្មីនេះរបស់លោក ចន ក្នុងការដាក់ពិន័យសិស្សខូច។ នាពេលបច្ចុប្បន្នកម្មវិធីនេះត្រូវបានប្រើជាង ៧០០សាលាហើយនៅសហរដ្ឋអាមេរិក។ នៅពេលកម្មវិធីនេះបានដាក់ណែនាំបង្ហាញនៅទីក្រុងភីតសបឺហ្គ (Pittsburg) រដ្ឋកាលីហ្វញី (California) សិស្ស៥០នាក់ត្រូវនាំឪពុកម្តាយមកជាមួយ។ ក្នុងចំណោមសិស្សទាំងនោះ មាន៤៨នាក់បានកែប្រែ លែងមានបង្កបញ្ហាដល់សាលា និងថ្នាក់រៀនទៀត។

## បទពិសោធន៍មួយនៅកម្ពុជា

នេះគ្រាន់តែជាបទពិសោធន៍ដោយមិនបានបង្ហាញនូវទិន្នន័យច្បាស់លាស់គឺ គ្រាន់តែថា យើងបានចូលរួមតាមដានសកម្មភាពសិស្សខូចទាំងនោះ ដោយប្រើវិធីដូចតទៅ:

១-បង្កភាពស្និទ្ធស្នាល : ត្រូវបង្កភាពស្និទ្ធស្នាល តែម៉ឺងម៉ាត់ជាមួយគេ ផ្តល់នូវការរាប់អានមួយដែលមិនធ្លាប់មានសំរាប់គេដោយហេតុថា មិត្តភក្តិដទៃ ឬមនុស្សក្នុងសង្គមមិនទទួលយកគេឡើយ។

២-ព្យាយាមសួរនាំ : ព្យាយាមសួរនាំគេពេលបង្រៀន ឬបញ្ហាផ្សេងៗរបស់គេ និយាយបង្កប់ន័យ តែមិនប្រដៅចំៗពេក។

៣-មិនដាក់ពិន័យ : បើគេខុស ព្យាយាមលើកទឹកចិត្ត មិនដាក់ពិន័យ ឬខឹងផង ព្រោះថាឈាមជ័រយុវជនពោរពេញដោយថាមពល មិនចង់ចាញ់នរណាឡើយ។

៤-ព្យាយាមស្គាល់ចិត្តគេ : ព្យាយាមស្គាល់ចិត្តគេ តែមិនត្រូវអោយគេស្គាល់ចិត្តគ្រូវិញ ជៀសវាងការវាយស្មើរវាងសិស្ស និងគ្រូ ហើយតំរូវទៅតាមចិត្តគេខ្លះ។

៥-មិនលំអៀង : ត្រូវបង្ហាញទឹកចិត្តជាកណ្តាល ដោយមិនលំអៀងទៅរកគេពេក ឬលំអៀងទៅរកសិស្សល្អពេក។

៦-ផ្តល់ការលើកទឹកចិត្ត និងទំនុកចិត្ត : ព្យាយាមលើកទឹកចិត្តចំពោះមេរៀនដែលគេរៀន ហើយឧស្សាហ៍លើកយកឧទាហរណ៍របស់គេជាញយៗ ដើម្បីអោយគេមានទំនុកចិត្ត និងជឿជាក់លើតំលៃខ្លួនរបស់គេនៅក្នុងសង្គម តែកុំញឹកពេក ព្រោះគេអាចច្រឡំថា ជាពាក្យបញ្ចើចបញ្ចើ ។

ដោយហេតុផលនេះ យើងបានកែប្រែក្មេងដែលខិលខូចមួយចំនួនធំដោយជោគជ័យ ។ ទោះជាដូច្នេះក៏ដោយ នេះគ្រាន់តែជាបទពិសោធន៍ផ្ទាល់ខ្លួនប៉ុណ្ណោះ មិនមែនជាក្បួនខ្នាតយកទៅអនុវត្តន៍គ្រប់កាលៈទេសៈឡើយ ៕

លោក អួន ស៊ីឡុត
វិ.ហ៊ុន សែន បល្ល័ង្ក កំពង់ធំ

## ប្រស្នាល្បងប្រាជ្ញា

មានព្រានព្រៃពីរនាក់ទៅបរបាញ់សត្វក្នុងព្រៃ។ តាំងពីព្រឹកទល់ថ្ងៃត្រង់ ព្រានព្រៃបាញ់បានតែទន្សាយមួយក្បាល។ ពេលថ្ងៃក្តៅខ្លាំងព្រានព្រៃនាំគ្នាឈប់សំរាកនៅក្រោមម្លប់ដើមឈើធំមួយ ហើយរៀបចំចំអិនសាច់ទន្សាយហូប ប៉ុន្តែជាចៃដន្យអាក្រក់ព្រានព្រៃភ្លេចយកដែកកេះមកតាមខ្លួន។ បន្ទាប់មក ព្រានព្រៃក៏នាំគ្នាបន្តដំណើរទៅមុខទៀត ស្រាប់តែឃើញស្រះមានក្រពើធំៗយ៉ាងច្រើន ប៉ុន្តែនៅចំកណ្តាលស្រះមានកូនកោះតូចមួយ ហើយមានភ្លើងកំពុងឆេះគល់ឈើពុកមួយលើកូនកោះនោះផង។ ព្រានព្រៃចង់យកភ្លើងនោះមកចំអិនសាច់ទន្សាយហូប។ សួរថា :

តើព្រានព្រៃយកភ្លើងនោះបានដោយវិធីណា?

(ចំលើយនៅទំព័រទី២៦)

ផាត់ សាំ

"A useless life is an early death..."

**"ជីវិតដែលមិនមានប្រយោជន៍**

**គឺជីវិតដែលស្លាប់មុនដល់ពេលស្លាប់..."**

*Johan Wolfzang Goethe*

(ទស្សនវិទូអាល្លឺម៉ង់ ១៧៤៩-១៨៣២)

# គំរូនៃការសិក្សាមួយ

តើយើងត្រូវធ្វើដូចម្ដេច ដើម្បីសិក្សារៀនសូត្រអំពីអ្វីមួយ?

ដើម្បីសិក្សារៀនសូត្រអំពីអ្វីមួយ យើងត្រូវ :

**១.បានដឹងឮជាមុន/ ណែនាំអោយស្គាល់ជាមុន** : នេះជាចលករ/កំលាំងជំរុញចិត្ត ដើម្បីសិក្សារៀនសូត្រ។ សិស្សត្រូវការដឹងជាមុនអោយបានច្រើនអំពីប្រធានបទនៃមេរៀន ដើម្បីធ្វើអោយពួកគេមានចិត្តចង់សិក្សារៀនសូត្រ។

**២.រៀនដើម្បីចេះដឹង** : នេះជាដំណាក់នៃការសិក្សា។ គឺជាការរៀនសូត្រ ដើម្បីចេះដឹងអំពីអ្វីៗទាំងឡាយ។ សិស្សត្រូវស្ដាប់ មើល សួរសំនួរ កត់ត្រា អាន និងធ្វើលំហាត់។

**៣.សាកល្បង** : ដើម្បីសិក្សារៀនសូត្រអំពីអ្វីមួយ យើងត្រូវធ្វើអ្វីនោះដើម្បីសាកល្បងចំណេះដឹង ឬអនុវត្តសមត្ថភាពជំនាញរបស់យើង។ ប្រសិនបើសិស្សមិន "សាកល្បង" ទេនោះ ពួកគេមិនអាចដឹងថា តើពួកគេចេះ ឬក៏មិនចេះ? ឬអាចធ្វើអ្វីនោះបាន ឬក៏មិនបាន?

**៤.ត្រូវទទួលយកប្រតិសកម្ម ឬពត៌មានត្រឡប់** : អ្វីៗដែលបានសិក្សារៀនសូត្ររួចហើយ ត្រូវមានប្រតិសកម្ម ឬពត៌មានត្រឡប់មកវិញ។ ប្រតិសកម្មប្រាប់សិស្សអោយដឹងអំពីអ្វីដែលពួកគេបានធ្វើ និងកំពុងធ្វើនោះ តើត្រូវ ឬខុស? ប្រតិសកម្ម គប្បីប្រាប់សិស្សអោយដឹងអំពីហេតុផលថា តើហេតុអ្វីបានជាពួកគេធ្វើត្រូវ ឬធ្វើខុស?

**៥.អនុវត្ត** : ដើម្បីប្រាកដថា សិស្សបានសិក្សារៀនសូត្រអ្វីៗ ចេះពិតមែននោះ លុះត្រាតែពួកគេអាចអនុវត្តអ្វីៗដែលបានសិក្សារួចហើយនោះទៅក្នុងស្ថានភាពនៃជីវិតពិតបាន។

* ដំណាក់ទាំងឡាយនៅក្នុងគំរូនៃការសិក្សានេះ មិនមានលក្ខណៈងាយស្រួល ឬជាលំដាប់ឡើយ។ ជារឿយៗ សិស្សត្រូវការធ្វើឡើងវិញនូវដំណាក់ខាងដើមណាមួយ។ ដូចនេះ គំរូនៃការសិក្សាមានលំនាំជាវង់។ ក្រោយពីបានទទួលប្រតិសកម្ម សិស្សអាចធ្វើការសាកល្បងជាថ្មីឡើងវិញ ឬមួយក៏រៀនដើម្បីចេះដឹងអំពីអ្វីៗនោះអោយបានល្អជាងមុនឡើងវិញ។

ឧទាហរណ៍ : អំពីភាពគានតឹងឡើយណាយ។

១-បានដឹងឮ ឬណែនាំអោយស្គាល់ជាមុន : មានអត្ថបទមួយនៅក្នុងកាសែត ទស្សនាវដ្ដី ឬព្រឹត្តិប័ត្រពត៌មានដែលទាក់ទាញចិត្តរបស់យើង។

២-រៀនដើម្បីចេះដឹង : យើងអាន យើងសិក្សាស្រាវជ្រាវអំពីមូលហេតុរបស់ជំងឺគានតឹងឡើយណាយ

អំពីការវិវត្តរបស់វា អំពីផលប៉ះពាល់របស់វា និងអំពីហេតុផលរបស់វានៅក្នុងកន្លែងធ្វើការ ។

៣-សាកល្បង : យើងលើកយកអត្ថបទដែលបានអាននោះទៅពិភាក្សាជាមួយសហការី និងមិត្តភក្តិរបស់យើង ។

៤-ទទួលប្រតិកម្ម : អ្នកខ្លះឯកភាពថា ការយល់ដឹងអំពីភាពតានតឹងឡើយណាយនេះ ជាកត្តាមួយសំខាន់ដែលជួយដល់ការថែរក្សាសុខភាពរបស់យើង ។ អ្នកផ្សេងទៀតមិនឯកភាពជាមួយការបកស្រាយរបស់យើង ។ ដូច្នេះ យើងត្រូវ :

ក-រៀនដើម្បីចេះដឹង ( ជាថ្មីឡើងវិញ)

- យើងអានអត្ថបទស្ដីអំពី Stress ជាថ្មីឡើងវិញ
- យើងអានអត្ថបទផ្សេងៗជាច្រើនទៀត
- យើងអោយអ្នកផ្សេងទៀតជាច្រើននាក់បញ្ចេញទស្សនៈរបស់ពួកគេចំពោះ Stress នេះ ។

ខ-សាកល្បង ( ជាថ្មីឡើងវិញ)

- យើងលើកយកប្រធានបទដដែលនោះទៅពិភាក្សាជាមួយសហការីរបស់យើងជាថ្មីម្ដងទៀត

គ-ទទួលប្រតិសកម្ម ( ជាថ្មីទៀត)

- សហការីរបស់យើងបានជឿជាក់តាមមតិរបស់យើង ។

ឃ-អនុវត្ត

- យើងរៀបចំផែនការ ដើម្បីអនុវត្តការបន្ថយភាពតានតឹងឡើយណាយរបស់បុគ្គលិកទាំងឡាយ ។
- យើងសរសេរអត្ថបទមួយស្ដីអំពី Stress ចុះផ្សាយក្នុងព្រឹត្តិប័ត្រពត៌មានរបស់សាលា ឬស្ថាប័ន ។

**<u>សូមបញ្ជាក់ថា</u> :**

១) ការសិក្សារៀនសូត្រ ដើរតាមលំនាំជារង្វង់ និងជាលំដាប់ ។ សកម្មភាពសិក្សាណាមួយដែលមិនគោរពតាមលំដាប់ទេនោះ គឺពុំទទួលបានលទ្ធផលល្អឡើយ ។

២) ប្រតិសកម្មកើតមានតែនៅក្រោយ ពេលដែលសិស្សបានធ្វើអ្វីមួយនោះរួចហើយ ។

**លោក ម៉េង ស៊ីមហួច**

**អតីតនាយកមជ្ឈមណ្ឌលបច្ចេកទេស**

**និងវិជ្ជាជីវៈព្រះកុសុមៈ (ចូលនិវត្តន៍)**

# ប្រភេទនៃចរិតលក្ខណៈ

## Les types des Caractères

ធម្មតា អ្នកគ្រូ លោកគ្រូ ក៏ដូចជាមាតាបិតាសិស្សតែងបានធ្វើការកត់សំគាល់សិស្សានុសិស្ស បុត្រីបុត្រា របស់ខ្លួន "គ្រូទាយ ម្ដាយថា" ដើម្បីងាយស្រួលវាយតំលៃសកម្មភាពនានារបស់គេ ក៏ដូចជាងាយស្រួលក្នុងការជំរុញ ឬតំរែតំរង់ក្នុងការអប់រំ ។ ក្នុងករណីនេះ ព្រះសមណគោតមក៏បានកត់សំគាល់ឃើញថា បុគ្គលមាន ៣ ប្រភេទ ÷

១- បុគ្គលងាយទទួលយកការអប់រំ : បុគ្គលប្រៀបដូចផ្កាឈូកផុសផុតពីផ្ទៃទឹក ។

២- បុគ្គលមានលទ្ធភាពទទួលយកការអប់រំ : បុគ្គលប្រៀបដូចផ្កាឈូកផុតបានត្រឹមផ្ទៃទឹក ។

៣-បុគ្គលមិនងាយចាប់យកការអប់រំ : បុគ្គលប្រៀបដូចផ្កាឈូកផុសមិនរួចពីផ្ទៃទឹក ។

តើអ្នកគ្រូ លោកគ្រូបានកត់សំគាល់សិស្សានុសិស្សយ៉ាងណាខ្លះដែរ?

ជាទូទៅ បុគ្គលម្នាក់ៗមានកំលាំងកាយ-ចិត្ត (ញាណសក្តិ) បំរុងទុកសំរាប់អភិវឌ្ឍដើម្បីទទួលយកការ អប់រំ គ្រាន់តែមានភាពខុសគ្នាក្នុងការទទួលឥទ្ធិពលសង្គមផ្សេងពីគ្នា ។ អ្នកចិត្តវិទ្យាក៏បានធ្វើការកត់សំគាល់ទៅ តាមសរីរាង្គ ទៅតាមចិត្តវិទ្យាវិភាគ... ហើយបានចាត់ជាថ្នាក់ផ្សេងៗ មានជាអាទិ៍ដូចជា ÷

- លោកក្រេតស្មែរ (Kretschmer) គ្រូពេទ្យផ្លូវចិត្តអាល្លឺម៉ង់ (១៨៨៨-១៩៦៤) ដោយផ្អែកលើសរីរាង្គ បានចែកជា ៣ ប្រភេទ ហើយក្នុងប្រភេទនីមួយៗមានចរិតលក្ខណៈសមស្របរបស់វា ÷
  - បុគ្គលស្គមខ្ពស់ (le leptosome)
  - អត្តពលិក (l'athlétique)
  - បុគ្គលក្រអាញ (le trapu)
- លោកយុង (Jung) គ្រូពេទ្យផ្លូវចិត្តស្វីស (១៨៧៥-១៩៦១) ដោយផ្អែកលើចិត្តវិទ្យាវិភាគ បាន កំណត់បុគ្គលជា ២ ប្រភេទ ÷
  - អត្តវិស័យបុគ្គល (l'introverti) : បុគ្គលអាត្មានិយម ។
  - វត្ថុវិស័យបុគ្គល (l'extraverti) : បុគ្គលដែលឆាប់រំភើបទៅនឹងតថភាពនៃពិភពខាងក្រៅ ។
- លោកហៃម៉ាន់ ((Heymans) គ្រូពេទ្យជនជាតិប៊ែលហ្ស៊ិក (១៨៥២-១៩៦៨) ជ័យលាភីណូបែល ១៩៣៨ បានបង្កើតប្រភេទបុគ្គល ៨ ប្រភេទទៅតាមការកត់សំគាល់ ៣ យ៉ាង ÷
  - ភាពឆាប់រំជួលចិត្ត ឬភាពមិនឆាប់រំជួលចិត្ត (L'émotivité ou la non-émotivité)
  - ភាពសកម្ម ឬភាពអសកម្ម (L'activité ou la non-activité)
  - បឋមភាព ឬទុតិយភាព (la primarité ou la secondarité) ។

ប្រភេទបុគ្គលទាំងនោះរួមមាន ÷

១-បុគ្គលល្ងើយ(l'amorphe) : មិនរំជួលចិត្ត + អសកម្ម + បឋមភាព

២-បុគ្គលស្ពឹក(l'apathique) : មិនរំជួលចិត្ត + អសកម្ម + ទុតិយភាព

៣-បុគ្គលឆាប់ខឹង(le sanguin) : មិនរំជួលចិត្ត + សកម្ម + បឋមភាព

៤-បុគ្គលធ្ងឹង(le flegmatique) : មិនរំជួលចិត្ត + សកម្ម + ទុតិយភាព

៥-បុគ្គលមួម៉ៅ(le nerveux) : រំជួលចិត្ត + អសកម្ម + បឋមភាព

៦-បុគ្គលរំភើប(le sentimental) : រំជួលចិត្ត + អសកម្ម + ទុតិយភាព

៧-បុគ្គលចិត្តស្រាល(le colérique) : រំជួលចិត្ត + សកម្ម + បឋមភាព

៨-បុគ្គលងប់(le passionné) : រំជួលចិត្ត + សកម្ម + ទុតិយភាព

ពាក់ព័ន្ធនឹងចរិតលក្ខណៈខាងលើ ការអប់រំត្រូវតែរៀបចំអោយបានសមស្រប ។ ឧទាហរណ៍សំរាប់បុគ្គលងប់ខ្ញីមសារមេរៀនត្រូវមានលក្ខណៈជាវិជ្ជមាន ហើយបើជាអវិជ្ជមានវិញ ការបង្រៀនល្អ ត្រូវតែផ្សារនឹងការអប់រំល្អ ។

ជារួម អ្នកអប់រំត្រូវតែមានយុទ្ធវិធីច្បាស់លាស់សំរាប់ប្រភេទនៃចរិតលក្ខណៈនីមួយៗ ។ យើងត្រូវជំរុញបុគ្គលល្ងើយអោយមានចិត្តរំភើប សកម្មភាពរហ័សរហួន និងមានការចងចាំ ពោលគឺយើងធ្វើយ៉ាងណាអោយសិស្សានុសិស្សយើងមានលក្ខណៈណាសមស្របដូចជាអ្វីគួរអោយចងចាំ អ្វីគួរអោយឆាប់រំភើបជាដើម ។

ដកស្រង់ប្រែសំរួល : លោកកែតខ យ៉ាវ

---

<u>ចំលើយសំណួរល្បងប្រាជ្ញាទំព័រទី ៨</u>

ចំលើយ - អត់ផ្ទូរ អត់ចត់

ឆាត់ សាំ

---

បឋមភាព ≠ ទុតិយភាព = កង្វះភាពអចិន្ត្រៃយ៍នៃសភាពចិត្ត ≠ អចិន្ត្រៃយ៍ភាពនៃសភាពចិត្ត

Cours de psychologie enfantine et Juvénile-Andre Ferré




# លំដាប់នៃការវិវត្តសរីរាង្គមនុស្ស

## វិវត្តន៍សមាមាត្រសរពាង្គកាយ




ក្នុងចន្លោះ១ឆ្នាំទៅ២២ឆ្នាំសមាមាត្រនៃរាងកាយមនុស្ស (ក្បាល-ដងខ្លួន-អវយវៈ) ប្រែប្រួល។ ក្បាលប្រែប្រួលពី១/៤ទៅប្រមាណ១/៨។ ផ្ទុយទៅវិញ ជើងប្រែប្រួលតិចតួចលើសពី១/៤ទៅ ១/២។

សរីរាង្គកាយមនុស្សយើងត្រូវតែវិវត្តទៅតាមលំដាប់។ ទារកដ៏ល្អមួយរូបមិនមែនមានន័យថា មានរូបរាងសមាមាត្រនោះទេ វាមានជើងខ្លី ដៃតូចល្អិត ក្បាលធំហួសខ្នាត ហើយពោះមូលធំ។ តើហេតុអ្វីយ៉ាងដូចនេះ? អង្គប្រាណដ៏តូចនេះសំរាប់សំរួលដល់ការប្រសូត្រចេញពីគភ៌។

អវៈយវៈទាំងឡាយដែលគ្រប់ពេលវេលាត្រូវតែមានការលូតលាស់នោះ ត្រូវមានសភាពតូចល្អិត។ ចុះក្បាលវិញ? វាមានរាងធំ ព្រោះវាជាមេបញ្ជា វាជាសរីរាង្គដែលអភិវឌ្ឍច្រើនជាងគេ។ តែខួរក្បាលមួយ វាមានទំងន់ ៣០០ក្រាម ប្រមាណជា ១០% នៃម៉ាសរបស់អង្គប្រាណ។ ម្ភៃឆ្នាំក្រោយមក វាកើនដល់ ១,៥គ.ក ប៉ុន្តែវាមានតែ២% នៃម៉ាសរបស់យើង។

ក្នុងចន្លោះពេលនោះ សរីរាង្គដទៃទៀតបានបន្តការលូតលាស់របស់វា ចាប់ពីពេលដែលវាត្រូវបំពេញមុខងាររបស់ខ្លួន។ ការខំបំប៉ោងសួត បញ្ចេញសំរែកដំបូងបានធ្វើអោយដុះដាលប្រព័ន្ធបេះដូង និងផ្លូវដង្ហើម។ បន្តមកទៀត គឺជាការពង្រឹងសរីរាង្គសំរាប់បំពេញតំរូវការរបស់ខ្លួនប្រាណ។ នៅពេលកើត បេះដូងមានមាឌពី

៤០ស.ម$^{៣}$ កើនឡើងបន្តិចនៅអាយុ៦ខែ កើនឡើងបួនដងនៅអាយុ២ឆ្នាំ ហើយឈានដល់ពី ៦០០ទៅ ៨០០ស.ម$^{៣}$ នៅពេល ពេញវ័យ។ មាឌឈាមកើនដោយសមាមាត្រទៅនឹងម៉ាសនៃរាងកាយ។ ទំងន់បេះដូងពី៦០ទៅ៧០ក្រាម សំរាប់ ទារកទើបកើតកើនទៅដល់ ២០ដងសំរាប់មនុស្សចាស់។ ចំនួនកូនចង់សូត (សំរាប់ធានាចរាចរអុកស៊ីសែនក្នុង ឈាម) ឆ្លងពី២០លានទៅ៣០០លាននៅពេលអាយុ៨ឆ្នាំ ហើយជាការវិវត្តចុងក្រោយរបស់សួត។

ថ្លាល (អវៈយវៈត្រង់ចុងឆ្អឹងជំនីមនុស្ស) ចាប់រីកលូតលាស់ និងមានតួនាទីផលិតឡាំផូស៊ីតសំរាប់ប្រព័ន្ធភាពស៊ាំដ៏ល្អប្រសើរនៃអង្គប្រាណ។ ប្រដាប់រំលាយអាហារចាប់ដំណើរការតាមការបរិភោគ។ វក្ក (តំរងនោម) ដើរតួដ៏សក្ដិសមសំរាប់បំបាត់សំណល់ទាំងឡាយ ហើយអាការៈក្នុង ទាំងអស់ (ខួរក្បាល សួត បេះដូង។ល។) ឈានទៅដល់ការបង្គ្រប់មាឌរបស់វា។

ចំណែកប្រដាប់បន្តពូជ ប្រសិនបើវាមានការលូតលាស់ដោយបែបអៀនប្រៀនក្នុងអំឡុងកុមារភាព នោះវានឹងរំដើបរញ្ជួយអស់សរីរាង្គនៅយោព្វនភាព (ការផ្លាស់ពីកុមារភាពទៅជំទង់) ចាប់ផ្ដើមរវាង ៩និង១៣ឆ្នាំ សំរាប់កុមារី, ១០និង១៤ សំរាប់កុមារា) ៕

ប្រែសំរួល តែង យ៉ារ

-----

មិនថាស្គម ឬធាត់នោះទេ ជាទូទៅ នោះគឺអាស្រ័យមកពីបញ្ហាការហូបចុក

<u>គេចែកអាហារជា បី ក្រុម ÷</u>

+ **អាហារសាងសង់ :** ត្រី សាច់ ទឹកដោះគោ ស៊ុត ក្ដាម បង្កង សណ្ដែកបាយ សណ្ដែកសៀង។ល។
+ **អាហារថាមពល :** ខ្លាញ់ជ្រូក ខ្លាញ់ត្រី ប្រេងរុក្ខជាតិ ទឹកឃ្មុំ អំពៅ ស្ករ ស្រូវ ពោត ដំឡូង នំធ្វើពីម្សៅ។ល។
+ **អាហារការពារ :** បន្លែបៃតង ប៉េងប៉ោះ ស្ពៃ ការ៉ុត ត្រប់ ល្ពៅ ផ្លែឈើទុំគ្រប់ប្រភេទ។ល។




## ការអប់រំ (តចប់)

### ៣_ការអប់រំ ដើម្បីក្លាយជាពលរដ្ឋល្អ

គោលបំណងសំខាន់មួយសំរាប់ការអប់រំដែលមានរយៈពេលយូរអង្វែងនោះ គឺការអប់រំដើម្បីក្លាយជាពលរដ្ឋល្អ។ ទស្សនវិទូដ៏ល្បីល្បាញរបស់ក្រិចបុរាណ គឺលោក អារីស្តូត (Aristote) បានពន្យល់ថា ភាពជោគជ័យរបស់រដ្ឋាភិបាលគឺផ្អែកលើគុណភាពនៃការអប់រំដែលត្រូវផ្តល់ដល់យុវជនក្មេងៗ។ លោក ថមើជេហ្វើសិន (Thomas Jefferson) បានសរសេរថា ជាតិសាសន៍មួយដែលសំបូរដោយភាពល្ងង់ខ្លៅ និងភាពទំនេរមិនរំពឹងថា ក្លាយជារដ្ឋស៊ីវិល័យមួយបានឡើយ។

អ្នកប្រវត្តិវិទូអាមេរិកដ៏ល្បីល្បាញម្នាក់ គឺលោក ហង់រី ស្ទីល កុមាជើ (Henry Steele Commager) បានធ្វើការសន្និដ្ឋានថា សាលារៀនជាអ្នកទទួលខុសត្រូវចំពោះការផ្តល់ចំណេះដឹងដល់ប្រជាពលរដ្ឋអាមេរិក ចាប់តាំងពីពេលបង្កើតប្រទេសអាមេរិក។ លោកបានបន្តពន្យល់ទៀតថា គោលដៅទី២នៃការអប់រំ គឺការច្នៃប្រឌិត និងការពង្រឹងគំនិតនៃសហគមន៍ជាតិដើម្បីអភិវឌ្ឍជាតិសាសន៍ថ្មីមួយ វាបានក្លាយទៅជាទឹកដីនៃជនអន្តោប្រវេសន៍ (អ្នកចូលមករស់នៅថ្មីនៃបណ្តាជាតិសាសន៍ជាច្រើន) ពួកគេរស់នៅតាមក្រុមផ្សេងៗគ្នា ដោយគ្មានភាសា ឬវប្បធម៌ឡើយ។ សាលារៀនបានជួយលើកកំពស់គំនិតញាណរបស់សហគមន៍ និងអត្តសញ្ញាណជាតិ ក្នុងចំណោមប្រជាជនទាំងនោះ ដែលគេធ្វើឡើងដោយការបង្រៀនភាសារួមមួយដល់អ្នកដែលទើបមកដល់ថ្មីជាមួយទស្សនៈ នៃការចូលរួមបញ្ចូលតាមរយៈប្រវត្តិសាស្ត្រអាមេរិក។

សព្វថ្ងៃ មានការពន្យល់ជំទាស់ខ្លះថា សាលារៀនមិនទាន់បានចូលរួមអោយបានសមរម្យ ដើម្បីអោយប្រជាជនមានតួនាទីជាពលរដ្ឋល្អនោះទេ។ ការរិះគន់ខ្លះទៀតបានជឿថា មានការធ្លាក់ចុះជាទូទៅមួយក្នុងតម្លៃប្រពៃណី ដូចជាការគោរពច្បាប់ និងបទបញ្ជា ហើយកេងយកចំណេញផ្នែកផ្លូវចិត្តដែលជាកម្មសិទ្ធិរបស់សហគមន៍ជាតិ។ មានក្រុមមនុស្សជាច្រើនទៀត កំពុងធ្វើការអំពាវនាវដល់សាលារៀនអោយជួយបង្កើនការលើកកំពស់បន្ថែមទៀតដល់ការអភិវឌ្ឍនៃចំណេះដឹងអត្តសញ្ញាណជាតិ និងការទទួលខុសត្រូវរបស់សិស្ស។

### ៤_ការអប់រំសំរាប់អភិវឌ្ឍបុគ្គលម្នាក់ៗ

មានទស្សនៈមួយដែលនិយាយថា សាលារៀនគួរត្រូវផ្តល់កម្មវិធីសិក្សា ដើម្បីជួយសិស្សនូវការអភិវឌ្ឍបុគ្គលិក

លក្ខណៈការិតខ្ពស់បំផុត ហើយមានរយៈពេលយូរ ។

ទស្សនៈនេះ ត្រូវបានគេឆ្លុះបញ្ចាំងតាមរយៈច្បាប់មួយដែលគេបានអនុម័តកាលពី១៥ឆ្នាំមុនដែលគេផ្ដោតខ្លាំងទៅលើការរៀបចំកម្មវិធីសិក្សា ដើម្បីតំរូវទៅតាមបំណងប្រាថ្នារបស់បុគ្គលម្នាក់ៗ ។ ក្នុងចំណោមច្បាប់ទាំងនោះ គេអំពាវនាវអោយបង្កើតជាកម្មវិធីសិក្សាពិសេសមួយសំរាប់សិស្សពិការ និងសិស្សរៀនពីរភាសា ។ ការប្រឹងប្រែងនេះ គឺរៀបចំកម្មវិធីសិក្សានៅសាលារៀនអោយល្អបំផុត ហើយមានសកម្មភាពបើកចំហរសំរាប់សិស្សទាំងពីរភេទ ។

ចាប់តាំងពីដើមឆ្នាំ១៩៨០ មានការរីករាលដាលនៃក្រុមគាំទ្រកម្មវិធីសិក្សាដែលបានធ្វើគំរោងមួយឆ្លើយតបទៅនឹងចម្លើយខុសគ្នារបស់សិស្សម្នាក់ៗ ដែលជាទូទៅពួកគេធ្លាប់បានទទួលឥទ្ធិពលតិចជាងក្នុងឆ្នាំ១៩៦០ និងឆ្នាំ ១៩៧០ ។ នេះជាការសើតសំរាំងមួយដែលអ្នករៀបចំនយោបាយត្រូវសំលឹងមើលស្ដង់ដារកម្មវិធីសិក្សាមួយ និងស្ដង់ដារតែស្ដមួយដែលជាចំលើយនៃការទទួលខុសត្រូវរបស់ការអប់រំអាមេរិក ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗ គំរូដែលធ្លាប់ត្រូវបានគេបង្ហាញចំពោះសាធារណៈ គឺជាគំរូដែលមានលក្ខណៈតិចតួច ឬស្ទើរគ្មានផ្ដល់ផលប្រយោជន៍ក្នុងចំណោមអ្នកសិក្សា ។ ក្នុងប្រព័ន្ធអប់រំជប៉ុន ដែលឆ្លុះបញ្ចាំងលើការតំរង់ទិស ប្រជាជនខ្លះជឿថា ប្រព័ន្ធសាលារៀនជប៉ុនគួរត្រូវបានដណ្ដើមជើងឯកនៅក្នុងសហរដ្ឋអាមេរិក ។ ទាំងនេះជាការគាំទ្រនូវទស្សនៈដែលជាអំពើល្អសំរាប់អ្វីមួយ ដើម្បីកាត់បន្ថយលើកម្មវិធីសិក្សាសាលារៀនដែលជាគំរោងដ៏ជាក់លាក់មួយ ដើម្បីឆ្លើយតបទៅនឹងចំលើយរបស់សិស្សម្នាក់ៗដែលមានទស្សនៈផ្សេងៗ ។

ដើម្បីភ្ជាប់ទៅនឹងការឯកភាពគ្នាក្នុងវេទិកាពិភាក្សាជុំវិញការងារអប់រំ ។ អ្នកបុគ្គលិកថ្មីដែលចាប់យកវិជ្ជាជីវៈនេះ ត្រូវការយល់ដឹងនូវចំណេះដឹងមូលដ្ឋានខាងក្រៅ ។ ការយល់ដឹងជាតំរូវការកណ្ដាលដែលមានសារសំខាន់ចំពោះសង្គម ។ កំលាំងប្រវត្តិវិទ្យា និងនយោបាយបានបញ្ជាក់ទៅលើការកែប្រែប្រព័ន្ធសាលារៀន និងការសិក្សា ។ ការយល់ដឹងបានជួយគ្រូបង្រៀនអោយស្ថិតនៅមានមុខងារពិតប្រាកដ ។

បន្ថែមលើនេះ ការសិក្សាដែលស្ដីអំពីមូលដ្ឋានគ្រឹះនៃការអប់រំ នឹងជួយអោយបុគ្គលិកថ្មីមានការយល់ដឹងពីកម្មវិធីសិក្សាសាលារៀនដែលត្រូវបង្កើតឡើង ហើយចាត់ទុកជាអាទិភាពដំបូង ។

មូលដ្ឋានគ្រឹះនៃការអប់រំ រួមមាន : សង្គមវិជ្ជាអប់រំ ប្រវត្តិអប់រំ ចិត្តវិជ្ជាអប់រំ ទស្សនៈវិជ្ជាអប់រំ កម្មវិធីសិក្សា និងការបង្រៀនច្បាប់អប់រំ៕

**អនុបណ្ឌិត គួយ សួនាន**

# វិធីបង្រៀន និងកម្មវិធីសៀវភៅសិក្សាខ្មែរនៅបឋមសិក្សា បំពេញវិជ្ជាពីឆ្នាំ១៩៥៣ ដល់១៩៧០ (ត)

## ១-ការបង្រៀនមេសូត្រ

### ១.១-គោលបំណង

មេសូត្រមានគោលបំណងអោយសិស្សសិក្សា ដោយសូត្រអោយចាំស្ទាត់នូវអត្ថបទមួយ ជាពាក្យរាយ ឬពាក្យកាព្យទៅតាមបែបបទមួយដ៏រស់រវើក ។

### ១.២-សារសំខាន់

- មេសូត្រធ្វើអោយមាន ឬជួយដល់ការអភិវឌ្ឍល័ទឹក ។ មេសូត្រមានតំលៃណាស់ ព្រោះវាជួយអោយសិស្សក្តាប់បាននូវចំណេះដឹង ។
- មេសូត្ររៀបចំបាននូវសមាសភាពមួយដែលផ្តល់ជូននូវគំនិត និងចង្អុលបង្ហាញពីបែបបទក្នុងការសូត្រ
- មេសូត្រធ្វើអោយសិស្សស្រឡាញ់ចូលចិត្ត និងស្គាល់រសជាតិនៃសោភ័ណថ្នែកអក្សរសិល្ប៍ ។
- មេសូត្រ បណ្តុះបណ្តាលបានយ៉ាងប្រសើរនូវរសជាតិមួយចំពោះសិស្សដូចជា អត្ថបទសំរាំង កំណាព្យ រឿងល្បើក... បង្កើតបាននូវគំរូល្អៗ ។
- មេសូត្របង្កើតបាននូវមេរៀនសីលធម៌មួយដ៏ល្អ ។ វាបានបណ្តុះបណ្តាលនូវទឹកចិត្តរបស់សិស្ស អត្ថបទសំរាំង កំណាព្យ រឿងល្បើក ជាទូទៅពោរពេញទៅដោយមេរៀនថ្នែកសីលធម៌ ។ ទាំងនេះជាចំរៀងបញ្ចេញនូវក្តីរីករាយ ឬក្តីក្រៀមក្រំ សេចក្តីសង្ឃឹម មេត្តាធម៌ ឬសេចក្តីរឹងរូស សេចក្តីក្លាហាន ឬភាពកំសាក ទឹកចិត្តស្នេហាមាតុភូមិ ឬមនុស្សជាតិ ។ ក្នុងន័យនេះ សីលធម៌សុទ្ធតែមានលក្ខណៈជាក់ស្តែង ។
- មេសូត្រ គឺជាលំហាត់ដ៏ល្អមួយនៃចលនវិធី គឺការបន្លឺសំលេង ការលើកដាក់សំលេង សំនួនវោហារសព្ទ ។ លើសពីនេះទៀត អត្ថបទកំណាព្យជាតូរ្យតន្ត្រីមួយដែលសណ្ឋិតជាប់ក្នុងល័ទឹកសិស្ស ។

### ១.៣-ការជ្រើសរើសអត្ថបទ

អត្ថបទសំរាំងត្រូវមានលក្ខណៈជាកំណាព្យដែលសិស្សចូលចិត្ត ស្របតាមវ័យ និងកំរិតយល់ដឹងរបស់សិស្ស ស្របតាមធម្មជាតិនៃសាលារៀន ស្របគ្នានឹងមេរៀនសីលធម៌ ។ មេសូត្រជាការបំពេញបង្គ្រប់ថ្នែកសីលធម៌ និងការថាផ្ទួនៗឡើងវិញ ។ វាជាថ្នាំដាស់សតិមួយប្រភេទដែលជំរុញកុមារឱ្យមានទង្វើយ៉ាងសកម្ម មិនមែនជំរុញកុមារអោយស្ថិតក្នុងភាពស្រមើស្រមៃឡើយ ។ វាជាអត្ថបទដែលសំបូរទៅដោយសញ្ចេតនាធម្មជាតិ សេចក្តីស្រឡាញ់រាប់អានគ្នាជាបងប្អូន សេចក្តីស្នេហាមនុស្សដូចគ្នា និងមាតុភូមិ ។

### ១.៤-វិធីបង្រៀនមេសូត្រ

វិធីបង្រៀនមេសូត្រមានដូចតទៅ :

លោកចេត្រ នែម ដែលជាអធិការដ៏ល្បីល្បាញម្នាក់ក្នុងសម័យនោះ បានចែករបៀបបង្រៀនមេសូត្រជាពីរកំរិតថ្នាក់ គឺកំរិតថ្នាក់ដែលសិស្សមិនទាន់ចេះអាន និងកំរិតថ្នាក់ដែលសិស្សចេះអាន ។

នៅកំរិតថ្នាក់ដែលសិស្សចេះអានអក្សរហើយ គ្រូត្រូវសរសេរមេសូត្រនៅលើក្ដារខៀនមុនពេលសិស្សចូលរៀនៈ

- គ្រូអានអត្ថបទនេះមួយចប់អោយសិស្សស្ដាប់ ព្រមទាំងពន្យល់ពាក្យណាដែលសិស្សមិនទាន់ស្គាល់ន័យពាក្យនោះ ដូចជាការបង្រៀនអាន ។
- គ្រូអោយសិស្សអានអត្ថបទនេះម្នាក់ម្ដង១ មួយពួកម្ដង១ ដូចកាលបង្រៀនអាន។ ក្នុងពេលសិស្សកំពុងអាន គេលុបពាក្យម្ដងមួយ១។ មុនដំបូងគេលុបពាក្យបន្ទាប់បន្សំដូចជា ប្រធានកម្មបទ ហើយទីបំផុតគេលុបកិរិយាសព្ទ។ សិស្សនៅតែអានត១គ្នា ម្នាក់ម្ដង១មួយពួកម្ដង១ លុះត្រាតែគេលុបអត្ថបទនោះអស់រលីងនៅលើក្ដារខៀន ។

លោកចេត្រ នែម បានបញ្ជាក់ទៀតថា នៅថ្នាក់ឧត្ដមដ្ឋាន គេគួរតែអោយសិស្សសរសេរអត្ថបទនេះឡើងវិញលើក្រដាសសំណៅមួយសន្លឹក។ គ្រូត្រូវកែអត្ថបទរបស់សិស្សដូចជាគេកែអត្ថបទសរសេរតាមសូត្រ គឺអោយសិស្សមធ្យមម្នាក់ចំលងអត្ថបទរបស់វាដាក់លើក្ដារខៀន ដើម្បីអោយសិស្សទាំងអស់គ្នាកែ ។

ក៏ដូចជាការបង្រៀនអត្ថបទរៀនអានដែរ វិធីបង្រៀនមេសូត្របានអភិវឌ្ឍលំអិតជាងមុន នៅពាក់កណ្ដាលទសវត្សឆ្នាំ ១៩៦០ ដោយគេបានណែនាំដូចតទៅ :

មុននឹងបង្រៀនសិស្ស គ្រូត្រូវបកស្រាយជាមុននូវអត្ថបទដែលត្រូវបង្រៀនសិស្ស បន្ទាប់មកគេត្រូវប្រើល្បិចៈ

- ប្រកាសប្រាប់ពីចំណងជើងកំណាព្យ
- គ្រូអានអត្ថបទជាគំរូ
- គ្រូអោយសិស្សអានអត្ថបទនោះពីរ ឬបីនាក់
- ពន្យល់គំនិតក្នុងអត្ថបទ
- សិក្សាគំរោង និងគំនិតទូទៅ
- មធ្យោបាយដែលអ្នកនិពន្ធប្រើប្រាស់ ដើម្បីឈោងចាប់គោលបំណងរបស់គេដូចជារចនាបទ វាក្យសព្ទ ចង្វាក់
- អោយសិស្សអានអត្ថបទកំណាព្យអោយបានច្រើនដង
- លំហាត់លំនឹក : គ្រូលុបពាក្យក្នុងអត្ថបទកំណាព្យបន្តិចម្ដង១
- ការសូត្រអត្ថបទតាមបែបបំពេញឃ្លាឡើងវិញ
- ការបង្កើតអត្ថបទឡើងវិញ : សិស្សម្នាក់១បង្កើតឃ្លាមួយ ។

ការរៀបរាប់ខាងលើ មិនបានបញ្ជាក់ពីកំរិត ថ្នាក់ទេ ប៉ុន្តែបានបញ្ជាក់ថា គ្រូពុំអាចយកវិធីនេះទៅអនុវត្តបានគ្រប់ថ្នាក់ទេ ។ (នៅមានត)

អនុបណ្ឌិត ស្វ សុធីរ

(៩)Cf.Ministère de l'Education Nationale, Cours de perfectionnement pédagogique,op.cit,p.53-54

# កំណែលំអសាលារៀន : ជំហានដំបូងមួយ (ត)

## រវាងគ្រូប្រចាំថ្នាក់ និងគ្រូប្រចាំថ្នាក់

គ្រូប្រចាំថ្នាក់មានតួនាទីសំរេចលើការសិក្សារបស់សិស្ស ។ គ្រូបង្រៀនល្អ អាចសំរបការបង្រៀនរបស់ខ្លួនអោយឆ្លើយតបទៅនឹងតំរូវការរបស់សិស្ស ហើយអាចធ្វើអោយការរៀនរបស់សិស្សបានសប្បាយដែលអាចជួយអោយកាត់បន្ថយបានប្រកបដោយប្រសិទ្ធភាពនូវអត្រាបោះបង់ការសិក្សា និងធ្លាក់ថ្នាក់ ។ នាយកសាលាទាំងអស់តែងបានយកចិត្តទុកដាក់លើបញ្ហានេះ ។ សកម្មភាពជាច្រើនដូចជា ការបំប៉នគ្រូ ការប្រជុំក្រុមបច្ចេកទេស ទស្សនកិច្ចសិក្សា សុទ្ធតែត្រូវបានអនុវត្តឡើងក្នុងបំណងបង្កើនសមត្ថភាពគ្រូបង្រៀន ។ ប៉ុន្តែទោះបីជាយ៉ាងនេះក្ដី ក៏បញ្ហាសមត្ថភាពគ្រូបង្រៀននៅតែជាបញ្ហាដ៏ធំដែលត្រូវពុះពារជដែល ហើយដំណោះស្រាយស្ថិតនៅក្នុងសាលារៀន ។ ឫសគល់របស់បញ្ហាស្ថិតនៅក្នុងទំនាក់ទំនងរវាងគ្រូ និងគ្រូ ។ នៅសាលាភាគច្រើន គ្រូបង្រៀនពុំមានអន្តរសកម្មភាពរវាងគ្នានឹងគ្នា ។ ពួកគេមានទំលាប់ធ្វើការដោយឡែកទីទៃពីគ្នា ។ ក្រៅពីការប្រជុំផ្លូវការនានាដូចជាការប្រជុំប្រចាំខែ ការប្រជុំក្រុមប្រឹក្សាបច្ចេកទេស ការប្រជុំគណៈកម្មការកំរង ។ល ។ គេមិនដែលឃើញមានការជជែកគ្នារវាងលោកគ្រូ អ្នកគ្រូពីការអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួនទេ ។ ពិតមែនហើយថា កន្លងមកសាលាមួយចំនួនបានយកចិត្តទុកដាក់ដល់ការបង្កើនសមត្ថភាពរបស់គ្រូតាមរយៈការរៀបចំអោយមានទស្សនកិច្ចសិក្សាសំរាប់លោកគ្រូ អ្នកគ្រូបានទៅរៀនសូត្រនូវបទពិសោធន៍ល្អៗពីសាលានានា ប៉ុន្តែសាលាតិចបំផុតដែលបានផ្ដល់ឱកាសជូនពួកគាត់អោយរៀនពីគ្នាក្នុងសាលារបស់ខ្លួនតាមរយៈការសង្កេត និងដកពិសោធន៍សកម្មភាពបង្រៀនរបស់គ្នាទៅវិញទៅមក ។ កង្វះនូវទំនាក់ទំនងរៀនសូត្រពីគ្នាបែបនេះ ញ៉ាំងអោយគ្រូម្នាក់ៗមានភាពឯកោ មិនប្រាស្រ័យទាក់ទងគ្នា ។ ដោយហេតុនេះ បទពិសោធន៍ល្អៗ គំរូអនុវត្តល្អៗ គំនិតថ្មីៗដែលគ្រូបង្រៀនម្នាក់ៗបានរកឃើញ ក៏ស្ថិតនៅតែក្នុងខ្លួនគ្រូនោះ ពុំមានឱកាសនឹងត្រូវបានពង្រីកផ្សព្វផ្សាយឡើយ ។ ម្យ៉ាងទៀត ភាពឯកោនេះក៏បណ្ដុះឡើងផងដែរនូវទំនាក់ទំនងបែបប្រកួតប្រជែងនិយមក្នុងចំណោមគ្រូបង្រៀន ។ ដោយសារគំនិតប្រកួតប្រជែងដណ្ដើមសមានចិត្តពីនាយកសាលា និងមាតាបិតាសិស្សនោះ គ្រូបង្រៀនមួយចំនួនមិនខ្លាចនឹងនិយាយអាក្រក់ពីគ្នាឯង ហើយជាពិសេសគ្មានចេតនាក្នុងការចែករំលែកបទពិសោធន៍ល្អៗរវាងគ្នានឹងគ្នាទេ ។

វិធីដ៏ល្អបំផុតមួយសំរាប់លើកកំពស់សមត្ថភាព គឺការរៀនពីគ្នាទៅវិញទៅមក ការដកពិសោធន៍ពីគ្នាទៅវិញទៅមក ។ ធ្វើយ៉ាងនេះបានលុះត្រាតែគ្រូបង្រៀនម្នាក់ៗជិតស្និទ្ធជាមួយគ្នា សហការក្នុងការងារ និងមានឱកាសបានជជែកគ្នាពីការអនុវត្តរបស់ខ្លួនម្នាក់ៗ ។ ដើម្បីសម្រេចបាននូវបរិយាកាសការងារបែបនេះ នាយកសាលាត្រូវសំរបសំរួលកែប្រែទំនាក់ទំនងរវាងគ្រូនឹងគ្រូ អោយក្លាយជាទំនាក់ទំនងមួយដែលប្រកបដោយអន្តរសកម្មភាព សហប្រតិបត្តិការ និងការជួយគ្នាទៅវិញទៅមក ។ ប្រការនេះទាមទារនូវភាពប៉ិនប្រសប់ ឈ្លាសវៃ និងមធ្យោបាយ

គន្លឹះមួយចំនួនដូចខាងក្រោម ÷

- ផ្តល់ឱកាសអោយគ្រូបង្រៀននិយាយគ្នាពីការអនុវត្ត បង្កើតវេទិកាជជែកគ្នាលើការបង្រៀន និងរៀន អោយបានជាក់ស្តែង និងញឹកញាប់ ។
- ផ្តល់ឱកាសអោយគ្រូបង្រៀនសង្កេតគ្នាទៅវិញទៅមក ។ ការសង្កេតនេះត្រូវផ្សារភ្ជាប់ជាមួយនឹងការ ជជែកគ្នាអំពីការអនុវត្ត ។
- ផ្តល់ឱកាសអោយគ្រូបង្រៀនអង្គុយជាមួយគ្នាធ្វើផែនការមេរៀន និងវាយតំលៃការអនុវត្តកម្មវិធី សិក្សា ។
- លើកទឹកចិត្តអោយគ្រូបង្រៀនចែករំលែករវាងគ្នានឹងគ្នានូវសំភារៈ និងគំនិត ។
- លើកកំពស់អោយគ្រូបង្រៀន បង្រៀនគ្នាទៅវិញទៅមកនូវការបង្រៀន ការរៀន និងការដឹកនាំ ។ ចំណេះដឹង និងជំនាញត្រូវតែបានបង្ហាញ និងចែករំលែកគ្នាទៅវិញទៅមក ។

ទំនាក់ទំនងនេះ ពិតជាពិបាកនឹងធ្វើអោយកើតមានបានណាស់ ។ វាអាស្រ័យលើសមត្ថភាព ឆន្ទៈ និង ឥរិយាបថរបស់គ្រូម្នាក់ៗ ។ នាយកសាលាគប្បីយល់ថា គ្រូបង្រៀនរមែងខុសគ្នាពីម្នាក់ទៅម្នាក់ទាំងលើសមត្ថភាព រៀន សមត្ថភាពការសង្កេត និងការចែករំលែកបទពិសោធន៍គ្នា ។ ដូចនេះ នាយកសាលាត្រូវចេះសំរបសំរួល និង ធ្វើប្រតិកម្មនៅតាមប្រភេទគ្រូនីមួយៗ ។ គាត់គួរតែជ្រាបថា ក្នុងសាលានីមួយៗយ៉ាងហោចណាស់មានក្រុមគ្រូ បង្រៀន បីប្រភេទ ÷

១-គ្រូបង្រៀនដែលមិនមានចេតនាសង្កេត វិនិច្ឆ័យការបង្រៀនរបស់គ្រូដទៃ និងមិនចង់អោយគ្រូដទៃ សង្កេតការបង្រៀនរបស់ខ្លួន ។ គ្រូបង្រៀនក្រុមនេះ មិនមានទំនុកចិត្តក្នុងការធ្វើអោយមានការប្រែប្រួលទេ ។ ពួក គេមិនប្រាកដក្នុងចិត្តលើមុខរបររបស់គេ មានការថប់អារម្មណ៍ ហើយផ្ទេរការថប់អារម្មណ៍របស់ខ្លួនទៅលើសិស្ស និងគ្រូដទៃទៀត ។

២-គ្រូបង្រៀនដែលមានឆន្ទៈចង់កែលំអសមត្ថភាព និងជំនាញរបស់ខ្លួន ប៉ុន្តែមិនមានទំនុកចិត្តក្នុងការ អោយគ្រូដទៃទៀតមកសង្កេតការអនុវត្តការងាររបស់ខ្លួន ។ គ្រូបង្រៀនទាំងនេះ ខំប្រឹងប្រែងធ្វើអោយមានការ ប្រែប្រួលតាមរយៈការឆ្លុះបញ្ចាំងការងារប្រចាំថ្ងៃរបស់ខ្លួន ប៉ុន្តែនៅតែខ្វះទំនុកចិត្តក្នុងការអោយគេមកសង្កេតខ្លួន បង្រៀន និងរំលែកពិសោធន៍ជាមួយគេ ។ ដូចគ្រូក្នុងក្រុមទី១ដែរ គ្រូប្រភេទនេះនៅតែមានការថប់អារម្មណ៍ ។

៣-គ្រូបង្រៀនមួយចំនួនតូច មានឆន្ទៈចង់អោយមានការប្រែប្រួល ។ ពួកគេមានទំនុកចិត្តក្នុងការសង្កេត មើលការអនុវត្តរបស់អ្នកដទៃ មានឆន្ទៈអោយអ្នកដទៃមកសង្កេតការអនុវត្តរបស់ខ្លួន និងមានបំណងពង្រីកបទ ពិសោធន៍របស់ខ្លួនអោយដល់គ្រូដទៃទៀត ។ គ្រូបង្រៀនទាំងនេះ មានទំនុកចិត្តលើខ្លួនគេ ហើយអាចជួយគ្រូ បង្រៀនដទៃទៀតអោយមានការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព ។ ជាភ័ព្វអាក្រក់ គ្រូបង្រៀនក្នុងក្រុមនេះមិន មានចំនួនច្រើនទេ ។

ភារកិច្ចរបស់នាយកសាលា គឺជួយគ្រូប្រភេទទី១ និងទី២ អោយឈានឡើងចូលប្រភេទទី៣ ហើយជួយគ្រូក្នុងក្រុមទី៣នេះអោយបង្កើនបាននូវសមត្ថភាពរបស់ខ្លួនកាន់តែខ្ពស់ថែមទៀត។ គ្រូប្រភេទទី១ និងទី២ ជាមនុស្សប្រកាន់ទំលាប់ និងមិនមានទំនុកចិត្តក្នុងការធ្វើអត្តពិគ្រោះ (Introspection-ការត្រិះរិះខ្លួនឯង)។ ដូចនេះការធ្វើអោយគេឈានទៅរកស្ថានភាពជាអ្នកត្រិះរិះជញ្ជឹងគិត (natural reflection) នោះជាការលំបាកបំផុត។ ដំបូងបំផុតលោកនាយកត្រូវបំផុសឡើងនូវទំនុកចិត្តផ្ទាល់ខ្លួន (self confidence) និងការអោយតំលៃផ្ទាល់ខ្លួន (self esteem) របស់គេដោយបង្កើតឡើងក្នុងសាលានូវបរិយាកាសទុកចិត្តគ្នា (Trust) យោគយល់គ្នា (understanding) និងជួយគ្នាទៅវិញទៅមក។ នាយកសាលាគប្បីបង្ហាញនូវគំរូនៃសេរីភាពក្នុងការចែករំលែកគំនិត និងបទពិសោធន៍។ ត្រូវផ្តល់ការយកចិត្តទុកដាក់លើរាល់គំនិតយោបល់ទាំងអស់ ទោះបីជាគំនិតយោបល់ខ្លះមានលក្ខណៈមិនសមរម្យ ឆ្គាំឆ្គង ឬគួរអោយអស់សំណើចក្តី។

នាយកសាលា គួរតែផ្តួចផ្តើមអោយពួកគេពិនិត្យពិចារណាលើការបង្រៀន និងការគ្រប់គ្រងថ្នាក់របស់គេ ដោយបំប៉នពួកគេអោយចេះពិនិត្យគ្នាទៅវិញទៅមក ជជែកគ្នា ឆ្លុះបញ្ចាំងលើការងាររបស់ខ្លួន ដើម្បីបានជាមូលដ្ឋានក្នុងការធ្វើផែនការទៅអនាគត។

លំនាំក្នុងការជួយគ្រូអោយឈានចូលប្រភេទទី៣ គប្បីធ្វើអោយរឹងមាំគ្រប់គ្រាន់ដែលអាចអោយគេឈានទៅមុខបាន។ ការរីកចំរើនរបស់គេ ទោះបីតិចតួចយ៉ាងណាក្តី ក៏គប្បីត្រូវតែបានទទួលការសរសើរ។ រាល់ការអនុវត្តទាំងឡាយណាដែលបន្ថយបង្អាក់ការជំរុញលើកទឹកចិត្តត្រូវតែចៀសវាង។

នាយកសាលា គួរតែរកឱកាសអង្គុយជជែកលេងជាមួយគ្រូពីបំនិនវិជ្ជាជីវៈរបស់គេ លើកទឹកចិត្តគេអោយយកចិត្តទុកដាក់ដល់ចំណុចខ្លាំងរបស់គេ និងរកវិធានការកែលំអចំណុចខ្វះខាត។ នេះហើយ គឺជាការវាយតំលៃវិជ្ជាជីវៈ។ រាល់ការវាយតំលៃទាំងអស់ គប្បីត្រូវធ្វើតាមបែបវិជ្ជមានដែលភ្ជាប់ជាមួយនូវជំនួយកែលំអផង។

ជួយគ្រូក្នុងប្រភេទទី១ និងទី២អោយឈានទៅរកប្រភេទទី៣ជាការលំបាកហើយ ប៉ុន្តែការជួយគ្រូប្រភេទទី៣អោយមានការរីកចំរើនថែមទៀតនោះ ជាការលំបាកកាន់តែខ្លាំងថែមទៀត។ ជូនកាល ដោយសារការជួយគ្រូប្រភេទទី១ និងទី២ អោយមានការប្រែប្រួលនោះ លោកនាយកបានធ្វើអោយគ្រូប្រភេទទី៣ឈានថយក្រោយមកក្រុមទី១ ឬទី២វិញ។ ប្រការនេះ អាស្រ័យដោយឥរិយាបថរបស់នាយកសាលា។ គ្រូបង្រៀនអាចមានការរីកចំរើនជាអចិន្ត្រៃយ៍បាន លុះត្រាតែគេមានអារម្មណ៍សុខស្រួលក្នុងលំនាំនៃកំណែលំអនោះ។ ក្នុងករណីនេះ នាយកសាលាគប្បីបង្ហាញនូវភាពបើកចំហចំពោះពួកគេ។ គ្រប់អធិការកិច្ចទាំងអស់ ទោះបីជាក្នុងបំណងណាក៏ដោយ ក៏ត្រូវតែប្រាប់គេអោយដឹងមុន។ លើសពីនោះទៀត នាយកសាលា និងគ្រូបង្រៀន គួរតែចែករំលែកគំនិតគ្នាទៅវិញទៅមក ទាំងមុន និងក្រោយអធិការកិច្ច។ រាល់បញ្ហាទាំងអស់ ត្រូវតែយកមកពិភាក្សារកដំណោះស្រាយ។ គ្រូបង្រៀនត្រូវតែមានសេរីភាពក្នុងការសាកល្បងគំនិតថ្មី ហើយបទពិសោធន៍ល្អៗ គប្បីតែត្រូវបានផ្សព្វផ្សាយអោយបានទូលំទូលាយ។ ការប្រជុំថ្ងៃព្រហស្បតិ៍ អាចជាឱកាសមួយល្អបំផុតសំរាប់ផ្សព្វផ្សាយបទពិសោធន៍ទាំងនេះ។

រាល់ការសង្កេតអធិការកិច្ច ត្រូវតែមានគោលដៅលើកកំពស់សមត្ថភាពវិជ្ជាជីវៈរបស់គ្រូ ។ វាត្រូវតែមានផលប៉ះពាល់ជាវិជ្ជមានលើការលូតលាស់របស់គ្រូ ចៀសវាងបង្កើតឡើងនូវការថប់អារម្មណ៍ និងការប្រកួតប្រជែងរវាងគ្រូបង្រៀន ។

វិធីដ៏ល្អមួយទៀត ដើម្បីធ្វើអោយមានការប្រែប្រួលជាវិជ្ជមានក្នុងទំនាក់ទំនងរវាងគ្រូបង្រៀន គឺការជួយគេអោយធ្វើការជាក្រុម ។ ក្រុមល្អ អាចជួយគ្រូអោយមានការរីកចំរើនបានប្រកបដោយប្រសិទ្ធភាព ។

(នៅមានត)

លោក អ៊ុច សារិត់
អតីតអនុប្រធានមន្ទីរអប់រំ យុវជន
និងកីឡា ខេត្តតាកែវ (ចូលនិវត្តន៍)

## ចំលើយប្រស្នាល្បងប្រាជ្ញាទំព័រទី ១២

ព្រានព្រៃទាំងពីរនាក់បោះវល្លិ៍មកគ្នាអោយបានប្រវែងលើសទទឹងស្រះ ហើយចងគប់ចំកណ្តាលខ្សែវល្លិ៍។ បន្ទាប់មក ព្រានព្រៃកាន់កន្ទុយខ្សែទាញដើរទៅមាត់ស្រះម្ខាងម្នាក់ ដោយទាញខ្សែអោយតឹង លៃដាក់គប់អោយចំភ្លើង។ ពេលឃើញភ្លើងឆេះគប់ហើយ ព្រានព្រៃទាំងពីរត្រូវស្រាវខ្សែដើរមកជួបគ្នាវិញ ដូចរូបខាងក្រោម :



# ការផលិតសម្ភារៈ និងការប្រើប្រាស់សម្ភារៈឧបទេសក្នុងការបង្រៀន វិទ្យាសាស្ត្រអនុវត្តនៅបឋមសិក្សាតាមគោលវិធីសិស្សមជ្ឈមណ្ឌល

ក្នុងការបង្រៀនវិទ្យាសាស្ត្រអនុវត្ត លោកគ្រូ អ្នកគ្រូត្រូវតែមានសំភារៈឧបទេសជាចាំបាច់ គឺធ្វើយ៉ាងណាអោយសិស្សានុសិស្សយើងបានឃើញ កាន់ ហើយមានគំនិតស្រាវជ្រាវបន្ទាប់ពីគេបានទទួលចំណេះដឹងពីសាលារួច។ ព្រោះការបង្រៀនវិទ្យាសាស្ត្រអនុវត្ត លោកគ្រូ អ្នកគ្រូត្រូវទាញយកធម្មជាតិ និងបរិស្ថានខាងក្រៅចូលមកក្នុងថ្នាក់រៀន ហើយយកចំណេះដឹងដែលសិស្សទទួលបានពីក្នុងថ្នាក់រៀនទៅបំរើអោយការវិវឌ្ឍរបស់ធម្មជាតិ និងបរិស្ថានខាងក្រៅវិញ។

ដើម្បីជាជំនួយដល់លោកគ្រូ អ្នកគ្រូ ខ្ញុំសូមលើកយកឧទាហរណ៍នៃការផលិត និងប្រើប្រាស់សំភារៈឧបទេសក្នុងការបង្រៀនវិទ្យាសាស្ត្រអនុវត្តស្តីពី "ដំណាំកប្បាស" មកបង្ហាញជូនដូចខាងក្រោម÷

## I. លក្ខណៈចាំបាច់ដែលលោកគ្រូ អ្នកគ្រូត្រៀមមុនពេលបង្រៀន

មុនពេលបង្រៀន លោកគ្រូ អ្នកគ្រូត្រូវមានសំភារៈដូចតទៅ÷

- ក្រមា អំបោះ (សំឡីកប្បាស) គ្រាប់កប្បាស
- ផ្លែកប្បាសទុំ ខ្ចី ឬរូបភាព
- ស្លឹកកប្បាស
- សំបកដបទឹកសុទ្ធ កញ្ចប់ដី និងដី (សំភារៈទាំងអស់ សំភារៈខ្លះលោកគ្រូ អ្នកគ្រូអាចអោយសិស្សយកពីផ្ទះមកបាន)។



ដំណាំកប្បាស

ចំពោះស្លឹកកប្បាស ដើម្បីរក្សាអោយបានយូរ លោកគ្រូ អ្នកគ្រូ ត្រូវកាត់ទងដោយរក្សាទុកស្លឹកមួយ ឬពីរ។បន្ទាប់ពីកាត់រួចត្រូវយកស្លឹកនេះទៅដាក់ក្នុងផ្នត់នៃក្រដាសកាសែត (ក្រដាសកាសែតមិនរលោង) ហើយយកទៅសង្កត់នៅកន្លែងរាបស្មើបានបីទៅបួនថ្ងៃ។ ត្រូវផ្លាស់កន្លែងលើផ្ទៃនៃក្រដាសកាសែត ដើម្បីអោយវាឆាប់ឆ្អួត។ ធ្វើរបៀបនេះរហូតដល់រយៈពេលពី១០ទៅ១៥ថ្ងៃ។ នៅពេលស្លឹកស្ងួតល្អហើយ យើងយកស្លឹកនេះទៅបិទលើក្រដាស រួចយកស្បោងផ្លាស្ទិចស្រោបការពារដើម្បីរក្សាទុកអោយបានយូរ។

ឧទាហរណ៍ : មានលក្ខណៈដូចស្លឹកកប្បាសខាងលើនេះ ។

## II. ដំណើរការបង្រៀន

បែងចែកក្រុមសិស្ស ហើយអោយក្រុមនីមួយៗពិនិត្យក្រមា :

- លោកគ្រូ អ្នកគ្រូ បំផុសសំណួរ តើគេផលិតក្រមាពីអ្វី?
    - សិស្សខ្លះអាចឆ្លើយ : គេផលិតក្រមាពីអំបោះ។
- លោកគ្រូ អ្នកគ្រូ យកអំបោះអោយក្រុមនីមួយៗរបស់សិស្សពិនិត្យ ហើយបំផុសសំណួរ តើអំបោះគេរវៃ ឬធ្វើពីអ្វី?
    - ពេលសិស្សឆ្លើយសំណួរជាហូរហែមក ត្រូវកែតម្រូវចំលើយរបស់សិស្ស ដើម្បីអោយត្រូវនឹងចំណុចដែលលោកគ្រូ អ្នកគ្រូចង់បានឬនៅតំបន់ដែលមានដំណាំកប្បាសសិស្សអាចឆ្លើយបានត្រឹមត្រូវតែម្តង។
- លោកគ្រូ អ្នកគ្រូ បង្ហាញសំឡីអោយក្រុមសិស្សពិនិត្យ ហើយបំផុសសំណួរ ធ្វើរបៀបសំណួរនិងចំលើយ ខាងលើ។
- បន្ទាប់មក លោកគ្រូ អ្នកគ្រូបង្ហាញផ្លែកប្បាសទុំ ខ្ចីឬរូបភាព( ទៅតាមតំបន់ដែលងាយរកនិងមិនអាចរកបាន) អោយក្រុមសិស្សពិនិត្យ ដើម្បីអោយសិស្សស្គាល់ពីប្រភពដំណាំដែលផ្តល់សំឡី។ រូបភាពមានលក្ខណៈដូចរូបខាង ក្រោម :



**ផ្លែកប្បាសខ្ចី**



ផ្លែកប្បាសទុំ



តើគេដាំកប្បាសដូចម្តេច?

បង្ហាញគ្រាប់កប្បាសអោយសិស្សតាមក្រុមពិនិត្យ។ ក្រុមនីមួយៗយកសំបកដបទឹកសុទ្ធមកកាត់ជាពីរផ្នែក។ ផ្ការផ្នែកខាងមាត់ ដាក់កំណាត់ជក់ទឹកនៅមាត់ដប និងដាក់ដីលាយជីពីលើ ហើយយកទៅដាក់លើផ្នែកខាងក្រោមដែលដាក់ទឹក (រូបភាពខាងឆ្វេង)។ លោកគ្រូ អ្នកគ្រូ អោយសិស្សដាក់គ្រាប់កប្បាស់ដាំ និងបិទថ្ងៃ ខែ ដែលដាំ ហើយធ្វើបំណែងចែកអោយក្រុមនីមួយៗធ្វើកាលវិភាគថែរក្សា និងសង្កេតរយៈពេលដែលដុះ និងអោយសិស្សសង្កេតការវិវត្តរបស់ដំណាំកប្បាស។

នេះជាគំរូនៃការដាំដំណាំកប្បាសដូចបានរៀបរាប់ខាងលើ

លោក : សាន់ ប៊ុនលី អធិការបឋមសិក្សា
អធិការដ្ឋានអប់រំ ក្រសួងអប់រំ យុវជន និងកីឡា



# វិធីបង្រៀនគំនូរ (ត)

ដោយលោក ប៉ាន់ ត្រា

## ការផាត់ និងការអោយស្រមោលដោយខ្មៅដៃ

នៅត្រីមាសទី១ ត្រូវអោយសិស្សគូរ និងអោយស្រមោលតាមខ្លួនសង្កេតពិនិត្យឃើញដោយខ្មៅដៃ គឺបានសេចក្តីថា គ្រាន់តែបង្វឹកសិស្សអោយថ្មឹក អោយយល់ក្នុងការវាស់ និងយល់ក្នុងការអោយស្រមោលប៉ុណ្ណោះ ជាការប្រសើរណាស់ទៅហើយ សមនឹងពាក្យស្លោកគរុកោសល្យថា : "បង្រៀនតិច ប៉ុន្តែល្អ"។

## ការលាប និងការអោយស្រមោលដោយថ្នាំពណ៌ទឹក

កាលក្នុងត្រីមាសទី១ សិស្សបានរៀនគូរ និងអោយស្រមោលគំនូរជាច្រើនមកហើយដោយប្រើខ្មៅដៃ។ ដូចនេះសិស្សប្រាកដជាយល់ខ្លះហើយអំពីរបៀបគូរ និងអោយស្រមោលនេះ។

ដល់មកត្រីមាសទី២ លោកគ្រូ អ្នកគ្រូ ត្រូវធ្វើសហការជាមួយសិស្ស ដើម្បីវិភាគរាវរកពណ៌ផ្សេងៗដែលត្រូវលាប និងអោយស្រមោលលើគំនូរដែលបានគូរដោយថ្នាំពណ៌។

មុននឹងអោយសិស្សលាប និងផាត់ស្រមោលដោយថ្នាំពណ៌ លោកគ្រូ អ្នកគ្រូត្រូវណែនាំសិស្សអោយស្គាល់សំបុរខ្ចី ឬចាស់ និងរបៀបលាយដែលនឹងត្រូវយកមកលាប និងផាត់លើគំនូរជាមុនសិន។

យើងជូនជាឧទាហរណ៍ដូចខាងក្រោមនេះ ÷

សំបុរខ្ចី (គឺផ្នែកវត្ថុដែលពន្លឺចាំងចំ)។ បើវត្ថុដែលគូរនោះមានពណ៌ដូចម្តេច ពណ៌ដែលត្រូវលាបនៅកន្លែងនោះក៏ត្រូវមានពណ៌ដូចនោះដែរ។

សំបុរខ្មៅព្រាល គឺយកពណ៌របស់វត្ថុជាគំរូលាយនឹងខ្មៅបន្តិច (តាមសំបុរដែលយើងចង់បាន)។

សំបុរចាស់ គឺសំបុរខ្មៅព្រាល លាយនឹងខ្មៅបន្តិចថែមទៀត (តាមសំបុរដែលយើងចង់បាន)។

## គំនូរបង្ហាញរបៀបលាប និងផាត់ស្រមោលដោយថ្នាំពណ៌

វត្ថុរាងមូលទ្រវែង : ថូដាក់ផ្កា (ពណ៌បៃតង)



រូបទី១



រូបទី២



រូបទី៣



រូបទី ៤



រូបទី៥

## ការលាបពណ៌

- លាបពណ៌ថូនេះ តាមពណ៌ពិតរបស់វា គឺថាបើថូនោះពណ៌ក្រហម ត្រូវលាបពណ៌លើគំនូរពណ៌ក្រហមដែរ។ បើថូនោះពណ៌បៃតង ត្រូវលាបពណ៌លើគំនូរក៏ពណ៌បៃតងដែរ នៅចំហៀងខាងឆ្វេងដែលពន្លឺចាំងមកចំ (រូបទី១) ។
- នៅចំហៀងខាងស្តាំដែលបាំងពន្លឺនោះ ត្រូវលាបសំបុរងងឹត (ក្រមៅ) គឺយកពណ៌ថូមកលាយនឹងពណ៌ខ្មៅបន្តិច បានជាពណ៌បៃតងក្រមៅ ឬបៃតងចាស់។
- យកពណ៌បៃតងចាស់ក្រមៅនេះមកលាបផ្នែកថូខាងស្តាំជាផ្នែកបាំងពន្លឺ លុះត្រាតែមកជួបនឹងពណ៌បៃតងខ្ចីដែលបានលាបរួចមកហើយពីខាងឆ្វេង (រូបទី២) ។
- យកជក់ស្អាតជ្រលក់ទឹកអោយសើមល្មម ហើយយកមកជូតរំលាយតំណពណ៌ទាំងពីរនោះពីលើចុះក្រោម លុះត្រាតែពណ៌បៃតង និងបៃតងចាស់នោះរលាយចូលគ្នា (រូបទី៣) ។

## ការលាបថាន

យកពណ៌ដទៃទៀតដែលមានសំបុរខុសអំពីពណ៌បៃតង គឺពណ៌ថ្មដូចជា លឿង ក្រហម ខៀវ ឬស្វាយមកលាបបំពេញថាន ដើម្បីបំផុសរូបរាងថូនោះអោយលេចឡើង។

របៀបលាបថាននេះ ត្រូវបាននិយាយពីដើមរួចមកហើយគឺ÷

- បើផ្ទៃរូបភាពមានពណ៌សំបុរខ្ចី ត្រូវលាបថានពណ៌ចាស់។
- បើផ្ទៃរូបភាពមានពណ៌ចាស់ ត្រូវលាបថានពណ៌ខ្ចី។

## វត្ថុរាងជ្រុង

ចំពោះវត្ថុដែលមានរាងជ្រុង ការផាត់ស្រមោលដោយថ្នាំពណ៌មានរបៀបដូចការអោយស្រមោលដោយខ្មៅដៃដែលបានបង្ហាញពីលើនោះដែរ គឺជ្រុងនីមួយៗមានសំបុរខ្ចី ឬចាស់ដាច់ៗពីគ្នា គ្មានការផាត់បំព្រាលរំលាយពណ៌ចូលគ្នា ដូចស្រមោលវត្ថុរាងមូលទ្រវែងនោះឡើយ។

ឧទាហរណ៍ : វត្ថុរាងជ្រុង÷ សៀវភៅមើល...។

មើលពីខាងឆ្វេង




១- លាបពណ៌សនៅជ្រុងទទឹងខាងឆ្វេង ។

២- នៅជ្រុងបណ្តោយខាងមុខ ត្រូវលាបពណ៌សលាយខ្មៅបន្តិច (គឺពណ៌ប្រផេះយ៉ាងស្រាល) ។

៣- ឯក្របត្រូវលាបតាមពណ៌ក្របសៀវភៅជាគំរូ ។

មើលពីខាងស្តាំ




១- លាបពណ៌សលាយខ្មៅបន្តិច គឺពណ៌ប្រផេះយ៉ាងខ្ចី នៅជ្រុងបណ្តោយខាងមុខ ។

២- នៅជ្រុងទទឹងខាងស្តាំ ត្រូវលាបពណ៌ប្រផេះក្រមៅ គឺប្រផេះស្រាលថែមខ្មៅបន្តិចទៀត ។

គំនូររាងមូល និងជ្រុងខាងលើនេះ បានបង្ហាញរបៀបគូរ លាបពណ៌ និងអោយស្រមោលយ៉ាងច្បាស់លាស់ ។ ដូចនេះ លោកគ្រូ អ្នកគ្រូប្រាកដជាយល់ជាក់លាក់ហើយ ។

ហេតុនេះ ការរិះរកវត្ថុផ្សេងៗជាគំរូដាក់អោយសិស្សគូរនោះ ជាភារៈរបស់លោកគ្រូ និងអ្នកគ្រូនេះឯង ។

(នៅមានត)

**គេគណិតវិទ្យាស្ទើរជាមួយនឹងព្រឹត្តិការណ៍ មិនខុសអ្វីពីគេសាងសង់គេហដ្ឋានអំពីឥដ្ឋៗ ប៉ុន្តែការប្រមូលព្រឹត្តិការណ៍ ក៏មិនមានន័យថា ការគណិតវិទ្យាស្ទើរនោះឡើយ មិនខុសអ្វីពីគ្រាន់តែការគរឥដ្ឋទេៗ ដូចនេះ ទាចាំបាច់ត្រូវតែមានគោលការណ៍ឯកភាពមួយៗ**

**ហង់រី ពង់ការ៉េ**

(Henri Poincaré : គណិតវិទូជនជាតិបារាំង ១៨៥៤-១៩១២)

# ភាសា

## ព្យាង្គតំរួតក្នុងសម័យខេមរយានកម្ម (ត)

### ១.២_ក្បួនវិធីផ្សេងទៀត

#### ១.២.១.អំពីបន្តក់

សៀវភៅវេយ្យាករណ៍ភាគច្រើនបានពន្យល់អំពីបំរើបំរាស់បន្តក់។ ពេលនេះយើងសូមកត់សំគាល់លក្ខណៈ ២ ចំណុចគឺ :

**ក-តួព្យញ្ជនៈប្រកបក្នុងភាសាខ្មែរសុទ្ធមាន :**

ក ង ច ញ ត ន ប ម យ រ ល វ ស។ ឯវណ្ណយុត្តិប្រើជាជំនួសព្យញ្ជនៈប្រកបមាន២ គឺ " ំ" (ម់) និង "ះ" (ហ់)[(១)]។

**ខ-តួព្យញ្ជនៈប្រកបដែលអាចទទួលបន្តក់បានមាន ៩តួ :**

ក ង ច ញ ត ន ប ល ស[(២)]។

ដូចនេះ តួ "ម" ពុំអាចប្រើប្រកបនឹងតួស្រៈដែលមានសញ្ញាបន្តក់ ( ់ ) ឡើយ :

- ស្រះកប់តួមានបន្តក់ ( ់ ) "ា+់> ាំ " សំរាប់កត់សូរខ្លី [អ់] រឺ [អ៊់]។
- ឯស្រះភ្ជាប់តួមានបន្តក់ ( ់ ) "ា+់>ា់" សំរាប់កត់សូរខ្លី [អាំ] រឺ [អ៊ាំ]។

#### ១.២.២.<u>អំពីនិគ្គហិត ( ំ )</u>

- សៀវភៅវេយ្យាករណ៍ សង្ខេប "សូរស័ទខ្មែរ" ÷
  + នៅទំព័រ៥៨ មានសេចក្ដីថា តួ ុំ ំ ាំ... ជាព្យាង្គបិតខ្លីជាមួយនឹង ម ប្រកប ÷

អុម > ុំ      អម់ > ំ      អាម់ > ាំ

អ៊ុម > ុំ      អ៊ម់ > ំ      អ៊ាម់ > ាំ ។

  + នៅទំព័រ២៤ មានសេចក្ដីថា និគ្គហិត ( ំ ) ជំនួស "ម់" ÷ សម់ > សំ...។

- សៀវភៅទំរង់សូរវិទ្យាខ្មែររបស់បណ្ឌិតអក្សរសាស្ត្រឃួន សុខម្ភ (១៩៧០)
  + នៅទំព័រ១៩មានសេចក្ដីថា រូមមក [m] ជាសូរច្រមុះបបូរមាត់លឺ។ ក្នុងឋានៈជាខ្យល់ប្រកប សូរនេះមានលក្ខណៈជាសូរលេបដូចជាក្នុងពាក្យតាម [ta:m] ដាំ [dam] ទុំ [tum]។
  + ឧទាហរណ៍ផ្សេងទៀត ÷ រលីម [rɔli:m] ឡេម [le:m] ឡឹម [lœ:m] កំពុង [kɔmpuŋ]

---

(១) កេង វ៉ាន់សាក់ សូរស័ព្ទខ្មែរ បោះពុម្ពលើកទី១ គ.ស១៩៦៦ ទំព័រ២១ និងទំព័រ៩៤។

(២) ពូវ អ៊ុម វេយ្យាករណ៍ខ្មែរ បោះពុម្ពលើកទី១ ព.ស ២៤៨៨ ទំព័រ៦។

ដំបូល [dɒmbo:l] សូម [so:m] សុំ [som] ជំហរ [cɔmhɔ:r] នំ [nɔm] កម [kɒ:m] ដំ [dɒm] តាម [ta:m] ព្រម [prɔ:m] ភូមិ [phu:m]... ។

ដូចនេះ សូរ [m] កត់ សំគាល់ដោយសញ្ញាពីរសំរាប់ប្រើជាតួប្រកបគឺ សញ្ញា "ម" និង សញ្ញាដំលើ " ំ "÷

- ក្នុងនាទីជាតួប្រកបក្នុងព្យាង្គ សញ្ញា "ម" ប្រើជាមួយនឹងតួស្រៈវែង ដូចជាក្នុងពាក្យលឹម ឡោម ឡឹម កម សូម តាម...។
- ក្នុងនាទីជាតួប្រកបក្នុងព្យាង្គ សញ្ញា " ំ" ប្រើជាមួយនឹង
  + តួស្រៈខ្លី ដូចជាក្នុងពាក្យ ÷ ទុំ សុំ...។
  + តួស្រៈខ្លីប្រើបន្តក់ ដូចជាក្នុងពាក្យ ÷ ដំ នំ កំពុង ជំហរ ដាំ...។

ក្បួនវិធីខាងលើទាំងអស់នេះ ជាគំរាយផ្លូវដ៏សំខាន់ដែលនាំអោយខេមរយានកម្មអាចសំរេចចិត្តជាចុងក្រោយ ។

## ២_ការសិក្សាស្រាវជ្រាវ

ទន្ទឹមនឹងការអនុវត្តខេមរយានកម្មក្នុងការសិក្សាដោយប្រញាប់ប្រញាល់ អង្គការខេមរយានកម្មបានខិតខំធ្វើការសិក្សាស្រាវជ្រាវ ដើម្បីរកអោយឃើញចំណុចខ្វះខាត ហើយកែលំអជាបណ្តើរៗថែមទៀតផង ។ អង្គការខេមរយានកម្មយកចិត្តទុកដាក់ទៅលើបញ្ហាជាច្រើន ជាពិសេសបញ្ហាសំនេរព្យាង្គគំរូត ។

### ២.១_ពាក្យក្លាយ (ពាក្យដែលគេស្គាល់ពាក្យឫស)

តាមការស្រាវជ្រាវ ពាក្យឫសអាចបង្កើតពាក្យក្លាយពីរព្យាង្គ សរសេរជាព្យាង្គរាយក៏មាន សរសេរជាព្យាង្គគំរូតក៏មាន ។

ក_ពាក្យក្លាយពីពាក្យឫសផ្តើមដោយព្យញ្ជនៈទោល

| ពាក្យឫសផ្តើមដោយព្យញ្ជនៈទោល | | | | | | | |
|---|---|---|---|---|---|---|---|
| ទំរង់ផ្នត់ | ពស-ពពស | ពសព- | | -សព/ព- | -សព- | -ស/ព- | ពាក្យក្លាយខ្លះអាចសរសេរបាន២យ៉ាង |
| ពាក្យក្លាយ | ព្យាង្គរាយ | ព្យាង្គគំរូត | ព្យាង្គរាយ | ព្យាង្គរាយ | ព្យាង្គរាយ | ព្យាង្គរាយ | |
| ពីពាក្យឫស ÷ កើត | | បង្កើត | | កំណើត | | | |
| កាយ | កកាយ | | | កំនាយ | | | |
| កាន់ | ប្រកាន់ | បង្កាន់ | | កំនាន់ | | | |
| ខាត | | បង្ខាត | | | កំហាត | | |
| ចាស់ | | កញ្ចាស់ | | ចំនាស់ | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ជាន់ | ប្រជាន់ | បញ្ជាន់ | | ជំនាន់ | | | |
| ឈប់ | | បញ្ឈប់ | | | ជំហប់ | | |
| ដើរ | | បណ្ដើរ | | ដំនើរ | | | |
| តឹង | | បន្តឹង | | តំនឹង | | | |
| ថយ | | បន្ថយ | | | តំហយ | | |
| បែក | | | បំបែក | បំនែក | | | |
| ពើង | | | បំពើង | ពំនើង | | | |
| ភាយ | | | បំភាយ | | ពំហាយ | | |
| រីង | | ពង្រីង | សំរេង | | | របេង | សំរេង ឬសម្រេង |
| រុក | | | សំរុក | | | របុក | សំរុក ឬសម្រុក |
| វិល | ក្រវិល | បង្វិល | | | | | |
| ហាត់ | | បង្ហាត់ | លំហាត់ | | | | |
| អៅ | | បង្អៅ | | | | | |
| អោយ | | | | អំនោយ | | | |
| យល់ | | ពន្យល់ | | | | យោបល់ | |
| លេច | | សម្លេច | | | | | សំលេច ឬសម្លេច |
| សល់ | | បន្សល់ | | សំនល់ | | | |
| សិត | | | | សិរិត | | | សិរិត ឬសម្រិត |
| ងំ | | | សំងំ | | | | សំងំ ឬសម្ងំ |
| បក | | | សំបក | បំនក | | | សំបក ឬសម្បក |
| រលាក | | | | | រំលាក | | រំលាក ឬរម្លាក |
| រលំ | | | | | រំលំ | | រំលំ ឬរម្លំ |
| រអិល | | | | | រំអិល | | រំអិល ឬរម្អិល |

(នៅមានត)

ស្វ មុយឃៀង




# យើងទាំងអស់គ្នាជួយការពារត្រីបឹងទន្លេសាប

អាងក្លាំទន្លេ សាបជាបឹង ចំណុះអោយស្ទឹង ហូរចូលមក
នាំទាំងមច្ឆា ច្រើនគគោក អោយសម្ងំជ្រក ក្នុងទឹកសាប ។
តាំងពីស្ទឹងសែន បត់បែនជិត និងស្ទឹងជីនិត ពិតខ្ពង់រាប
ស្ទឹងស្មោងហូរខ្លាញ់ បាញ់ទំនាប ទឹកស្ទឹងសៀមរាប ហូរមកដែរ ។
ឯស្ទឹងជីក្រែង តែងសំរុក នាំទឹកហូរបុក ហៀរពេញស្រែ
ស្ទឹងបរិបូណ៌ ហូររាល់ខែ នាំត្រីមកដែរ ចូលក្នុងអាង ។
បើស្ទឹងស្រែងដៃ ទោះថ្ងៃយប់ ហូរជួយបង្គ្រប់ តែមិនខ្លាំង
វីស្ទឹងពោធិ៍សាត់ ប្រឹងប្រណាំង ជូនតិចជូនខ្លាំង មិនហ៊ានឈប់ ។
ស្ទឹងមង្គល បូរីកំពង់ស្វាយ ខំហូរពីឆ្ងាយ កាយជីល្បប់
ឯស្ទឹងជូនទ្រី ព្រែកអូរនប អូរជាហូរគ្រប កាត់ពាមចាំង ។
ស្ទឹងស្រែងស្វែង ឧត្តរមានជ័យ ជាប់ព្រំដែនថៃ ឆ្ងាយពីអាង
ប៉ុន្តែប្រឹងហូរ តាមកំលាំង ពេលទឹកស្រកខ្លាំង កាន់តែលឿន ។
គ្រប់ស្ទឹងសុទ្ធសឹង បាននាំត្រី តិច ឬច្រើនក្តី មកបង្កើន
អោយរស់ជ្រកជុំ ផ្តុំពងកូន ម្តងរាប់រយផ្លូន ក្នុងកោងកាង ។
និងព្រៃរនាម ដែលលិចទឹក សត្វល្អិតរវើក ទឹកឡើងខ្លាំង
ត្រីហក់ត្រចាក់ ស៊ីប្រណាំង សប្បាយចិត្តនឹង បង្កាត់ពូជ ។
កញ្ចុះ អណ្តែង កញ្ជ្រោក់ស្លា ត្រីលិញ ត្រីប្រា មានធំតូច
ត្រីផ្ទក់ សណ្តាយ បែបរាងខូច ក្រវែលលបលួច ស៊ីកូនគេ ។
ត្រីក្រាយ ក្រឹមក្រាញ់ មិនចាញ់មាឌ ទោះខ្លួនតូចល្អិត ស្ចិតម្ទេះទេ
ក៏ខំពងកូន គ្មានទំនេរ ផ្សព្វផ្សាយពូជដែរ ខ្លាចបាត់បង់ ។

ត្រីឆ្ពិន ត្រីឆ្កោក ត្រីកន្ធរ ត្រីរៀល ត្រីពោធិ៍ និងត្រីឆ្លាំង
មិនសូវរវល់ ហែលសំកាំង ជ្រកក្នុងដើមរាំង ដែលលិចទឹក ។
ត្រីឆ្នូញ ត្រឱន ត្រីក្លាំងហាយ ត្រីផ្ទោងប្រញាយ ជ្រើមពេលព្រឹក
ចង្វារ ព្រលូង ខ្ទឹងមិនស្លឹក ចិត្តតែងគិតនឹក ខ្លាចផុតពូជ ។
ត្រីច្រកែង ឆ្កោក អណ្តាតឆ្កែ ត្រីស្លាតលង់ស្នេហ៍ ធ្លាប់តែខូច
ខ្លួនរាងសំប៉ែត ឆ្អឹងតូចៗ តែអាចផុតពូជ ព្រោះប្រហិត ។
ត្រីខ្នាន់ ត្រីកែស ត្រីកន្ត្រប់ រស់នៅសែនស្ងប់ មិនសូវគិត
ទោះទឹកជ្រៅរាក់ អាចផលិត ពូជកូនបង្កាត់ ដូចគេឯង ។
កំភ្លាញ ក្អុក ក្អិត ពិតតូចមែន តែពងរាប់សែន មិនកំប្លែង
រស់ដូចអស់គេ ឥតទាស់ទែង ប្រកាន់ហួងហែង បែងទឹកដី ។
ប៉ុន្តែមានត្រី ច្រើនប្រភេទ តាមខ្ញុំសង្កេត គួរអាល័យ
ព្រោះជិតផុត ពូជពីផែនដី ដោយសារគ្រោះភ័យ នៃបរិស្ថាន ។
ត្រីនាគ ត្រីរាជ ត្រីគល់រាំង ត្រីត្រសក់សាំង ពន់ប្រមាណ
ត្រីស្ទក់ ត្រីក្បក ត្រីក្បាលឡាន ត្រីជន្លួញមាន់ ត្រីដំរី ។
ត្រីឆ្កោកទីទុយ ប៉ាស៊ីអ៊ី ឃើញសល់មួយពីរ ជាចំណី
សម្រាប់អ្នកមាន លក់បានថ្លៃ នៅក្នុងទឹកដី ខេត្តស្ទឹងត្រែង ។
ត្រីឆ្នាក្រពើ ត្រីរមាស ក៏ស្ទើរវិនាស ហួសនឹងថ្លែង
ត្រីកន្ត្រប់ខ្លា កន្ត្រងប្រេង កំភ្លាញ សម្រែ ឃើញតិចណាស់ ។
ការរៀបរាប់ត្រី នៃទឹកសាប ខ្ញុំសូមសង្ខេប មិនទាន់អស់
ព្រោះប្រភេទត្រី ច្រើនរយនោះ ខ្ញុំស្គាល់មិនអស់ ខ្វះឯកសារ ។
ប៉ុន្តែសំខាន់ យើងត្រប់គ្នា ខំជួយការពារ ពូជមច្ឆា
រដូវពងកូន កុំប៉ះពារ ឬនេសាទវា ទ្រង់ទ្រាយធំ ។
នេសាទបរិភោគ ក្នុងគ្រួសារ នោះគ្មានបញ្ហា ទេពូអ៊ុំ
ប្រើឈ្នាងអង្រុត ឆ្នុកទ្រូផ្សំ ចងសន្ទូចត្រាំ ដាក់បង្កៃ ។
សូមកុំប្រើប្រាស់ អួនអញ្ចង សំណាញ់ មងត្រង ឬអួសស្បៃ
អោយបែកសំបុក ខ្ចាត់ពងត្រី លង់លិចក្នុងដី ក្សយផុតពូជ ។

(នៅមានត)

ដោយលោក ហាស់ ម៉ុចតេវ៉ា

អធិការបឋមសិក្សា មន្ទីរអប់រំ យុវជន និងកីឡា ខេត្តស្វាយរៀង

# បានរស់

(បទពាក្យ ៧)

បានរស់ព្រោះតែម្ដាយឪពុក
រស់មួយជីវិតពេញដោយហេតុ
បានរស់ត្រូវតែអោយមានភ័ព្វ
កិរិយាថ្លៃថ្នូរ ស គំនិត

បានរស់ស្គាល់មុខព្រោះសង្កេត
រស់បានសង្កេតហេតុជាមជិត ។
រស់បានល្អគាប់ជាមនុស្សពិត
ចិត្តបាបទុច្ចរិតវៀរអោយផុត ។

សុច្ចរិតកាន់ខ្ជាប់ កុំទុញទាល់
សំដីជាអាទិ៍ តិតអោយម៉ត់
បានរស់ព្រោះមានការស្រេកឃ្លាន
ចង់រស់ចង់បានសុខមេត្រី

បានរស់ត្រូវស្គាល់ក្ដីបរិសុទ្ធ
ផ្អែមជូរ ឬចត់មុននឹងស្ដី ។
រស់កើតមកមាន មនុស្សសត្វក្ដី
លប់លើសលោកិយជាចំណង់ ។

បាប បុណ្យ គុណទោស រស់ត្រូវមាន
ព្រះធម៌ជាផ្លូវ កុំបោះបង់

ចំណេះជាយាន នាំផ្ចិតផ្ចង់
ផ្លូវត្រង់នាំត្រង់ ណាអ្នករស់ ៕

លោក ឆេង ឆែន

អគ្គលេខាធិការនៃគណៈកម្មាធិការ ស.ប.ស.ខ. ខេត្ត
និងជាអនុប្រធានការិ.យុវជន
នៃមន្ទីរអ.យ.ក. ខេត្តកំពង់ឆ្នាំង

"May you live all the days of your life"

"សូមអោយអ្នកមានជីវិតរស់នៅគ្រប់ថ្ងៃទាំងអស់នៃជីវិតរបស់អ្នក"

*Jonathan Swift*
អ្នកប្រាជ្ញអង់គ្លេស ១៦៦៧-១៧៤៥

មានន័យថាគ្រប់ពេលវេលាដែលយើងមានជីវិតរស់នៅនោះ សូមអោយយើងរស់នៅដូចជាមនុស្សដែលមានជីវិត គឺរស់នៅដោយប្រើពេលវេលាអោយជាប្រយោជន៍ មិនមែនរស់នៅដូចមនុស្សស្លាប់ គឺមានជីវិតរស់ដោយមិនមានប្រយោជន៍អ្វីនោះទេ

# តម្រងមិនជ្រាបទឹក

ខ្ញុំសូមចូលរួមសាកល្បងដោះស្រាយការធ្វើពិសោធន៍ដែលយកស្បៃមកធ្វើតំរប អាចបង្ហូរទឹកចូលបាន តែមិនអាចចាក់ចេញវិញបាន ដែលមានក្នុងអត្ថបទ "តំរបមិនជ្រាបទឹក" ទស្សនាវដ្ដីគ្រូបង្រៀនលេខ ២៧ ត្រង់ទំព័រ ៤៣។

**វិធីធ្វើពិសោធន៍ឡើងវិញ:**

១- យកស្បៃពីរជាន់ទៅពាសគ្របមាត់ដបមួយ (ដបមាត់ធំ ដូចជាដបទឹកដោះគោកូនង៉ែតជាដើម) រួចចងអោយជាប់នឹងកដបដោយខ្សែកៅស៊ូ។

២- បង្ហូរទឹកចូលដបនោះ ទឹកហូរចូលកាត់តាមស្បៃតំរបគ្មានទើសទាល់អ្វីឡើយ។

៣- នៅពេលផ្កាប់មាត់ដបចុះក្រោម ទឹកក្នុងដបពុំហូរ ឬជ្រាបចេញវិញទេ ហាក់ដូចជាមានតំរបមួយជិតល្អដូច្នោះដែរ។

ចំពោះពិសោធន៍នេះ លោក Alain Schuhl បានបកស្រាយថា :

"អ្វីទាំងអស់អាចពន្យល់បាន

ទឹកហូរចូលទៅក្នុងដប គ្មានការលំបាកអ្វីឡើយ តែមិនអាចចេញវិញបាន។ តាមពិត ស្បៃនៅតែជាស្បៃដដែល ទោះណាជាផ្កាប់ ឬផ្ងារដបក៏ដោយ។ ដូច្នេះ គឺទឹកទេដែលធ្វើអោយមានសភាពខុសប្លែកគ្នា។ ពេលហូរចេញពីក្បាលម៉ាស៊ីន ទឹកមានសម្ពាធមួយសមល្មមអាចហូរឆ្លងកាត់ស្បៃចូលទៅក្នុងដបបានដោយស្រួល។ តែដើម្បីចេញវិញ ទឹកគ្រាន់តែដក់លើស្បៃដោយមានកំលាំងប្រទាញស្មើនឹងទំងន់របស់វាប៉ុណ្ណោះ។

សាកល្បងធ្វើការពិសោធនេះជាថ្មីម្តងទៀត ដោយបញ្ចូលទឹកក្នុងដបត្រឹមតែ ២ឬ៣ស.ម. បានហើយ។ នៅពេលផ្កាប់ដប ហើយក្រឡុកអោយខ្លាំងៗនោះ ទឹកអាចចាក់ចេញតាមកំលាំងជំរុញនីមួយៗបាន។

ដូច្នេះ មិនមែនមានន័យថា ស្បៃដែលមានរន្ធសុសសាច់ នៅពេលខ្លះអាចជិតមិនអោយទឹកជ្រាបឆ្លងកាត់បានដូចជាផ្នុកយ៉ាងល្អនោះឡើយ។ ហេតុការណ៍នេះ គេហៅថា "អាយតភាពផ្ទៃក្រៅ"។ ចូរអ្នកដាក់ដបនៅកន្លែងណាមួយ រួចបន្តក់ទឹកមួយតំណក់ដោយថ្នមៗទៅលើស្បៃដដែលនោះ។ ពេលនោះតំណក់ទឹកមិនឆ្លងកាត់ស្បៃទេ (រូបទី១)។ ដើម្បីឆ្លងកាត់តម្រងតំណក់ទឹកត្រូវប្តូររូបរាង។ ដោយសារក្រឡាស្បៃញឹក ទឹកដែលចេញតាមចន្លោះទៅក្រោម មានកាំនៃភាពកោងកាន់តែតូច (រូបទី២)។ ត្រង់នេះហើយដែលអាយតភាពផ្ទៃក្រៅកកើតឡើង ។ល។ និង ។ល។"



១_កំលាំងកកើតដោយអាយតភាពផ្ទៃក្រៅ



២_កាំនៃភាពកោង

ការបកស្រាយរបស់លោក Alain Schuhl និយាយតែពី "អាយតភាពផ្ទៃក្រៅ" ពុំមានលើកពីហេតុផលផ្សេងទៀតទេ។

ឥឡូវ ខ្ញុំសុំបង្ហាញនូវពិសោធន៍បែបនេះជាបន្តទៀត ដោយយកបំពង់កែវ (ឬបំពង់ទុយោបឺតភេសជ្ជៈ ឬសំបកប៊ិច) ជ្រលក់ទៅក្នុងទឹក ក្នុងកំរិតមួយ(រូប ក)។ រួចយកម្រាមដៃបិទចុងខាងលើអោយជិត ហើយដកចេញមកវិញ។ ទឹកដែលស្ថិតក្នុងបំពង់នោះ ពុំស្រក់ចេញវិញទេ ទោះបីវន្ធបំពង់ធំជាងវន្ធស្បៃពិសោធខាងលើក៏ដោយ (រូប ខ)។ តែនៅពេល ដកម្រាមដៃចេញ ទឹកនឹងហូរចេញអស់ពីបំពង់(រូប គ)។ ខ្ញុំយល់ថា បើដបពិសោធន៍ខាងលើមានវន្ធនៅបាតដែលខ្យល់អាចចូលបាន នោះទឹកពិតជាពុំនៅ "ដក់" លើស្បៃទៀតឡើយ។




ពិសោធន៍ខាងលើនេះបញ្ជាក់ថា ទឹកពុំចំណុះតែទៅលើ "អាយតភាពផ្ទៃក្រៅ" ប៉ុណ្ណោះទេ។
សូមលោកគ្រូ អ្នកគ្រូ ពិសេសសាស្ត្រាចារ្យរូបវិទ្យា មេត្តាជួយបកស្រាយ៕

លោក យស់ អ៊ាង

"មានតែជីវិតដែលខិតខំធ្វើការងារប៉ុណ្ណោះ
ដែលអាចនឹងរំងាប់កិលេសតណ្ហាទាំងឡាយបាន"

**"Il n'y a que la vie laborieuse qui puisse amortir les passions"**

*Vovenarque*

អ្នកប្រាជ្ញបារាំង

# ល្បែងគណិតពិសេស (តចប់)

## ៦-គ្រាប់ឃ្លីនៅក្នុងចាន

មិត្តរបស់អ្នកបានដកយកគ្រាប់ឃ្លីមួយចំនួនពីក្នុងចាន មកក្តាប់ក្នុងដៃ ដោយអ្នកពុំបានដឹងឡើយ។ បន្ទាប់ពីធ្វើលេខទិញខ្លះមក អ្នកអាចទាយបាននូវចំនួនគ្រាប់ឃ្លីដែលមិត្តរបស់អ្នកកំពុងក្តាប់ក្នុងដៃ។

**សំភារៈ**

- គ្រាប់ឃ្លី ២០គ្រាប់
- ចានមួយ (សំរាប់ដាក់ឃ្លី)

| របៀបលេង | ឧទាហរណ៍ |
|---|---|
| ១-យកចាន ផ្ទុកគ្រាប់ឃ្លី ២០គ្រាប់ដាក់លើតុ ហើយបែរខ្នងមករកមិត្តរបស់អ្នក។ ប្រាប់វាអោយដកយក គ្រាប់ឃ្លីពី១ទៅ៩គ្រាប់ទុកក្នុងហោប៉ៅអាវរបស់វា។ | ឧទាហរណ៍ : មិត្តរបស់អ្នកដកគ្រាប់ឃ្លី ៧គ្រាប់ទុកក្នុងហោប៉ៅ។ |
| ២-ប្រាប់វាអោយរាប់គ្រាប់ឃ្លីដែលសល់នៅក្នុងចាន(រាប់ស្ងាត់ៗ)។ | ២០ - ៧ = ១៣ |
| ៣-អោយវាបូកតួលេខគ្រាប់ឃ្លីនៅសល់។ | ១៣ → ១ + ៣ = ៤ |
| ៤-ប្រាប់វាអោយដកចំនួនគ្រាប់ឃ្លីតាមលេខគណនាឃើញក្នុងជំហាន ៣ ពីចានទុកក្នុងហោប៉ៅអាវរបស់វា ជាមួយគ្រាប់ឃ្លីដែលវាទុកក្នុងហោប៉ៅក្នុងជំហានទី១មុន។ | មិត្តរបស់អ្នកដកគ្រាប់ឃ្លី៤គ្រាប់ទុកក្នុងហោប៉ៅ។ |
| ៥-ប្រាប់វាអោយដកយកគ្រាប់ឃ្លីមួយចំនួនពីក្នុងចានក្តាប់(លាក់) ក្នុងដៃ (ប៉ុន្មានក៏បាន)។ | វាដកឃ្លី៦គ្រាប់ក្តាប់ក្នុងដៃ |
| ៦-អ្នកបែរមុខត្រឡប់មកវិញ ដោយចាប់យកគ្រាប់ឃ្លី១គ្រាប់ដែលសល់ក្នុងចានមកដាក់លើថ្ងាស់ ធ្វើហាក់ដូចជាកំពុងសញ្ជឹងគិត២ ឬ៣វិនាទី។ តមកអ្នកទាយគ្រាប់ឃ្លីដែលមិត្តរបស់អ្នកក្តាប់ក្នុងដៃ។ | គ្រាប់ឃ្លីដែលមិត្តរបស់អ្នកក្តាប់មានចំនួន៦គ្រាប់។ |

* នៅពេលបែរមុខត្រឡប់មកវិញ អ្នកត្រូវរាប់ស្ងាត់ៗនូវចំនួនគ្រាប់ឃ្លីសល់ក្នុងចាន (ក្នុងសកម្មភាពល្បែងជាឧទាហរណ៍ខាងលើនេះ ក្រោយពីចប់ជំហានទី៥ គ្រាប់ឃ្លីនៅសល់ក្នុងចានមាន៣គ្រាប់)។ អ្នកគ្រាន់តែដកគ្រាប់ឃ្លីនៅសល់នោះពី៩ ផលដកនេះ គឺស្មើនឹងគ្រាប់ឃ្លីដែលមិត្តរបស់អ្នកក្តាប់ក្នុងដៃ : ៩ - ៣ = ៦។

អ្នកក៏អាចដឹងផងដែរនូវគ្រាប់ឃ្លីដែលមិត្តរបស់អ្នកទុកក្នុងហោប៉ៅ គឺ "១១គ្រាប់ជានិច្ច"។

**សំគាល់:**

- ក្នុងជំហានទី ៦ ប្រសិនបើគ្មានគ្រាប់ឃ្លីសល់ក្នុងចានទេ អ្នកត្រូវយកចានទោះមកដាក់នឹងថ្ងាសរបស់អ្នក។ ក្នុងករណីនេះ គ្រាប់ឃ្លីនៅក្នុងដៃ គឺ : ៩ - ០ = ៩ គ្រាប់។
- ប្រសិនបើមិត្តរបស់អ្នកមិនអាចក្ដាប់គ្រាប់ឃ្លីតាមវាចង់បានអស់ទេ អោយវារកពែងមួយទៀត ឬចង់មួយដាក់គ្រាប់ឃ្លីនេះជំនួសវិញ លៃយ៉ាងណាកុំអោយអ្នកដឹងចំនួនគ្រាប់ឃ្លីនោះ។
- ត្រូវចំណាំថា អ្នកទាយក្នុងល្បែងនេះ ដឹងបានតែចំនួនគ្រាប់ឃ្លីសរុប ២០គ្រាប់ និងគ្រាប់ឃ្លីសល់ក្នុងចានក្រោយចប់ជំហានទី ៥ប៉ុណ្ណោះ។ ការយកគ្រាប់ឃ្លី១គ្រាប់ពីក្នុងចានមកដាក់លើថ្ងាស គឺជាឱកាសដើម្បីរាប់គ្រាប់ឃ្លីនៅសល់។

## ៧-ជើងឯកលេខ ៧

អ្នកគឺជាជើងឯកលេខ ៧ ដោយសារថា ទោះជាមិត្តរបស់អ្នកជ្រើសយកលេខប៉ុន្មានក៏ដោយ បន្ទាប់ពីមិត្តរបស់អ្នកបានធ្វើប្រមាណវិធីទាំង ៤រួច លទ្ធផលចុងក្រោយនៅតែលេខ ៧ ជានិច្ច។

**សំភារ:**

-ម៉ាស៊ីនគិតលេខ ១គ្រឿង

**របៀបលេង**

ហុចម៉ាស៊ីនគិតលេខអោយមិត្តរបស់អ្នក ហើយប្រាប់វាអោយ÷

| | |
|---|---|
| ១-បញ្ចូលលេខណាមួយតាមដែលវាអាចចាំបាន (លេខនេះ ត្រូវតិចជាង ៨ ខ្ទង់) ក្នុងម៉ាស៊ីនគិតលេខ | ឧទាហរណ៍ : ១២៣ |
| ២-គុណលេខនោះនឹង ២ | ១២៣ x ២ = ២៤៦ |
| ៣-ដកលទ្ធផលនឹង ១៦ | ២៤៦ - ១៦ = ២៣០ |
| ៤-គុណលទ្ធផលនឹង ៤ | ២៣០ x ៤ = ៩២០ |
| ៥-ចែកផលគុណនឹង ៨ | ៩២០ ÷ ៨ = ១១៥ |
| ៦-ថែម ១៥ លើផលចែក | ១១៥ + ១៥ = ១៣០ |
| ៧-ដកលេខដែលបានជ្រើសរើសដំបូង (ឧ : ១២៣) ពីផលបូក | ១៣០ -១២៣ = ៧ |

សំគាល់ : ក្នុងជំហានទី ៦ បើគេថែមលេខផ្សេងទៀត (ក្រៅពី ១៥) គេនឹងបានលទ្ធផលក្នុងជំហាន៧ ជាលេខផ្សេងពី ៧ ជានិច្ចដែរ។ ឧទាហរណ៍ : ១១៥ + ១៨ = ១៣៣, ១៣៣ - ១២៣ = ១០។ កាលបើដូចនេះ ចំណងជើងល្បែងនេះ ត្រូវដូរជា "ជើងឯកលេខ១០"វិញ។

## ៨-ខ្ញុំមានម្រាមដៃ ១១ (កំប្លែងគណិតវិទ្យា)

មិត្តរបស់អ្នកនឹងអស់សំណើច រួចហាក់ដូចជាវង្វេងវង្វាន់នៅពេលដែលអ្នកអះអាងថា អ្នកមានម្រាមដៃ ១១។

របៀបលេង:

ចូរលើកដៃទាំងពីររបស់អ្នកនៅមុខមិត្តរបស់អ្នក រួចសួរវាថា : "តើខ្ញុំមានម្រាមដៃប៉ុន្មាន?"

មិត្តរបស់អ្នកមុខជាឆ្លើយថា : មានម្រាមដៃ ១០។

អ្នកតបថា : ១០មែនឬ? សូមពិនិត្យមើលអោយច្បាស់! បន្ទាប់មក អ្នករាប់ម្រាមដៃស្ដាំបញ្ច្រាសមកវិញ រួចបូកនឹងម្រាមខាងឆ្វេង៥។ លទ្ធផលគឺ ១១។




១០, ៩, ៨, ៧, ៦ថែមម្រាមដៃឆ្វេង ៥ទៀត ត្រូវជា ១១!

សូមពិចារណា! ប្រសិនបើមានករណីដូចក្នុង "កំប្លែងគណិតវិទ្យា"នេះ តើលោកគ្រូ អ្នកគ្រូនឹងពន្យល់ប្រាប់សិស្សដូចម្ដេច? ។


**លោក ខៀវ សិន**

**នាយកប.ថ.ស ភូមិវាល**

**ស្រុកជើងព្រៃ ខេត្តកំពង់ចាម**


| ការកែតម្រូវទស្សនាវដ្ដីលេខ២៧ | | | | |
|---|---|---|---|---|
| ល.រ | ទំព័រ | បន្ទាត់ | ពាក្យខុស | ពាក្យត្រូវ |
| ១ | ៣៩ | ១១ | ពូវ អ៊ុយ | ពូវ អ៊ុម |
| ២ | ក្រុបក្រោយ | ចុងបង្អស់ | ដង្ហែរ | ដង្ហែ |

# មង្គលនៃស្ត្រី

ហូរ សិរី

សង្គមខ្មែរយើងចាត់ទុកថា ស្ត្រីដែលកើតមកហើយតែងមានពន្លកនៃអធិបតីភាព និងមង្គលភាពជាប់មកជាមួយជាស្រេច។ តែលក្ខណៈសម្បត្តិទាំងពីរនេះ នឹងអាចរីកចំរើនទៅបាន ទាល់តែស្ត្រីនោះខិតខំដោយខ្លួនឯងផ្ទាល់ និងដោយមានម្ដាយឪពុក បងប្អូនញាតិមិត្តរួមចំណែកអប់រំចរិយាសម្បត្តិ កិរិយាមារយាទ អាកប្បកិរិយាឥរិយាបថអោយបានសមរម្យល្អ ប្រសើរតាំងពីតូចរៀងរហូតដល់ចាស់ផង។ លក្ខណៈសំខាន់ៗដែលស្ត្រីត្រូវមានគឺ ÷

- កូនល្អ មិត្តល្អ សិស្សល្អ
- ប្រពន្ធល្អ អ្នកជិតខាងល្អ អ្នកគ្រប់គ្រងល្អ
- ម្ដាយល្អ អ្នកអប់រំល្អ ទីប្រឹក្សាល្អ។

ដើម្បីសំរេចបំណងខាងលើនេះ បុព្វបុរសខ្មែរយើងបានចងក្រងច្បាប់ឧបទេស និងរឿងតំណាលមួយចំនួនសំរាប់អប់រំទូន្មានដល់កូនស្រីខ្មែរគ្រប់រូបអោយស្ថិតនៅក្នុងគុណសម្បត្តិទាំងពីរខាងលើជានិច្ច។ ចំពោះច្បាប់ឧបទេស យើងឃើញមានជាអាទិ៍ គឺច្បាប់ស្រីរបស់ព្រះបាទអង្គឌួង ច្បាប់ស្រីរបស់បណ្ឌិតម៉ឺនមៃ និងសុភាសិត ច្បាប់ស្រីរបស់ឧកញ៉ាសុត្តន្តប្រីជាឥន្ទ។ ចំណែករឿងតំណាលវិញមានដូចជា រឿងស្រីពិត សម្លាញ់ពីរនាក់ បុរសកំជិលមានប្រពន្ធគ្រប់លក្ខណ៍ជាដើម។ សូមលើកយកច្បាប់ស្រីដែលជាស្នាព្រះហស្តរបស់ព្រះបាទអង្គឌួងមកបង្ហាញជូនខាងក្រោមនេះ ÷



ក្នុងច្បាប់ស្រីនេះ អ្នកនិពន្ធបានបង្ហាញអោយឃើញច្បាស់លក្ខណៈជាមង្គលនៃស្ត្រី។

១_មង្គលនៃស្ត្រីប្រាំបីប្រការ

១-ស្រីជា មានឫកពាស្រគត់ស្រគំ សំដីពិរោះពិសារ
២-ស្រីត្រង់ ចេះថែរក្សាទ្រព្យសម្បត្តិ មិនមានប្រមាទ
៣-ស្រីប្រាជ្ញ ចេះអធ្យាស្រ័យ ស្រស់ស្រាយរាក់ទាក់
៤-ស្រីស្លូត ស្ដាប់បង្គាប់តាមប្ដី
៥-ស្រីគាប់ ឧស្សាហ៍ព្យាយាម សន្សំសំចៃ
៦-ស្រីស្អាត ចេះរៀបចំទុកដាក់ ផ្គាប់ចិត្តប្ដី
៧-ស្រីស្មោះ ស្វាមីភក្ដិចំពោះតែប្ដីមួយ
៨-ស្រីស្មើ មានខន្តី ស៊ូទ្រាំស្លាប់រស់ជាមួយប្ដី ។

២_មង្គលនៃភរិយា

- មាតាភរិយា ជាភរិយាទុកដូចម្ដាយចេះផ្គត់ផ្គង់ ឃើញលអាណិតអាសូរប្ដីដូចជាកូន ហើយរក្សាភក្ដីភាពចំពោះប្ដីជានិច្ច ។ ភរិយាប្រភេទនេះ មានចិត្តចង់អោយប្ដីមានចំណេះវិជ្ជា យសសក្តិថ្កើងរុងរឿង មានទ្រព្យសម្បត្តិ ស្លៀកពាក់ស្អាតបាត មានចំណីអាហារគ្រប់សព្វ មានសុខភាពល្អ នាងចេះថែទាំថ្នាំសង្កូវជាប្រចាំ ។
- ភគិនីភរិយា ជាភរិយាទុកដូចជាប្អូនស្រឡាញ់បង ទទួលដំបូន្មានពីប្ដីដូចទទួលដំបូន្មានពីបងដូចនោះដែរ ។ នាងប្ដូរផ្ដាច់តែជាមួយប្ដី យកប្ដី ជាទីពំនាក់ឥតបែកបែរឡើយ ។
- សខាភរិយា ជាភរិយាទុកដូចមិត្តសំឡាញ់ ចង់តែជួបគ្នាជានិច្ច ពេលបាត់មុខប្ដី នាងនឹករលឹក ពេលប្ដីមកដល់នាងសប្បាយរីករាយស្រស់ស្រាយ ។
- ទាសីភរិយា ជាភរិយាប្រៀបដូចអ្នកបំរើ ខិតខំខ្វល់ខ្វាយបំរើប្ដី ស្ដាប់បង្គាប់ប្ដីជានិច្ច ខ្លាចប្ដី គោរពប្ដី ។ (ចំពោះចំណុចនេះ បច្ចុប្បន្នមានការកែប្រែផ្នត់សង្គមខ្មែរ ដោយអប់រំការបញ្ជ្រាបយេនឌ័រ អោយមានសមភាពរវាងបុរស និងស្ត្រី ចៀសវាងការរំលោភសិទ្ធិស្ត្រីដោយប្រើអំពើហិង្សា) ។

ក្នុងច្បាប់ស្រីរបស់ព្រះបាទអង្គឌួង ព្រះអង្គបានទូន្មានដល់ស្ត្រីអោយរក្សាភាពអធិបតី និងជាមង្គលរបស់ខ្លួនអោយខ្ជាប់ កុំអោយបាត់បង់ ។ ព្រះអង្គបានបង្ហាញលក្ខណៈជាមង្គលដែលនាំទៅដល់សុខ សុភមង្គលក្នុងគ្រួសារ ហើយស្ត្រីរក្សាបានលក្ខណៈល្អក្នុងសង្គមរបស់ខ្លួន ។

ទោះបីជាសង្គមខ្មែរយើងមានការអភិវឌ្ឍពីជំនាន់មួយទៅជំនាន់មួយក្ដី ក៏ខ្លឹមសារច្បាប់ស្រីរបស់ព្រះបាទអង្គឌួងមួយចំនួនធំនៅតែមានតម្លៃជាប់នឹងប្រពៃណីទំនៀមទំលាប់ខ្មែរយើងរហូតមកដល់សព្វថ្ងៃ ។

(នៅមានត)

ឯកសារពិគ្រោះ : ព្រលឹងមាតាធិបតេយ្យក្នុងសង្គមខ្មែរ : ងួន ញិល



# តើលោកគ្រូ អ្នកគ្រូ ដឹងទេ...?

## ផែនដីដែលយើងរស់នៅ

+ មានអាយុកាលគិតតាំងពីកំណើតរហូតមកដល់បច្ចុប្បន្នកាល មានប្រមាណបួនពាន់ប្រាំមួយរយលានឆ្នាំហើយ។
+ គឺជាភពតែមួយគត់ ដែលមានស្រទាប់ឋបនីយជីវមណ្ឌលក្នុងចំណោមភពទាំងអស់ ដែលរណបព្រះអាទិត្យ។
+ ស្ថិតនៅឆ្ងាយពីព្រះអាទិត្យ ក្នុងលំដាប់លេខ៣ ក្នុងចំណោមភពរណបទាំង ៩ គិតជាមធ្យមមានចំងាយប្រមាណ១៤៩.៦លានគីឡូម៉ែត្រ។
+ មានរាងជាដុំមូល(ស្វ៊ែរ)សំប៉ែតផ្នែកប៉ូលទាំងពីរបន្តិច។ វិជ្ជមាត្រកាត់តាមអេក្វាទ័រប្រវែង ១២ ៧៥៦ គ.ម។ វិជ្ជមាត្រកាត់តាមប៉ូលប្រវែងតែ ១២ ៧១៣គ.ម។
+ មានម៉ាស់សរុប ៥.៩៨ x ១០$^{២៤}$ គ.ក. និងមានដង់ស៊ីតេមធ្យម៥.៥២។
+ វិលជុំវិញខ្លួនឯងផង (២៤ម៉ោង/១ជុំ) និងធ្វើដំណើរវិលជុំវិញព្រះអាទិត្យផង ១ឆ្នាំបាន១ជុំព្រះអាទិត្យ ក្នុងថេរវេលា៣៦៥ថ្ងៃ ៦ម៉ោង ៩នាទី និង៩.៥វិនាទី។
+ ធ្វើដំណើរវិលជុំវិញព្រះអាទិត្យ តាមតារាវិថីក្នុងល្បឿន : ២៩.៧៩គ.ម. ក្នុងមួយវិនាទី។
+ មានតារាវិថីជារាងមូលពងក្រពើ (មូលទ្រវែងបន្តិច = ellipse) ដែលកន្លះអ័ក្សមធ្យម (axe moyen) ស្មើនឹងមួយឯកតានៃតារាសាស្ត្រ[១]។

(១) ឯកតានៃតារាសាស្ត្រ = unité astronomique សរសេរកាត់ ua ដែលមានប្រវែង ១៤៩ ៦០០ ០០០គ.ម ។

សមាគមបុគ្គលិកសិក្សាខ្មែរ
គណៈកម្មាធិការនាយក
លេខ : ២៣/០៦ គ.ក.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីជូនដំណឹងមរណភាព

តាងនាមសមាគមបុគ្គលិកសិក្សាទាំងមូលគណៈកម្មាធិការនាយកនៃ ស.ប.ស.ខ
សូមសំដែងសេចក្តីសោកស្តាយជាទីបំផុត ចំពោះការបាត់បង់ជីវិតនៃមិត្តយើង និងគ្រួសារ
ហើយសូមចូលរួមរំលែកទុក្ខមរណៈសញ្ញាជាមួយគ្រួសារនៃសពទាំងនោះ

| ល.រ | គោត្តនាម_នាម | អាយុ | ភេទ | មុខតំណែង | អង្គភាពបំពេញការងារ | ថ្ងៃ ខែ ឆ្នាំមរណៈ | មូលហេតុ | លេខប័ណ្ណ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | | | ក. មរណភាពសមាជិក | | | | |
| ១ | សុខ ច័ន្ទម៉ុល | ៥៧ | ស | គ្រូ ម.ទ.ភ | និវត្តជនសាលាគរុកោសល្យ ខេត្តតាកែវ | ៣១-០១-០៦ | រោគាពាធ | ១១៩តក | សពទី៤៧២៨ |
| ២ | គង់ ស៊ីផុល | ៥៦ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.ស សំរោងពន្លៃ-អង្គបុរី-តាកែវ | ២១-០១-០៦ | រោគាពាធ | ៣៦៨៣តក | - ៤៧២៩ |
| ៣ | អ៊ិក សុភាព | ៦១ | ប | គ្រូ ប.ឋ.ស | អង្គតាពៅ-សំរោង-តាកែវ | ១០-០៣-០៦ | រោគាពាធ | ៣០០៤តក | - ៤៧៣០ |
| ៤ | សេង ធន្មី | ៣៦ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.ស ត្រពាំងអណ្តើក-ត្រាំកក់-តាកែវ | ១៦-០២-០៦ | រោគាពាធ | ២៨៥៣តក | - ៤៧៣១ |
| ៥ | កេង ណៃស៊ុម | ៥១ | ស | គ្រូ ប.ឋ.ស | សាលាប.ឋ.ស ស្វាយទាប-ចំការលើ-កំពង់ចាម | ១៧-០១-០៦ | រោគាពាធ | ៩៧៩១កច | - ៤៧៣២ |
| ៦ | ស្វាយ ប៉ា | ៧៦ | ប | គ្រូ ប.ឋ.ស | និវត្តជនសាលាភ្នំប្រុស-កំពង់សៀម-កំពង់ចាម | ០៩-០២-០៦ | រោគាពាធ | ៤៩៩០កច | - ៤៧៣៣ |
| ៧ | កែវ ឈឹន | ៦១ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.ស ព្រែកហូរ-តាខ្មៅ-កណ្តាល | ០៦-០២-០៦ | រោគាពាធ | ៤១២កណ | - ៤៧៣៤ |
| ៨ | ឱ សាឡិប | ៥៧ | ស | គ្រូ ប.ឋ.ស | សុពណ៌-អង្គស្នួល-កណ្តាល | ២៩-០១-០៦ | ខ្យល់គរ | ៤៩២២កណ | - ៤៧៣៥ |
| ៩ | ប៊ុច គីមហេង | ៥៩ | ប | គ្រូ ម.ប.ភ | វិ.សិរីមង្គល-មុខកំពូល-កណ្តាល | ២៤-០១-០៦ | លើសឈាម | ៨៩៧កណ | - ៤៧៣៦ |
| ១០ | ឡុង ឌុយ | ៧៥ | ប | គ្រូ ប.ឋ.ស | និវត្តជនស្រុកស្អាង-កណ្តាល | ០៥-០៣-០៦ | ជរាពាធ | ៨០១០កណ | - ៤៧៣៧ |
| ១១ | រាជ រដ្ឋា | ៤១ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.ស កន្ទ្រាញអក-កំពង់ត្របែក-ព្រៃវែង | ០២-០១-០៦ | ខ្យល់គរ | ១៤៣៧ពវ | - ៤៧៣៨ |
| ១២ | ប្រាជ្ញ វ៉ារិន | ៥៧ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.ស ដូនកឹង-កំចាយមារ-ព្រៃវែង | ១៨-១២-០៥ | ខ្យល់គរ | ២៧៣ពវ | - ៤៧៣៩ |
| ១៣ | ពុធ ស្រ៊ន់ | ៥២ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.ស អង្គរទ្រេត-ព្រៃវែង-ព្រៃវែង | ១៩-០១-០៦ | ខ្យល់គរ | ៣៩៩១ពវ | - ៤៧៤០ |
| ១៤ | សោម ឈឿន | ៥៧ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.សអណ្តូងសាលា-កញ្ជ្រៀច-ព្រៃវែង | ០៤-០១-០៦ | ឆ្កែឆ្កួតខាំ | ៩៥៣ពវ | - ៤៧៤១ |
| ១៥ | អ៊ុំ ប៉ាញ | ៣១ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.ស បឹងដំ-ស៊ីធរកណ្តាល-ព្រៃវែង | ០១-០២-០៦ | រោគាពាធ | ៣៦៩៩ពវ | - ៤៧៤២ |
| ១៦ | ម៉េង លីជ្រាង | ៦២ | ប | គ្រូ ប.ឋ.ស | ការិ.អ.យ.ក. ស្រុកព្រៃវែង-ព្រៃវែង | ១៦-០១-០៦ | គ្រោះថ្នាក់ចរាចរ | ៣៦៩០ពវ | - ៤៧៤៣ |
| ១៧ | រស់ ឃឿន | ៦៥ | ប | គ្រូ ប.ឋ.ស | និវត្តជនសាលាសុពណ៌-កំពង់ត្របែក-ព្រៃវែង | ២៥-១២-០៥ | រោគាពាធ | ១៨១៥ពវ | - ៤៧៤៤ |
| ១៨ | អែម អុន | ៧៣ | ប | គ្រូ ប.ឋ.ស | និវត្តជនស្រុកកំពង់លាវ-ព្រៃវែង | ០១-០២-០៦ | ជរាពាធ | ៧៤២២ពវ | - ៤៧៤៥ |
| ១៩ | ជាប ប៊ូម៉េង | ៣៨ | ប | គ្រូ ម.ប.ភ | មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ព្រៃវែង | ១៨-០២-០៦ | រោគាពាធ | ១០៧ពវ | - ៤៧៤៦ |
| ២០ | ឃ្លោក ធឿន | ៤១ | ប | កម្មករ | វិ.ចាក់-ចាក់-ព្រៃវែង | ២៦-០១-០៦ | រោគាពាធ | ៤២៦០ពវ | - ៤៧៤៧ |
| ២១ | ញ៉ែម សាឡឿន | ៥២ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.ស អ្នកលឿង-ពាមរក៍-ព្រៃវែង | ១៩-០២-០៦ | រោគាពាធ | ៥៣២០ពវ | - ៤៧៤៨ |
| ២២ | បាល់ សាម៉ុន | ៥៩ | ប | គ្រូ ប.ឋ.ស | វិ.ស្វាយអន្ទរ-ព្រៃវែង-ព្រៃវែង | ២៥-០២-០៦ | រោគាពាធ | ៣៧៩២ពវ | - ៤៧៤៩ |
| ២៣ | ភីម ភ័ណ្ឌ | ៥៣ | ប | គ្រូ ប.ឋ.ស | ការិ.កីឡា មន្ទីរអ.យ.ក. ខេត្តព្រៃវែង | ០៩-០៣-០៦ | រោគាពាធ | ១៧១ពវ | - ៤៧៥០ |
| ២៤ | ជីវ ហឿន | ៦៣ | ស | គ្រូ ប.ឋ.ស | និវត្តជនវិ.ច្បារអំពៅ រាជធានីភ្នំពេញ | ២២-០២-០៦ | រោគាពាធ | ២០០០ភព | - ៤៧៥១ |
| ២៥ | តាត ហុក | ៦៣ | ប | គ្រូ ប.ឋ.ស | និវត្តជនសាលាគរុកោសល្យ និងវិក្រឹតការ ក្រុងព្រះសីហនុ | ០៥-១២-០៥ | ទឹកនោមផ្អែម | ២៤២៨សន | - ៤៧៥២ |
| ២៦ | អ៊ុក សំអឿន | ៥៨ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.ស វាលរេញ-ព្រៃនប់-ក្រុងព្រះសីហនុ | ០១-០២-០៦ | វះកាត់ក្រពះ | ២៩៣២សន | - ៤៧៥៣ |
| ២៧ | ទូច តារា | ២៥ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.សអូរត្រជាក់ចិត្ត-ព្រៃនប់-ព្រះសីហនុ | ០២-០៣-០៦ | គ្រោះថ្នាក់ចរាចរ | ៣៨៨៧សន | - ៤៧៥៤ |
| ២៨ | ចែ ប៉េងហេង | ៦០ | ប | គ្រូ ម.ប.ភ | ប្រធានការិ.អ.យ.ក.-ព្រែកប្រសព្វ-ក្រចេះ | ២០-០២-០៦ | រោគាពាធ | ០១៣២ក្រច | - ៤៧៥៥ |
| ២៩ | ប្រាក់ សុខុន | ៣៤ | ប | គ្រូ ម.ប.ភ | សាលាគរុកោសល្យ ខេត្តកំពង់ស្ពឺ | ២៣-០១-០៦ | ក្រិនថ្លើម | ០៨៣កស្ព | - ៤៧៥៦ |
| ៣០ | សាន់ យ៉ាត | ៤៧ | ស | គ្រូ ប.ឋ.ស | សាលាប.ឋ.ស សំរោង-ថ្ពង-កំពង់ស្ពឺ | ២១-០១-០៦ | ក្រិនថ្លើម | ៩២៣កស្ព | - ៤៧៥៧ |
| ៣១ | យិន ឈឹន | ៦១ | ប | គ្រូ ប.ឋ.ស | និវត្តជនសាលាអង្គស្នក-បរសេដ្ឋ-កំពង់ស្ពឺ | ០៩-០៣-០៦ | រោគាពាធ | ២៧៥១កស្ព | - ៤៧៥៨ |
| ៣២ | សំ សេង | ៦១ | ប | គ្រូ ប.ឋ.ស | និវត្តជនសាលាអង្គពោធិ-សំរោងទង-កំពង់ស្ពឺ | ០៨-០៣-០៦ | រោគាពាធ | ២៤៤២កស្ព | - ៤៧៥៩ |
| ៣៣ | ជា ជីម | ៣៩ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.ស ស្រង់-គងពិសី-កំពង់ស្ពឺ | ៣០-០១-០៦ | គ្រោះថ្នាក់ចរាចរ | ៥៣១កស្ព | - ៤៧៦០ |
| ៣៤ | ហង់ សុគន្ធ | ៥១ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.ស ត្រពាំងល្ពាក់-ឱដុង្គ-កំពង់ស្ពឺ | ០៩-០២-០៦ | ចងក | ១៩០៧កស្ព | - ៤៧៦១ |
| ៣៥ | ខ្លូត ប៊ុនសុង | ៣៥ | ប | គ្រូ ប.ឋ.ស | អនុ.ទួលសុភី-សំរោងទង-កំពង់ស្ពឺ | ០១-០៣-០៦ | បេះដូងរីក | ៤០៣៦កស្ព | - ៤៧៦២ |
| ៣៦ | សុខ ណារ៉េត | ៦៤ | ស | គ្រូ ម.ប.ភ | និវត្តជនការិ.អ.យ.ក.-ចំការមន គណៈកម្មាធិការនាយក | ០៧-០២-០៦ | លើសឈាម | ៣០៩១តក | - ៤៧៦៣ |
| ៣៧ | ម៉ុក សារុត | ៦០ | ប | គ្រូ ម.ទ.ភ | នាយកសាលាមធ្យមបច្ចេកទេសមនុស្សធម៌ គណៈកម្មាធិការនាយក | ២៩-០៣-០៦ | ជំងឺថ្លើម | ៥៥១តក | - ៤៧៦៤ |

| ខ. មរណៈភាពក្នុងសមាជិក | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ល.រ | គោត្តនាម_នាម | អាយុ | ភេទ | មុខរបរ | អត្តសញ្ញាណអ្នកទទួលសមាជិក | ថ្ងៃ ខែ ឆ្នាំមរណៈ | មូលហេតុ | លេខបណ្ណ | ផ្សេងៗ |
| ១ | អ៊ុង ញ៉ី | ៥០ | ស | ធ្វើស្រែ | ប្រពន្ធលោកឈឹម សុផល្លី សាលាព្រែក្សាកោះអណ្ដែត-តាកែវ | ៣០-០១-០៦ | រោគាពាធ | ២០៣៩តក | -៣០០៦ |
| ២ | ឈឹម សារឿន | ៥០ | ស | ធ្វើស្រែ | ប្រពន្ធលោកតាំ ទឹម សាលារំលក-អង្គរបុរី-តាកែវ | ០៥-០២-០៦ | រោគាពាធ | ៣៨៣៩តក | - ៣០០៧ |
| ៣ | សួន សាឯម | ៥១ | ស | ធ្វើស្រែ | ប្រពន្ធលោកឈឹម ជុំ សាលាស្លូលខ្ពស់-ព្រៃកប្បាស-តាកែវ | ២២-០២-០៦ | រោគាពាធ | ៤៥២៨តក | - ៣០០៨ |
| ៤ | អ៊ុន ណាត់ | ៤៦ | ស | ធ្វើស្រែ | ប្រពន្ធលោកប៉ែន ស៊ុនលី វិ.សម្ដេចឪ-សំរោង-តាកែវ | ០៨-០៣-០៦ | រោគាពាធ | ៣១០២តក | - ៣០០៩ |
| ៥ | ភាន ខួច | ៦៥ | ស | ធ្វើស្រែ | ប្រពន្ធលោកកែន ណាង និវត្តជនគោក-តាំបែរ-កំពង់ចាម | ១៥-០១-០៦ | រោគាពាធ | ៦១៧៨កច | - ៣០១០ |
| ៦ | ប្រាំ ឡឿន | ៥៧ | ស | កសិករ | ប្រពន្ធលោកនៅ ជួន សាលាយកបាត្រ-កៀនស្វាយ-កណ្ដាល | ០១-០២-០៦ | រោគាពាធ | ៦៩៦៦កណ | - ៣០១១ |
| ៧ | ឡាយ លី | ៣៦ | ប | កសិករ | ប្ដីអ.សជាំន់ ណារី សាលាសន្ទង-ខ្សាច់កណ្ដាល-កណ្ដាល | ១៣-០២-០៦ | ឧស្សាហ៍ | ៣៥៧៤កណ | - ៣០១២ |
| ៨ | យី ឈុនលី | ៤០ | ស | កសិករ | ប្រពន្ធលោកវ៉ាន់ នាត សាលាល្វាស-ល្វាឯម-កណ្ដាល | ២២-០១-០៦ | ឈើសឈាម | ២៧៩៧កណ | - ៣០១៣ |
| ៩ | ប៉ូច គឹមហេង | ៥៩ | ប | កសិករ | ប្ដីអ.ស កុយ សាម៉ុន វិ.សិរីមង្គល-មុខកំពូល-កណ្ដាល | ២៤-០១-០៦ | ឈើសឈាម | ៨៩៨កណ | - ៣០១៤ |
| ១០ | ឌុល សង | ៥០ | ស | កសិករ | ប្រពន្ធលោកប៊ូ អ៊ាប សាលាអង្គរឈ្នាកថ្មី-មេសាង-ព្រៃវែង | ១៥-១២-០៥ | ជំងឺថ្លើម | ៥៧៥០៣រ | - ៣០១៥ |
| ១១ | ឈុំ សុគន់ | ៣៣ | ស | កសិករ | ប្រពន្ធលោកឌុន សាមាន សាលាស្វាយសង្គម-ព្រៃវែង-ព្រៃវែង | ០១-១២-០៥ | គ្រោះថ្នាក់ចរាចរ | ៥២៣៦៣រ | - ៣០១៦ |
| ១២ | ចុន ហ៊ាប | ២៧ | ស | កសិករ | ប្រពន្ធលោកឈុន សុភាព សាលាស្វាយអន្ទរ-ព្រៃវែង-ព្រៃវែង | ៣១-១២-០៥ | រោគាពាធ | ៧៣៤៥៣រ | - ៣០១៧ |
| ១៣ | ខៀវ សារី | ៤៧ | ស | កសិករ | ប្រពន្ធលោកព្រៀម សាខន សាលាត្រពាំងសិការ-បាភ្នំ-ព្រៃវែង | ០៤-០១-០៦ | រោគាពាធ | ៤៣៧៩៣រ | - ៣០១៨ |
| ១៤ | ស៊ឹម យ៉ុល | ៤៨ | ស | កសិករ | ប្រពន្ធលោកសុខ សាវ៉ាន វិ.ជ.ស.រក្សជ័យ-បាភ្នំ-ព្រៃវែង | ២៦-១២-០៥ | រោគាពាធ | ៣៤៦០៣រ | - ៣០១៩ |
| ១៥ | ហ៊ិន ម៉ក់ | ៤៨ | ស | កសិករ | ប្រពន្ធលោកហេង អោគ ការិ.អ.យ.ក.-មេសាង-ព្រៃវែង | ២៧-០១-០៦ | រោគាពាធ | ៥៤៥២៣រ | - ៣០២០ |
| ១៦ | ស៊ិន រិម | ៦១ | ស | កសិករ | ប្រពន្ធលោកព្រុំ វើង សាលាហាបូរ-ព្រៃវែង-ព្រៃវែង | ២៥-០២-០៦ | រោគាពាធ | ៤០៥០៣រ | - ៣០២១ |
| ១៧ | អៀង ប៊ុណ្ណា | ៤១ | ស | កសិករ | ប្រពន្ធលោកប៉ែន សាម៉ុទ្ទី វិ.កំពង់ត្របែក-ព្រៃវែង | ៣០-១២-០៥ | រោគាពាធ | ១៣២៨៣រ | - ៣០២២ |
| ១៨ | សោម ផន | ៥២ | ស | កសិករ | ប្រពន្ធលោកនេត សាវ៉ាន់ សាលាទួលវៀង-កំចាយមារ-ព្រៃវែង | ០៣-០៣-០៦ | រោគាពាធ | ២៧៨០៣រ | - ៣០២៣ |
| ១៩ | ណាវ សារ៉ន | ៥១ | ស | កសិករ | ប្រពន្ធលោកតឹម សុផាត សាលាអ្នកលឿង-ពាមរក៍-ព្រៃវែង | ០៨-០៣-០៦ | រោគាពាធ | ៥៣១៥៣រ | - ៣០២៤ |
| ២០ | ឥង់ ណេង | ៦០ | ស | កសិករ | ប្រពន្ធលោកអន សាមិត្ត និវត្តជនស្រុកបន្ទាយមាស-កំពត | ១៩-០២-០៦ | ឈើសឈាម | ៣៤៥៧កព | - ៣០២៥ |
| ២១ | ឱន គឹមសាន | ៤០ | ស | កសិករ | ប្រពន្ធលោកហ៊ុំ សយ សាលាតាគោក-ប្រាសាទសំបូរ-កំពង់ធំ | ២១-០១-០៦ | រោគាពាធ | ២៤៩៨កធ | - ៣០២៦ |
| ២២ | សៀន រ៉េន | ៥៤ | ស | កសិករ | ប្រពន្ធលោកកែវ កៅ សាលាទំនប់-ប្រាសាទសំបូរ-កំពង់ធំ | ១៩-០២-០៦ | រោគាពាធ | ២៥២១កធ | - ៣០២៧ |
| ២៣ | អ៊ុក វេនី | ៥២ | ស | មេផ្ទះ | ប្រពន្ធលោកពូន សារឿន វិ.ឥន្ទ្រទេវី រាជធានីភ្នំពេញ | ០៨-០៣-០៦ | រោគាពាធ | ២២៩៧ភព | - ៣០២៨ |
| ២៤ | អាយ គីម | ៦៨ | ស | មេផ្ទះ | ប្រពន្ធលោកដៃ សេង សាលាសន្ធរម៉ុក រាជធានីភ្នំពេញ | ០៣-០២-០៦ | ជំងឺបេះដូង | ២៦៧៦ភព | - ៣០២៩ |
| ២៥ | ជួន ម៉ាលីន | ៣៧ | ប | ប្រជាជន | ប្ដីអ.ស ប៉ែន សុភាវត្តី សាលាសំពៅមាស រាជធានីភ្នំពេញ | ២៨-០១-០៦ | គ្រោះថ្នាក់ចរាចរ | ៥៣៧៩ភព | - ៣០៣០ |
| ២៦ | សួង វ៉ាន់ឃេន | ៥០ | ប | ប្រជាជន | ប្ដីអ.ស ឈឹម សូម៉ាលី សាលាភ្នំជូនពេញ រាជធានីភ្នំពេញ | ១៧-០៣-០៦ | គ្រោះថ្នាក់ចរាចរ | ២៩៧៣ភព | - ៣០៣១ |
| ២៧ | ចេង ចំរើន | ៥៩ | ប | កងទ័ពភូមិន្ទ | ប្ដីអ.ស លីម ដានី ការិ.អ.យ.ក.-ឆ្លូង-ក្រចេះ | ២១-០២-០៦ | រោគាពាធ | ១៦៦៤ក្រច | - ៣០៣២ |
| ២៨ | គុយ អ៊ី | ៥៧ | ស | កសិករ | ប្រពន្ធលោកប៊ូ សំអ៊ាន សាលាតាលុស ស្រុក និងខេត្តក្រចេះ | ១០-០៣-០៦ | រោគាពាធ | ១០៥៨ក្រច | - ៣០៣៣ |
| ២៩ | ដួង ម៉ុល | ៥៩ | ស | កសិករ | ប្រពន្ធលោកអ៊ុំ ភោគ សាលាប៉ោយស្នាង-សូទ្រនិគម-សៀមរាប | ១០-០៩-០៥ | រាបេង | ១៣៦០សរ | - ៣០៣៤ |
| ៣០ | ណុក ឃឿម | ៦៣ | ស | កសិករ | ប្រពន្ធលោកស៊ុក ឃិត សាលាជួនខ្ទ-ពួក-សៀមរាប | ២០-០២-០៦ | ឈើសឈាម | ៣១៩៦សរ | - ៣០៣៥ |
| ៣១ | ហែម ផន | ៦១ | ប | ប្រជាជន | ប្ដីអ.ស ឡាយ សុគន្ធារ៉ា សាកលវិ.ភូមិន្ទភ្នំពេញ គណៈកម្មាធិការនាយក | ០៤-០២-០៦ | រោគាពាធ | ១៧៦៧គ.ក | - ៣០៣៦ |
| ៣២ | ជួន គឹមអ៊ាត | ៥៧ | ស | មេផ្ទះ | ប្រពន្ធលោកសួង ព្រៀម និវត្តជន គណៈកម្មាធិការនាយក | ០៤-០៣-០៦ | ជំងឺថ្លើម | ៣២៦៨គ.ក | - ៣០៣៧ |

មេត្តាប្រមូលភាគទានឧបត្ថម្ភសពប្រចាំខែ មេសា ឆ្នាំ ២០០៦ អោយទាន់ពេលវេលា ដើម្បីដោះស្រាយជូនគ្រួសារសព ។

**ចំណាំ:**

ត្រូវបង់ប្រាក់ឧបត្ថម្ភសពសមាជិក.................... ៣៧ នាក់ x ៣០រ = ១១១០ រៀល

សពគូស្រករ................................................ ៣២ នាក់ x ១៥រ = ៤៨០ រៀល

ភាគទានប្រចាំខែ ........................................................ = ១០០ រៀល

ភាគទានសាងសង់ផ្ទះគ្រូបង្រៀន...................................... = ៣០០ រៀល

**សរុប** = ២០០០រៀល

ភ្នំពេញ, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៦

**ជ.គណៈកម្មាធិការនាយក**

**អគ្គលេខាធិការរង**

**ស្វាយ ធិត្យ**

សមាគមបុគ្គលិកសិក្សាខ្មែរ

គណៈកម្មាធិការនាយក

លេខ : ៤៦/០៦ គ.ក.

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីជូនដំណឹងមរណភាព

តាងនាមសមាគមបុគ្គលិកសិក្សាទាំងមូលគណៈកម្មាធិការនាយកនៃ ស.ប.ស.ខ

សូមសំដែងសេចក្តីសោកស្តាយជាទីបំផុត ចំពោះការបាត់បង់ជីវិតនៃមិត្តយើង និងគ្រួសារ

ហើយសូមចូលរួមកាន់ទុក្ខមរណៈសញ្ញាជាមួយគ្រួសារនៃសពទាំងនោះ

| ល.រ | គោត្តនាម-នាម | អាយុ | ភេទ | មុខតំណែង | អង្គភាពបំពេញការងារ | ថ្ងៃ ខែ ឆ្នាំមរណៈ | មូលហេតុ | លេខប័ណ្ណ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| ក. មរណៈភាពសមាជិក | | | | | | | | | |
| ១ | ហ៊ីម ម៉ែត | ៣៦ | ប | គ្រូ ប.ឋ.ស | វិ.សូរគោព៉េង ស្រុកបាកាន ខេត្តពោធិសាត់ | ០៩-១២-០៥ | ជំងឺពុកឆ្អឹង | ២១៦៣ពស | សពទី៤៧៦៥ |
| ២ | តៅ វេងរិន | ៦០ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.ស រលាំងទទឹង ស្រុកកណ្តៀង ខេត្តពោធិសាត់ | ២៨-០១-០៦ | រោគាពាធ | ៨២៦ពស | - ៤៧៦៦ |
| ៣ | ឃួន ថៃ | ៥៤ | ប | គ្រូ ប.ឋ.ស | ស្បា ស្រុកកណ្តៀង ខេត្តពោធិសាត់ | ០២-០១-០៦ | រោគាពាធ | ១១៣៨ពស | - ៤៧៦៧ |
| ៤ | ប៊ុន វណ្ណា | ៥៩ | ស | គ្រូ ប.ឋ.ស | សាលាប.ឋ.ស អង្គបុស្ស ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ | ១១-០៣-០៦ | លើសឈាម | ០៣៣៥បជ | - ៤៧៦៨ |
| ៥ | អ៊ុក សី | ៥០ | ប | កម្មករ | សាលាប.ឋ.សថ្មី ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ | ០៥-០៣-០៦ | ក្អួតឈាម + កន្ត្រាក់ | ២៦៥៦បជ | - ៤៧៦៩ |
| ៦ | រ៉ម ហយ | ៦៤ | ប | គ្រូ ប.ឋ.ស | និវត្តជនសាលារហាល ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ | ០៩-០៣-០៦ | រោគាពាធ | ១៨៩៥បជ | - ៤៧៧០ |
| ៧ | សួត្រ សុខុម | ៤២ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.ស ភូមិស្វាយ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ | ១៩-០៣-០៦ | លើសឈាម | ២៤៨៨បជ | - ៤៧៧១ |
| ៨ | ប្រាក់ បញ្ញាកា | ២៩ | ប | គ្រូ ប.ឋ.ស | ត្រាំខ្នា ស្រុកបាទី ខេត្តតាកែវ | ០៨-០៣-០៦ | រោគាពាធ | ៦៧៦៧តក | - ៤៧៧២ |
| ៩ | ម៉ែត ឈៀង | ៦៦ | ប | គ្រូ ប.ឋ.ស | និវត្តជន ស្រុកត្រាំកក់ ខេត្តតាកែវ | ១២-០៣-០៦ | រោគាពាធ | ៥៥៧១តក | - ៤៧៧៣ |
| ១០ | សួត្រ អេង | ៥៨ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.ស ព្រៃជ្វា ស្រុកត្រាំកក់ ខេត្តតាកែវ | ១៩-០២-០៦ | រោគាពាធ | ២៧៣៩តក | - ៤៧៧៤ |
| ១១ | ហ៊ាប សាមឿន | ៥២ | ស | គ្រូ ប.ឋ.ស | សាលាប.ឋ.មខ្វងក្រពើ ស្រុកចំការលើស៊ូមេមត់ ខេត្តកំពង់ចាម | ១២-០៣-០៦ | មហារីកសួត | ៤០១កច | - ៤៧៧៥ |
| ១២ | រិន ធា | ៣៤ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.ស សំបួរ ស្រុកបាធាយ ខេត្តកំពង់ចាម | ០៨-០៣-០៦ | គ្រោះថ្នាក់ចរាចរ | ៥១៣៦កច | - ៤៧៧៦ |
| ១៣ | ស៊ុម អែម | ៥២ | ប | គ្រូ ម.ប.ភ | វិ.សម្តេចជួន ណាត ស្រុកកំពង់សៀម ខេត្តកំពង់ចាម | ២៨-០៣-០៦ | ខ្យល់គរ | ៣៧៣៣កច | - ៤៧៧៧ |
| ១៤ | ចេង ឡាង | ៦៦ | ប | គ្រូ ប.ឋ.ស | និវត្តជនសាលាតាត្រាវ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម | ២៧-០៣-០៦ | រោគាពាធ | ៩៤០៧កច | - ៤៧៧៨ |
| ១៥ | សោម នាត | ៣៩ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.ស ស្វាយមីង ស្រុកអូររាំងឪ ខេត្តកំពង់ចាម | ២៣-០៣-០៦ | រន្ទះបាញ់ | ៩៦៥កច | - ៤៧៧៩ |
| ១៦ | មាស ឃាម | ៥៦ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.ស ព្រាច ស្រុកបាភ្នំ ខេត្តព្រៃវែង | ០៦-០៣-០៦ | ខ្យល់គរ | ៤៧០៣ពវ | - ៤៧៨០ |
| ១៧ | ឈើម សារ៉ន | ៥០ | ប | គ្រូ ម.ប.ភ | វិ.រស្មីសាមគ្គី ស្រុកពាមជរ ខេត្តព្រៃវែង | ១៨-០៣-០៦ | ខ្យល់គរ | ៣៤៧២ពវ | - ៤៧៨១ |
| ១៨ | ឡាយ ស៊ាត | ៥៤ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.សព្រៃតាម៉ឺន ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង | ៣១-០៣-០៦ | លើសឈាម | ៨២៣ពវ | - ៤៧៨២ |
| ១៩ | ស៊ុម ឡុងឌី | ៥១ | ប | គ្រូ ម.ប.ភ | នាយកអនុវិ.ចតុមុខ រាជធានីភ្នំពេញ | ០៧-០៣-០៦ | លើសឈាម | ៥២៨១ភព | - ៤៧៨៣ |
| ២០ | ឈុន សន | ៦២ | ប | គ្រូ ប.ឋ.ស | និវត្តជនស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង | ០២-០២-០៦ | ស្លាកខ្វិន | ២៨៨៣ស្វរ | - ៤៧៨៤ |
| ២១ | ព្រុំ សន | ៦៤ | ប | គ្រូ ប.ឋ.ស | និវត្តជន ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង | ០៩-០៣-០៦ | លើសឈាម | ២៧៩៣ស្វរ | - ៤៧៨៥ |
| ២២ | អ៊ីវ រ៉េ | ៣៥ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.សាឈើទាល ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង | ១៨-០៣-០៦ | រោគាពាធ | ២៤៩ស្វរ | - ៤៧៨៦ |
| ២៣ | ឃឿ សំបួរ | ៦៩ | ប | គ្រូ ប.ឋ.ស | និវត្តជនស្រុកស្វាយរៀង ខេត្តស្វាយរៀង | ២៥-០៤-០៦ | រោគាពាធ | ៣៦៣១ស្វរ | - ៤៧៨៧ |
| ២៤ | យូ ងួន | ៧២ | ប | គ្រូ ប.ឋ.ស | និវត្តជនស្រុកប្រាសាទបាគង ខេត្តសៀមរាប | ១២-០១-០៦ | រោគាពាធ | ១៦៧៣សរ | - ៤៧៨៨ |
| ២៥ | គង់ អេម៉ឡេន | ៣០ | ស | គ្រូ ប.ឋ.ស | សាលាប.ឋ.សកុមារអង្គរ ខេត្តសៀមរាប | ០១-០១-០៦ | រោគាពាធ | ១៩៧៦សរ | - ៤៧៨៩ |
| ២៦ | ប៊ុណ ច័ន្ទមណី | ៣៣ | ប | គ្រូ ម.ប.ភ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តបាត់ដំបង | ១៨-០២-០៦ | រោគាពាធ | ១៣២៧បប | - ៤៧៩០ |
| ២៧ | ឈី សុធី | ៥២ | ស | គ្រូ ប.ឋ.ស | ស្រុកបាត់ដំបង ខេត្តបាត់ដំបង | ២៤-០២-០៦ | គ្រោះថ្នាក់ចរាចរ | ៨១៤បប | - ៤៧៩១ |
| ២៨ | ចេង ស៊ីទួន | ៤៧ | ស | គ្រូ ប.ឋ.ស | សាលាប.ឋ.សសួសឌី ស្រុកឯកភ្នំ ខេត្តបាត់ដំបង | ១៥-០៣-០៦ | ធ្លាក់ពីលើដើមឈើ | ៤៦៧៦បប | - ៤៧៩២ |
| ២៩ | យ៉ុន ចិន្តា | ៣២ | ប | គ្រូ ម.ប.ភ | អនុវិ.ពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង | ១៩-០៣-០៦ | រលាកស្រោមខួរ | ៦៦៤១បប | - ៤៧៩៣ |
| ៣០ | ឈន វ៉ាង | ៥១ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.សអូរស្រា ស្រុកឯកភ្នំ ខេត្តបាត់ដំបង | ២៣-០៣-០៦ | លើសឈាម | ៤៤៥៦បប | - ៤៧៩៤ |
| ៣១ | ប៉ក់ សុខុន | ៥៩ | ស | គ្រូ ប.ឋ.ស | សាលាកំរងមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង | ២៧-០៣-០៦ | រោគាពាធ | ៤២២៥បប | - ៤៧៩៥ |
| ៣២ | ប្រាក់ សាគុំ | ៦៣ | ប | គ្រូ ប.ឋ.ស | និវត្តជនស្រុកថ្មគោល ខេត្តបាត់ដំបង | ១១-០៤-០៦ | រោគាពាធ | ១៥៩៣បប | - ៤៧៩៦ |
| ៣៣ | យង់ សឿង | ៥៣ | ស | គ្រូ ប.ឋ.ស | សាលាពពាលខែ ស្រុកថ្មគោល ខេត្តបាត់ដំបង | ១២-០៤-០៦ | លើសឈាម | ១៨០២បប | - ៤៧៩៧ |
| ៣៤ | ពេជ ទូច | ៦៥ | ប | គ្រូ ប.ឋ.ស | និវត្តជន ស្រុកថ្មគោល ខេត្តបាត់ដំបង | ១៧-០៤-០៦ | រោគាពាធ | ១៤៦០បប | - ៤៧៩៨ |
| ៣៥ | ញ៉ឹម ហ៊ុន | ៥៣ | ប | គ្រូ ប.ឋ.ស | សាលាប.ឋ.ស អូរដា ស្រុកសំឡូត ខេត្តបាត់ដំបង | ១៧-០៤-០៦ | ជំងឺសួត | ៣៧៨៥បប | - ៤៧៩៩ |
| ៣៦ | រឿន រ៉ាន់ | ៦០ | ប | គ្រូ ប.ឋ.ស | និវត្តជនស្រុកឯកភ្នំ ខេត្តបាត់ដំបង | ២៣-០៤-០៦ | របេង | ៤៣៨៨បប | - ៤៨០០ |
| ៣៧ | មុន សុភី | ៣៥ | ប | គ្រូម.ប.ភ | អនុវិ.ព្រែកនរិន្ទ ស្រុកឯកភ្នំ ខេត្តបាត់ដំបង | ២៤-០៤-០៦ | ក្រិនថ្លើម | ៤៥៨៤បប | - ៤៨០១ |

| ៣៨ | រាជ ម៉ាន់ | ៧១ | ប | កម្មករ | និវត្តជនមន្ទីរអ.យ.ក. គណៈកម្មាធិការនាយក | ១៤-០៤-០៦ | រោគាពាធ | ២០៤៧តក | - ៤៨០២ |
|---|---|---|---|---|---|---|---|---|---|
| | | | | | ១. មរណៈភាពក្នុងក្រុមសមាជិក | | | | |
| ល.រ | គោត្តនាម_នាម | អាយុ | ភេទ | មុខរបរ | អត្តសញ្ញាណពីការរបស់សមាជិក | ថ្ងៃ ខែ ឆ្នាំមរណៈ | មូលហេតុ | លេខប័ណ្ណ | ផ្សេងៗ |
| ១ | អ៊ុម គ្រឹម | ៦៨ | ស | ធ្វើស្រែ | ប្រពន្ធលោកហ៊ូ ភាន សាលាស្បា-កណ្តៀង-ពោធិសាត់ | ១៧-០២-០៦ | រោគាពាធ | | - ៣០៣៨ |
| ២ | ហៀង មឹង | ៥៨ | ប | ធ្វើស្រែ | ប្តីអ.ស ផា សារ៉ាត់ សាលាភ្នំធំ-មង្គលបុរី-បន្ទាយមានជ័យ | ០៣-០៣-០៦ | គាំងបេះដូង | ០៩១៦បជ | - ៣០៣៩ |
| ៣ | ពេក ព្រឿង | ៥១ | ស | ធ្វើស្រែ | ប្រពន្ធលោកឈើន ខៀ និវត្តជន ស្រុកស្វាយចេក-បន្ទាយមានជ័យ | ១០-០១-០៦ | រោគាពាធ | ២៦៤១បជ | - ៣០៤០ |
| ៤ | សុខ យ៉េន | ៥៨ | ស | ធ្វើស្រែ | ប្រពន្ធលោកឡូ គក់ សាលាឆក់ឈើនាង-អង្គស្នួល-កណ្តាល | ១៧-០៣-០៦ | រោគាពាធ | ៥១៣៤កណ | - ៣០៤១ |
| ៥ | ពត ហឿន | ៦១ | ស | ធ្វើស្រែ | ប្រពន្ធលោកអ៊ុយ ស្រួយ និវត្តជនព្រៃកប្បាស-តាកែវ | ១៧-០៣-០៦ | រោគាពាធ | ៤៩៣៩តក | - ៣០៤២ |
| ៦ | សូ សុខាម | ៤៤ | ស | ធ្វើស្រែ | ប្រពន្ធលោកគីម ជោតិ សាលាព្រៃជើង-គិរីវង់-តាកែវ | ២២-០៣-០៦ | រោគាពាធ | ៥៣៧៥តក | - ៣០៤៣ |
| ៧ | គីម សារុន | ៦០ | ស | ធ្វើស្រែ | ប្រពន្ធលោកស្រី ពៅ សាលាអង្គញ-ទ្រាំង-តាកែវ | ២៤-០៣-០៦ | រោគាពាធ | ០៧១៦តក | - ៣០៤៤ |
| ៨ | យឹម ណាត | ៧៥ | ប | ធ្វើស្រែ | ប្តីអ.ស ញ៉ែម ស្រេន និវត្តជនស្រុកទ្រាំង-តាកែវ | ២៧-០៣-០៦ | រោគាពាធ | ០៦៣៥តក | - ៣០៤៥ |
| ៩ | អ៊ុក យឿន | ៦៥ | ស | ធ្វើស្រែ | ប្រពន្ធលោកម៉ុត ពុំ និវត្តជនសាលាអំពិល-ស្រីសន្ធរ-កំពង់ចាម | ០២-០២-០៦ | គាំងបេះដូង | ៧៤៦៩កច | - ៣០៤៦ |
| ១០ | ប៉ែន ធុម | ៦០ | ប | ធ្វើស្រែ | ប្តីអ.សឆេង ផន សាលាខ្នាតអំពិល-ស្រីសន្ធរ-កំពង់ចាម | ២៥-០២-០៦ | រោគាពាធ | ១០២២៩កច | - ៣០៤៧ |
| ១១ | រីន ចា | ៣៤ | ប | គ្រូបង្រៀន | ប្តីអ.ស មិន គីមឃាង សាលាសំបូរ-បាធាយ-កំពង់ចាម | ០៨-០៣-០៦ | គ្រោះថ្នាក់ចរាចរ | ៥១៨០កច | - ៣០៤៨ |
| ១២ | ស៊ុំ ស៊ុនឿន | ៤៦ | ស | កសិករ | ប្រពន្ធលោកឃួន ឡា ការិ.មធ្យម.នៃមន្ទីរអ.យ.ក. កំពង់ចាម | ១៥-០៣-០៦ | រោគាពាធ | ២៧០កច | - ៣០៤៩ |
| ១៣ | ជិន ម៉ាប់ | ៣៧ | ប | កសិករ | ប្តីអ.ស អ៊ុ ស៊ីចាន់លី សាលាមត្តេយ្យព្រៃឈរ-កំពង់ចាម | ០២-០៣-០៦ | គ្រោះថ្នាក់ចរាចរ | ២៩២៣កច | - ៣០៥០ |
| ១៤ | សាយ យ៉ា | ៥២ | ស | កសិករ | ប្រពន្ធលោកហៃម ផុន សាលាអង្គនារាម-ត្បូងឃ្មុំ-កំពង់ចាម | ១០-០៣-០៦ | រោគាពាធ | ៩១៥២កច | - ៣០៥១ |
| ១៥ | រិន សាខន | ៥៤ | ស | កសិករ | ប្រពន្ធលោកសុខ ឡាត់ សាលាទួលព្រះឃ្លាំង-ស្ទឹងត្រង់-កំពង់ចាម | ១៨-០៣-០៦ | លើសឈាម | ១៦៤៣កច | - ៣០៥២ |
| ១៦ | ហៀង សុផុន | ៥០ | ស | កសិករ | ប្រពន្ធលោកស៊ុម ខ្មៅ សាលាអម្ពវ៉ាន-ក្រូចឆ្មារ-កំពង់ចាម | ២៩-០៣-០៦ | រំរ៉ោះ | ២៦៩៦កច | - ៣០៥៣ |
| ១៧ | ឌុល សារុន | ៤៧ | ស | កសិករ | ប្រពន្ធលោកអ៊ិន រិទ្ធី សាលាកំពាន់-មេមត់-កំពង់ចាម | ២០-០២-០៦ | រោគាពាធ | ៣៥១កច | - ៣០៥៤ |
| ១៨ | ស្វាយ បូរិទ្ធី | ៣៦ | ប | វិស្វករសំណង់ | ប្តីអ.សថោង នរីន្ទ វិ.មិត្តភាពខ្មែរ-ជប៉ុន-ព្រះស្តេច-ព្រៃវែង | ១៦-០៣-០៦ | រោគាពាធ | ៧៨៥២ពវ | - ៣០៥៥ |
| ១៩ | ប៊ុន សេងហួរ | ៤៧ | ប | ប្រជាជន | ប្តីអ.សអ៊ុក ស៊ុនលី សាលាវត្តជ័យបូកខ្ពស់ រាជធានីភ្នំពេញ | ២៥-០៣-០៦ | ខ្យល់គរ | ៩៣៧២កព | - ៣០៥៦ |
| ២០ | អ៊ុយ សារឿន | ៤៩ | ស | កសិករ | ប្រពន្ធលោកហៃម តេង វិ.ដងទង់ ស្រុកដងទង់ ខេត្តកំពត | ២២-០៣-០៦ | ជំងឺថ្លើម | ២៥៦៩កព | - ៣០៥៧ |
| ២១ | ព្រុំ សារន់ | ៣៨ | ប | ធ្វើស្រែ | ប្តីអ.សអ៊ុក ភឿង សាលាព្រៃកទប់-ស្វាយជ្រំ-ស្វាយរៀង | ១០-០៣-០៦ | គ្រុនចាញ់ | ១៩១៦ស្វរ | - ៣០៥៨ |
| ២២ | អុក យ៉ា | ៦៦ | ស | មេផ្ទះ | ប្រពន្ធលោកនាង ឈួន និវត្តជនស្រុកចន្ទ្រា-ស្វាយរៀង | ១២-០៩-០៥ | រោគាពាធ | ៨៦៤ស្វរ | - ៣០៥៩ |
| ២៣ | ងួន ភឿន | ៥២ | ស | ធ្វើស្រែ | ប្រពន្ធលោកម៉ៅ មិត្ត សាលាទួលអង្គ-ស្វាយទាប-ស្វាយរៀង | ០៣-០២-០៦ | ជំងឺសួត | ២១៥៥ស្វរ | - ៣០៦០ |
| ២៤ | អ៊ីវ រ៉ា | ៣៥ | ប | គ្រូបង្រៀន | ប្តីអ.សខែក វណ្ណថា សាលាខេត្តស្រុកនិងខេត្តស្វាយរៀង | ១៨-០៣-០៦ | រោគាពាធ | ២៦៥ស្វរ | - ៣០៦១ |
| ២៥ | ពៀក នាង | ៥៨ | ស | ធ្វើស្រែ | ប្រពន្ធលោកប៉ែន យុក និវត្តជនស្រុកស្វាយជ្រំ-ស្វាយរៀង | ១០-០៤-០៦ | រោគាពាធ | ៤០៣ស្វរ | - ៣០៦២ |
| ២៦ | ពាន់ មូរ៉ាម | ៤៩ | ស | ធ្វើស្រែ | ប្រពន្ធលោកឌីប ប្ញុណា សាលាស្រិត-ប្រាសាទបាគង-សៀមរាប | ១៥-១២-០៥ | រលាកស្រោមខួរ | ១៦៤១សរ | - ៣០៦៣ |
| ២៧ | ឈឿន សារុន | ៥៤ | ប | បើកបររថយន្ត | ប្តីអ.ស លាយ ភារី ស្ទក្រាម ស្រុកនិងខេត្តសៀមរាប | ០៤-០៣-០៦ | ទាចទឹក | ៦៤៧សរ | - ៣០៦៤ |
| ២៨ | ឈួន នុយ | ៧៧ | ស | ធ្វើស្រែ | ប្រពន្ធលោកឃែម ស៊ត់ សាលាសណ្តាន់-អង្គរធំ-សៀមរាប | ១៥-០៩-០៥ | រោគាពាធ | ១៨០៥សរ | - ៣០៦៥ |
| ២៩ | ព្រុំ កាន់ | ៤៨ | ស | ធ្វើស្រែ | ប្រពន្ធលោកខេត ក្រិច សាលាស្រែសមុទ្រ-ក្រវ៉ាន់-សៀមរាប | ២៣-០១-០៦ | រោគាពាធ | ៣៥៥៤សរ | - ៣០៦៦ |
| ៣០ | រាជ ម៉ាន់ | ៧១ | ប | កម្មករ | ប្តីអ.ស. ទៅ យ៉ាន និវត្តជនគណៈកម្មាធិការនាយក | ១៤-០៤-០៦ | រោគាពាធ | ២០៤៨ | - ៣០៦៧ |

មេត្តាប្រមូលភាគទានឧបត្ថម្ភសពប្រចាំខែ ឧសភា ឆ្នាំ ២០០៦ អោយទាន់ពេលវេលា ដើម្បីដោះស្រាយជូនគ្រួសារសព ។

**ចំណាំ:**

ត្រូវបង់ប្រាក់ឧបត្ថម្ភសពសមាជិក.................... ៣៨ x ៣០៛ = ១១៤០ រៀល

សពក្នុងស្រុក........................................ ៣០ x ១៥៛ = ៤៥០ រៀល

ភាគទានប្រចាំខែ ............................................. = ១០០ រៀល

ភាគទានសាងសង់ផ្ទះគ្រូបង្រៀន.............................. = ៣០០ រៀល

**សរុប** = ២០០០រៀល

ភ្នំពេញ, ថ្ងៃទី ០៨ ខែឧសភា ឆ្នាំ ២០០៦

**ជ.គណៈកម្មាធិការនាយក**

**អគ្គលេខាធិការរង**

**ស្វាយ ពិន្ទុ**

សមាគមបុគ្គលិកសិក្សាខ្មែរ
គណៈកម្មាធិការនាយក
លេខ : ៤៩/០៦ គ.ក.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## សេចក្តីជូនដំណឹងមរណភាព

តាងនាមសមាគមបុគ្គលិកសិក្សាទាំងមូលគណៈកម្មាធិការនាយកនៃ ស.ប.ស.ខ
សូមសំដែងសេចក្តីសោកស្តាយជាទីបំផុត ចំពោះការបាត់បង់ជីវិតនៃមិត្តយើង និងគ្រួសារ
ហើយសូមចូលរួមការទុក្ខមរណៈសញ្ញាជាមួយគ្រួសារនៃសពទាំងនោះ

| ល.រ | គោត្តនាម-នាម | អាយុ | ភេទ | មុខតំណែង | អង្គភាពបំរើការ | ថ្ងៃ ខែ ឆ្នាំមរណៈ | មូលហេតុ | លេខសំគាល់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| ក. មរណៈភាពសមាជិក | | | | | | | | | |
| ១ | ខៀវ ខាំស៊ី | ៧១ | ប | គ្រូ ប.បំ.ស | និវត្តជនសាលាស្តៅ ស្រុកសេសាន ខេត្តស្ទឹងត្រែង | ២៦-០៤-០៦ | រោគាពាធ | ២៤៦ សត | សពទី៤៨០៣ |
| ២ | ម៉ម ទូច | ៦៨ | ប | កម្មករ | និវត្តជន មន្ទីរអ.យ.ក. ខេត្តស្ទឹងត្រែង | ២១-០៤-០៦ | រោគាពាធ | ០៣៧សត | - ៤៨០៤ |
| ៣ | កែ ច័ន្ទរ៉ាវី | ៤៥ | ប | គ្រូ ប.បំ.ស | ឈើទៅ ស្រុកកោះធំ ខេត្តកណ្តាល | ០១-០៤-០៦ | រោគាពាធ | ៧៣៤ កណ | - ៤៨០៥ |
| ៤ | កែ យី | ៤០ | ប | គ្រូ ប.បំ.ស | សាលាប.បំ.ស កាកាំ ស្រុកពួក ខេត្តសៀមរាប | ២៦-០៤-០៦ | ថ្លើមខូច | ៣២៣៦សរ | - ៤៨០៦ |
| ៥ | អៀង ហុកឌី | ៥០ | ប | គ្រូ ប.បំ.ស | សាលាប.បំ.ស សំបូរ ស្រុកបាធាយ ខេត្តកំពង់ចាម | ១១-០៤-០៦ | ជំងឺថ្លើម | ៣១៥១កច | - ៤៨០៧ |
| ៦ | សួស វ៉ាត | ៦០ | ប | គ្រូ ប.បំ.ស | សាលាប.បំ.ស ភូមិកណ្តោង ស្រុកឆ្លូង ខេត្តក្រចេះ | ១១-០៥-០៦ | រោគាពាធ | ១៦៦៦ក្រច | - ៤៨០៨ |
| ៧ | ឈា សឿន | ៥៦ | ប | គ្រូ ប.បំ.ស | សាលាប.បំ.ស វត្តភ្នំ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ | ២៦-០១-០៦ | គ្រុនថ្លើម | ៣៣៥៤កស្ព | - ៤៨០៩ |
| ៨ | យី គន់ | ៥៦ | ប | គ្រូ ប.បំ.ស | សន្ទុង ស្រុកមេសាង ខេត្តព្រៃវែង | ១៦-០៤-០៦ | រោគាពាធ | ៥៤០៣ពវ | - ៤៨១០ |
| ៩ | ឯក សាគម៉ត | ៦៤ | ប | គ្រូ ប.បំ.ស | សាលាប.បំ.ស ស្វាយពល ស្រុកពារាំង ខេត្តព្រៃវែង | ១១-០៤-០៦ | រោគាពាធ | ៦៤៥២ពវ | - ៤៨១១ |
| ១០ | សុខ បាន | ៥៥ | ប | គ្រូ ប.បំ.ស | សាលាប.បំ.ស ពេជ្ញីរតន៍-កំពង់ត្របែក-ព្រៃវែង | ១៦-០៤-០៦ | រោគាពាធ | ១៨៥២ពវ | - ៤៨១២ |
| ១១ | ចេង អ៊ុន | ៤៥ | ប | កម្មករ | មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ខេត្តព្រៃវែង | ១៧-០៥-០៦ | រោគាពាធ | ១២៩ពវ | - ៤៨១៣ |
| ១២ | មាស ផុន | ៥២ | ប | គ្រូ ប.បំ.ស | សាលាប.បំ.ស ពោធិរោង ស្រុកសណ្តាន់ ខេត្តកំពង់ធំ | ២៥-០២-០៦ | រោគាពាធ | ២៨២៦កធ | - ៤៨១៤ |
| ១៣ | ហៃម ស៊ីចាន់ | ៤៩ | ប | គ្រូ ប.បំ.ស | សាលាប.បំ.ស មានជ័យ-សណ្តាន់-កំពង់ធំ | ១៥-០៣-០៦ | រោគាពាធ | ២៨០៣កធ | - ៤៨១៥ |
| ១៤ | ម៉ៅ ឈឺន | ៦៦ | ប | គ្រូ ប.បំ.ស | និវត្តជនសាលាទួលក្បិល-កំពង់ស្វាយ-កំពង់ធំ | ០៥-០៥-០៦ | រោគាពាធ | ១៧៣២កធ | - ៤៨១៦ |
| ១៥ | ជួន ជរ | ៦០ | ប | គ្រូ ម.ប.ភ | និវត្តជនការិ.អ.យ.ក. ស្រុកស្ទោង-កំពង់ធំ | ០៦-០៥-០៦ | រោគាពាធ | ២៣០៩កធ | - ៤៨១៧ |
| ១៦ | រ័ត្ន វណ្ណៈ | ៤៨ | ប | គ្រូ ម.ប.ភ | មន្ទីរ អ.យ.ក. រាជធានីភ្នំពេញ | ២៤-០៤-០៦ | លើសឈាម | ៩៣ភព | - ៤៨១៨ |
| ១៧ | វង្ស តារា | ៣៦ | ប | គ្រូ ម.ប.ភ | វិ.សន្ធរម៉ុក រាជធានីភ្នំពេញ | ០៥-០៤-០៦ | គ្រោះថ្នាក់ចរាចរ | ៨១២០ភព | - ៤៨១៩ |
| ១៨ | ម៉ម សៅរី | ៧០ | ស | គ្រូ ប.បំ.ស | និវត្តជនសាលាបាក់ទូក រាជធានីភ្នំពេញ | ២៨-០៤-០៦ | រោគាពាធ | ១៤២៩ភព | - ៤៨២០ |
| ១៩ | ម៉ក់ ជា | ៧៦ | ប | គ្រូ ប.បំ.ស | និវត្តជន សាលាវត្តសន្សំកុសល រាជធានីភ្នំពេញ | ១៥-០៥-០៦ | ជរាពាធ | ១០៨៧ភព | - ៤៨២១ |
| ២០ | ម៉ៅ ឈិនហ៊ី | ៣៦ | ប | គ្រូ ម.ទ.ក | វិ.សាមគ្គី រាជធានីភ្នំពេញ | ១៩-០៥-០៦ | រោគាពាធ | ៧៤៧៦ភព | - ៤៨២២ |
| ២១ | នួន ស៊ុយ | ៦១ | ប | គ្រូ ប.បំ.ស | និវត្តជនស្រុកដូនកែវ ខេត្តតាកែវ | ០៧-០៤-០៦ | រោគាពាធ | ៣៦០៨តក | - ៤៨២៣ |
| ២២ | កែវ សាវឿន | ៥១ | ប | គ្រូ ម.ប.ភ | វិ.ហ.ស អង្គប្រិយ៍-សំរោង-តាកែវ | ១៩-០៤-០៦ | ធ្លាក់ឈាម | ៣២១៦តក | - ៤៨២៤ |
| ២៣ | ប្រាក់ ចន្ថន | ៣៦ | ស | គ្រូ ប.បំ.ស | សាលាប.បំ.ស សែន ភាស-សំរោង-តាកែវ | ២១-០៤-០៦ | មហារីកស្បូន | ៥៨៤២តក | - ៤៨២៥ |
| ២៤ | សួស ហួ | ៧៥ | ប | គ្រូ ប.បំ.ស | និវត្តជន ស្រុកបាទី ខេត្តតាកែវ | ១០-០៤-០៦ | ជរាពាធ | ១៩៣១តក | - ៤៨២៦ |
| ២៥ | រ៉ែន សារុន | ៥៨ | ប | គ្រូ ម.ប.ភ | វិ.សុខ អាន សូរិយា-គិរីវង់-តាកែវ | ២២-០៥-០៦ | រោគាពាធ | ៤១១៥តក | - ៤៨២៧ |
| ២៦ | ព្រំ ម៉ែត | ៧១ | ប | គ្រូ ប.បំ.ស | និវត្តជន ស្រុកបាទី ខេត្តតាកែវ | ២៧-០៥-០៦ | រោគាពាធ | ១១៧៩តក | - ៤៨២៨ |
| ២៧ | គីម សិរិទ្ធ | ៥០ | ប | គ្រូ ប.បំ.ស | សាលាប.បំ.ស ពូនភ្នំ-បាទី-តាកែវ | ២៩-០៥-០៦ | រោគាពាធ | ១៨៣៦តក | - ៤៨២៩ |
| ២៨ | ភ្លឹង វិសុទ្ធ | ៣០ | ប | គ្រូ ប.បំ.ស | សាលាប.បំ.ស ខ្វាស់-សិរីសោភ័ណ-បន្ទាយមានជ័យ | ១៨-០៣-០៦ | គ្រោះថ្នាក់ចរាចរ | ៣៩៨៧បជ | - ៤៨៣០ |
| ២៩ | ទុំ វ៉ាន់នី | ៣៩ | ប | គ្រូ ប.បំ.ស | សាលាប.បំ.ស ចតុមុខ គណៈកម្មាធិការនាយក | ១៣-០៥-០៦ | គ្រោះថ្នាក់ចរាចរ | ៣៤០៩តក | - ៤៨៣១ |
| ៣០ | ម៉ម ស៊ីផុន | ៣២ | ប | គ្រូ ប.បំ.ស | សាលាមធ្យម.គរុកោសល្យមត្តេយ្យមជ្ឈិម គណៈកម្មាធិការនាយក | ២៦-០៥-០៦ | មហារីកឈាម | ២៩៤៩តក | - ៤៨៣២ |
| ខ. មរណៈភាពគ្រួសារសមាជិក. | | | | | | | | | |
| ល.រ | គោត្តនាម-នាម | អាយុ | ភេទ | មុខរបរ | អង្គភាពបំរើការរបស់សមាជិក | ថ្ងៃ ខែ ឆ្នាំមរណៈ | មូលហេតុ | លេខសំគាល់ | ផ្សេងៗ |
| ១ | ទិម ជា | ៤៨ | ស | ធ្វើស្រែ | ប្រពន្ធលោកវ៉ាង ញ៉ូន សាលាត្រសក់ផ្អែម-តាកែវ | ១៤-០៤-០៦ | រោគាពាធ | ៣៥៧៣តក | - ៣០៦៨ |
| ២ | មាស ម៉ារៀ | ៥៣ | ស | ធ្វើស្រែ | ប្រពន្ធលោកចាន់ ហុង និវត្តជន-សំរោង-តាកែវ | ១៣-០៤-០៦ | លើសឈាម | ៣០០៩តក | - ៣០៦៩ |
| ៣ | ប្រាក់ ចន្ថន | ៣៦ | ស | គ្រូបង្រៀន | ប្រពន្ធលោកប្រាក់ អាន សាលាសែន ភាស-តាកែវ | ២៣-០៤-០៦ | មហារីកស្បូន | ៥៨៤៦តក | - ៣០៧០ |
| ៤ | អ៊ុំ ណាម | ៦០ | ស | ធ្វើស្រែ | ប្រពន្ធលោកម៉ឹង នួន ស្រុកត្រាំកក់ ខេត្តតាកែវ | ១២-០៥-០៦ | រោគាពាធ | ៥៥៦០តក | - ៣០៧១ |
| ៥ | ឈឿន សិលា | ៣៩ | ប | ធ្វើស្រែ | ប្តីអ.ស សុខ ស៊ីច័ន្ទ សាលាចំបក់-បាទី-តាកែវ | ២៩-០៥-០៦ | រោគាពាធ | ១៨០៣តក | - ៣០៧២ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៦ | សើម សុគន្ធ | ៣២ | ស | ធ្វើស្រែ | ប្រពន្ធលោកប្រាក់ សារុន សាលាតាលាស់-មោងឫស្សី-បាត់ដំបង | ០៣-០២-០៦ | របេង | ៤១៩៩បប | - ៣០៧៣ |
| ៧ | ប៊ុណ ច័ន្ទមណី | ៣៣ | ប | គ្រូបង្រៀន | ប្ដីអ.ស ទុន សុខា ការិ.អ.យ.ក-បាត់ដំបង-បាត់ដំបង | ១៨-០២-០៦ | រោគពាធ | ១១០៣បប | - ៣០៧៤ |
| ៨ | ឯក ភាន | ៧៥ | ប | មន្ត្រីឃុំ | ប្ដីអ.ស សុក បូវណ្ណារី-ឯកភ្នំ-បាត់ដំបង | ១៧-០៣-០៦ | តាំងបេះដូង | ៤២៩៥បប | - ៣០៧៥ |
| ៩ | ជីម ប៊ុនរេត | ៣៤ | ប | ធ្វើស្រែ | ប្ដីអ.ស អោម ចំប៊ី ស្រុកបាត់ដំបង-បាត់ដំបង | ១៩-០៣-០៦ | រោគពាធ | ៩៤៧៧បប | - ៣០៧៦ |
| ១០ | ហម គី | ៣៧ | ប | ធ្វើស្រែ | ប្ដីអ.ស ឈឿន លី ស្រុកមោងឫស្សី ខេត្តបាត់ដំបង | ១៤-០៩-០៥ | ជំងឺថ្លើម | ៤២០៥បប | - ៣០៧៧ |
| ១១ | អ៊ុំ ភាគរៈ | ៣៣ | ប | ធ្វើស្រែ | ប្ដីអ.ស ប៊ុត ស៊ីថុន សាលាឈើទាល-កៀនស្វាយ-កណ្ដាល | ២៤-០៣-០៦ | រោគពាធ | ៧៤២៣កណ | - ៣០៧៨ |
| ១២ | ឈិត សារ៉េម | ៤៩ | ស | ធ្វើស្រែ | ប្រពន្ធលោកឌុក យ៉ានី ការិ.ចំនេះទូទៅនៃមន្ទីរអ.យ.ក-កណ្ដាល | ១៥-០៤-០៦ | រោគពាធ | ៥៥០០កណ | - ៣០៧៩ |
| ១៣ | វត្ត នាយ | ៥៨ | ប | ធ្វើស្រែ | ប្ដីអ.ស ញ៉ុក សេរី សាលាតាទក ស្រុកពួក ខេត្តសៀមរាប | ០៣-០៤-០៦ | ជំងឺសួត | ២៦៣៥សរ | - ៣០៨០ |
| ១៤ | អោក ស៊ុណាត | ៤០ | ស | កសិករ | ប្រពន្ធលោកគុំ ស្រេង សាលាកោះចិន-កោះសូទិន-កំពង់ចាម | ២១-០៣-០៦ | រោគពាធ | ២០៤២កច | - ៣០៨១ |
| ១៥ | ឃួន ឈុនឡេង | ៧២ | ស | កសិករ | ប្រពន្ធលោកស៊ុំ ស៊ាន វ.ជីហែ-កោះសូទិន-កំពង់ចាម | ៣១-០១-០៦ | ជរាពាធ | ១៨៣៤កច | - ៣០៨២ |
| ១៦ | ញាន ម៉េត | ៦៣ | ស | កសិករ | ប្រពន្ធលោកខែក ស៊ីថន សាលាទួលខ្វាវ-ត្បូងឃ្មុំ-កំពង់ចាម | ២០-០៤-០៦ | ធ្លាក់ពីលើផ្ទះ | ៨៧៥០កច | - ៣០៨៣ |
| ១៧ | សុខ ឈុនអ៊ី | ៥២ | ប | កសិករ | ប្ដីអ.ស អ៊ីវ ណារី អនុវិ.ខ្សាច់អណ្ដែត-ឆ្លូង-ក្រចេះ | ២៣-០៤-០៦ | រោគពាធ | ១៦៣៦ក្រច | - ៣០៨៤ |
| ១៨ | អ៊ុំ ហុន | ៤៦ | ស | កសិករ | ប្រពន្ធលោកប៊ុច សារឿន សាលាក្រាំងពញា-ឧដុង្គ-កំពង់ស្ពឺ | ០២-០៣-០៦ | របេង | ១៨១០កស្ព | - ៣០៨៥ |
| ១៩ | ព្រៀម ឡា | ៥០ | ស | កសិករ | ប្រពន្ធលោកសៅ ប៊ុនធឿន សាលាពាមឃ្លៃ-សំរោងទង-កំពង់ស្ពឺ | ១០-០៤-០៦ | រោគពាធ | ២៤០៨កស្ព | - ៣០៨៦ |
| ២០ | ប្រាក់ ផន | ៣៦ | ប | កសិករ | ប្ដីអ.ស ប៉ែន ភារី អនុវិ.មហាសាំង-ភ្នំស្រួច-កំពង់ស្ពឺ | ០៤-០៤-០៦ | គ្រោះថ្នាក់ចរាចរ | ១៤១៦កស្ព | - ៣០៨៧ |
| ២១ | ម៉ៅ ស៊ូ | ៧១ | ស | កសិករ | ប្រពន្ធលោករស់ ហឿង សាលាព្រៃកន្ទ្បាយ "២" ព្រៃវែង | ២០-០៣-០៦ | រោគពាធ | ៤៩៩៣ពវ | - ៣០៨៨ |
| ២២ | ហាយ សុខុន | ៦១ | ស | កសិករ | ប្រពន្ធលោកទី លាង សាលាវត្តព្រៃកន្ទ្បាយ-ព្រៃវែង | ០៩-០៣-០៦ | រោគពាធ | ៥០០៦ពវ | - ៣០៨៩ |
| ២៣ | សាន សុខន | ៤០ | ប | ប្រជាជន | ប្ដីអ.ស ស៊ឹម មិត្តារុណ វិ.វត្តកោះ រាជធានីភ្នំពេញ | ១៩-០៥-០៦ | រោគពាធ | ៣៥៥១ភព | - ៣០៩០ |
| ២៤ | គឹម សារ៉េត | ៤៣ | ប | ប្រជាជន | ប្ដីអ.ស អ៊ិក ពុទ្ធារី សាលាទួលគោក រាជធានីភ្នំពេញ | ២៤-០៥-០៦ | តាំងបេះដូង | ៦៤៣៥ភព | - ៣០៩១ |
| ២៥ | ចាន់ ស្រីពៅ | ៣៤ | ស | ប្រជាជន | ប្រពន្ធលោកម៉ុង រុន សាលាបឹងត្របែកខាងត្បូង រាជធានីភ្នំពេញ | ២៦-០៥-០៦ | មហារីកបំពង់ក | ៧៣០០ភព | - ៣០៩២ |
| ២៦ | ឡាយ ចាន់ធូ | ៥៦ | ស | ប្រជាជន | ប្រពន្ធលោកជូ សេង នា.ចែកផ្សាយ និងទីផ្សារ | ០៤-០៤-០៦ | គ្រោះថ្នាក់ចរាចរ | ៣៤ត.ក | - ៣០៩៣ |

មេត្តាប្រមូលភាគទានឧបត្ថម្ភសពប្រចាំខែ មិថុនា ឆ្នាំ ២០០៦ អោយទាន់ពេលវេលា ដើម្បីដោះស្រាយជូនគ្រួសារសព ។

**<u>ចំណាំ:</u>**

ត្រូវបង់ប្រាក់ឧបត្ថម្ភសពសមាជិក...................... ៣០ សព x ៣០៛ = ៩០០ រៀល

សពគ្រួសារ.................................................. ២៦ សព x ១៥៛ = ៤០០ រៀល

ភាគទានប្រចាំខែ .............................................................. = ១០០ រៀល

ភាគទានសាងសង់ផ្ទះគ្រូបង្រៀន........................................ = ៣០០ រៀល

**សរុប** = ១៧០០រៀល

ភ្នំពេញ, ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០៦

**ជ.គណៈកម្មាធិការនាយក**

**អគ្គលេខាធិការរង**

**ស្វាយ និត្យ**



# យុវសិស្ស ឌី តុងសារ

សិស្សវិទ្យាល័យទួលទំពូង បានប្រលងជាប់ជ័យលាភីមេដាយមាស

ក្នុងការប្រលងអន្តរជាតិអ្នកវិទ្យាសាស្ត្រវ័យក្មេងក្រោមអាយុ ១៦ឆ្នាំ

ហៅកាត់ ***IJSO (International Junior Science Olympiad)*** ៣មុខវិជ្ជា (រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា)

ដែលមានបេក្ខជនសរុប ១៩៦នាក់ មកពី ៣៦ប្រទេស បានចូលរួម។

សម័យប្រលង : ថ្ងៃទី ៤ ដល់ ១៣ ធ្នូ ២០០៥

នៅទីក្រុង *Yogyakarta* ប្រទេសឥណ្ឌូណេស៊ី